# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើ
# សេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **វ៉ាន់ គុណខេម**

សាស្ត្រាចារ្យណែនាំ

លោក **ព្រុំ សុគុណ**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ វ៉ាន់ តុលាខេម ជានិស្សិតឆ្នាំទី៤ ជំនាន់ទី១០ ថ្នាក់បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណជាតិយេ្យាភាព ជូនចំពោះ៖

- **មាតាបិតា** ដែលលោកទាំងពីរបានពុះពាររាល់ការលំបាក ដើម្បីចិញ្ចឹមបីបាច់ថែរក្សាយ៉ាងជិតដល់ អប់រំទូន្មានប្រៀនប្រដៅ ជួយឧបត្ថម្ភគ្រប់បែបយ៉ាងទាំងផ្នែកស្មារតីនិងសម្ភារ និងទំនុកបម្រុងខ្ញុំបាទតាំងពីតូចរហូតដល់ធំដោយមិនដែលគិតពីការនឿយហត់ ឱ្យខ្ញុំបាទបានសិក្សារហូតបានលទ្ធផលដូចសព្វថ្ងៃនេះ
- **ឯកឧត្តម អគ្គទេសាភិបាល នៃធនាគារជាតិនៃកម្ពុជា** ដែលបានអនុញ្ញាតឱ្យខ្ញុំបាទបានចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជា ហើយការណ៍នេះបានផ្តល់ឱកាសឱ្យខ្ញុំបាទបានសិក្សាបន្ថែមទាំងចំណេះដឹងនិងចំណេះធ្វើ ព្រមទាំងពង្រឹងនិងអភិវឌ្ឍសមត្ថភាពរបស់ខ្ញុំបាទជាបន្តបន្ទាប់
- **លោកជំទាវអគ្គនាយកបច្ចេកទេស លោកអគ្គនាយករងបច្ចេកទេស លោក លោកស្រីអនុប្រធាននាយកដ្ឋាន និងរៀមច្បងមន្ត្រីបុគ្គលិកនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ នៃធនាគារជាតិនៃកម្ពុជា** ដែលបានផ្តល់ដំបូន្មានល្អៗ ជួយបង្ហាត់បង្រៀន ផ្តល់ឯកសារនានាសម្រាប់ឱ្យខ្ញុំបាទសិក្សានិងស្រាវជ្រាវ ព្រមទាំងចែករំលែកចំណេះដឹងនិងបទពិសោធន៍ដ៏មានតម្លៃដល់ខ្ញុំបាទ
- **ឯកឧត្តមសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានអនុញ្ញាតឱ្យខ្ញុំបាទសរសេរសារណានេះ
- **លោកសាស្ត្រាចារ្យ ព្រុំ សុគុណ** ដែលបានណែនាំ បង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ផ្តល់ជាដំបូន្មាន មតិយោបល់កែតម្រូវល្អៗជាច្រើនដែលអាចជួយខ្ញុំបាទក្នុងការសិក្សា ការងារ និងការសម្រេចបាននូវការសរសេរសារណានេះ និង
- មិត្តភក្តិជិតស្និទ្ធទាំងអស់ ដែលបានចូលរួមផ្តល់ជាកម្លាំងចិត្តដល់ខ្ញុំបាទក្នុងការសម្រេចកិច្ចការនេះ។

ជាបរិយោសាន ខ្ញុំបាទ សូមប្រសិទ្ធិពរជ័យដល់ មាតាបិតា ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូសាស្ត្រាចារ្យ និងមិត្តភក្តិទាំងអស់ សូមទទួលបានជោគជ័យនូវរាល់ភារកិច្ចទាំងអស់ និងជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ប្រទេសកម្ពុជាជាប្រទេសដែលធ្លាប់ឆ្លងកាត់សង្គ្រាម អស្ថិរភាពនយោបាយ អស្ថិរភាពសេដ្ឋកិច្ច និងការបំបាត់ចោលយ៉ាងព្រៃផ្សៃនូវសិទ្ធិសេរីភាព ទីផ្សារ ប្រព័ន្ធរូបិយវត្ថុ ធនាគារ និងហិរញ្ញវត្ថុ។ ជាលទ្ធផល នៅក្នុងដំណើរការនៃការស្តារសេដ្ឋកិច្ចពីបាតដៃទទេ ប្រាក់ដុល្លារអាមេរិកបានហូរចូលមកប្រទេសកម្ពុជាជាបន្តបន្ទាប់ ក្រោមរូបភាពជាជំនួយនិងការវិនិយោគ ហើយប្រជាពលរដ្ឋក៏បានចាប់ផ្តើមងាកទៅរកការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ដើម្បីការពារអំណាចទិញរបស់ពួកគេ។

ក្នុងរយៈពេលជាងពីរទសវត្សរ៍ ប្រាក់ដុល្លារអាមេរិកបានចរាចរនៅក្នុងសេដ្ឋកិច្ចកម្ពុជាទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិដែរ ដោយវាបានបម្រើមុខងារជាមធ្យោបាយដោះដូរ ខ្នាតវាស់តម្លៃ និងការសន្សំ។ ការណ៍នេះបានអនុញ្ញាតឱ្យសេដ្ឋកិច្ចកម្ពុជាឈានទៅរកស្ថិរភាព និងប្រព័ន្ធធនាគារកម្ពុជាដំណើរការបានដូចធម្មតាវិញ។ ខណៈដែលកម្ពុជាទទួលបានអំណោយផលពីស្ថានភាពដុល្លាររូបនីយកម្ម សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ដូចជា ហានិភ័យអត្រាប្តូរប្រាក់ ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ចដែលអាចកើតមានឡើងនៅសហរដ្ឋអាមេរិក ជាដើម។ ដូចនេះ ដើម្បីត្រៀមខ្លួនសម្រាប់ទប់ទល់នឹងហានិភ័យទាំងនេះ និងដើម្បីបន្តជំរុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌ អ្នកស្រាវជ្រាវគ្រប់រូបគួរសិក្សាឱ្យបានដិតដល់ពីឥទ្ធិពលនៃដុល្លាររូបនីយកម្មដែលកំពុងមានកម្រិតខ្ពស់នេះមកលើសេដ្ឋកិច្ចប្រទេសកម្ពុជា។ ការយល់ដឹងឱ្យបានស៊ីជម្រៅទៅលើបញ្ហានេះ នឹងជាជំនួយដល់ការសម្រេចចិត្តដាក់ចេញនិងអនុវត្តគោលនយោបាយបន្តបន្ទាប់ ក្នុងគោលដៅអភិវឌ្ឍសង្គមជាតិនិងសេដ្ឋកិច្ចនាពេលអនាគត។

ដោយពិនិត្យឃើញពីភាពចាំបាច់ ក្នុងការសិក្សាលម្អិតទៅលើស្ថានភាពដុល្លាររូបនីយកម្មនៅកម្ពុជា ខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីពី "ឥទ្ធិពលនៃដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា" ដើម្បីសរសេរជាឯកសារសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តអ្នកអាន ព្រមទាំងអ្នកស្រាវជ្រាវទាំងឡាយដែលបានចំណាយពេលវេលាដ៏មានតម្លៃអានឯកសារស្រាវជ្រាវនេះ។ ខ្ញុំសង្ឃឹមថា មិត្តអ្នកអាននឹងអាចទទួលបានប្រយោជន៍ច្រើនពីឯកសារមួយនេះ និងបានយល់ដឹងកាន់តែច្បាស់ពីឥទ្ធិពលនៃដុល្លាររូបនីយកម្មចំពោះសេដ្ឋកិច្ចកម្ពុជា ដើម្បីជាទុនសម្រាប់ការសិក្សាស្រាវជ្រាវបន្តនិងការកំណត់វិធានការនិងគោលនយោបាយនានា សំដៅបន្តរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិសម្រាប់កូនចៅជំនាន់ក្រោយយើង។

# មាតិកា

បញ្ជីតារាង ........................................................................ v
បញ្ជីក្រាហ្វ ........................................................................ vi
បញ្ជីរូបភាព ........................................................................ vii
បញ្ជីឧបសម្ព័ន្ធ ........................................................................ viii

# សេចក្តីផ្តើម

១. លំនាំបញ្ហា ........................................................................ ១
២. ចំណោទបញ្ហា ........................................................................ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........................................................................ ២
៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........................................................................ ៣
៥. សារៈសំខាន់នៃការស្រាវជ្រាវ ........................................................................ ៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................................................ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................................................ ៤

# ជំពូកទី១
# រំព្ញកទ្រឹស្តី

១.១. អ្វីទៅជារូបិយវត្ថុ ........................................................................ ៦
១.២. មុខងារនៃរូបិយវត្ថុ ........................................................................ ៧
    ១.២.១. មធ្យោបាយដោះដូរ ........................................................................ ៧
    ១.២.២. ខ្នាតវាស់តម្លៃ ........................................................................ ៨
    ១.២.៣. មុខងាររក្សាតម្លៃ ........................................................................ ៩
    ១.២.៤. ស្តង់ដារសម្រាប់ការសងបំណុល ........................................................................ ៩
១.៣. ការវិវឌ្ឍនៃរូបិយវត្ថុ៖ ពីប្រព័ន្ធដោះដូរទំនិញនឹងទំនិញរហូតដល់ប្រព័ន្ធរូបិយវត្ថុមិនមែនក្រដាសប្រាក់ ........................................................................ ៩
    ១.៣.១. ប្រព័ន្ធដោះដូរទំនិញនឹងទំនិញ ........................................................................ ៩
    ១.៣.២. រូបិយវត្ថុទំនិញ ........................................................................ ១០
    ១.៣.៣. រូបិយវត្ថុក្រឹត្យ ........................................................................ ១០

១.៣.៤. មូលប្បទានបត្រ ............................................................................................... ១១
១.៣.៥. ប្រព័ន្ធទូទាត់អេឡិចត្រូនិក ............................................................................. ១១
១.៣.៦. រូបិយវត្ថុអេឡិចត្រូនិក .................................................................................... ១២
១.៤. បរិមាណផ្គត់ផ្គង់រូបិយវត្ថុ ..................................................................................... ១៣
១.៥. តម្រូវការរូបិយវត្ថុ ................................................................................................... ១៤
១.៥.១. មូលហេតុនៃការកាន់រូបិយវត្ថុ ........................................................................ ១៤
១.៥.២. កត្តាដែលជះឥទ្ធិពលដល់តម្រូវការរូបិយវត្ថុ ........................................................ ១៥
១.៦. ដុល្លារូបនីយកម្ម ..................................................................................................... ១៦
១.៧. ប្រភេទដុល្លារូបនីយកម្ម ......................................................................................... ១៧
១.៧.១. ដុល្លារូបនីយកម្មផ្លូវការ ................................................................................... ១៧
១.៧.២. ដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការ ................................................................. ១៧
១.៧.៣. ដុល្លារូបនីយកម្មមិនផ្លូវការ .............................................................................. ១៨
១.៨. ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ច ........................................................... ១៩
១.៨.១. គុណសម្បត្តិនៃដុល្លារូបនីយកម្ម ....................................................................... ១៩
១.៨.២. គុណវិបត្តិនៃដុល្លារូបនីយកម្ម ......................................................................... ២០

## ជំពូកទី២
## ធនាគារជាតិនៃកម្ពុជា

២.១. ទិដ្ឋភាពទូទៅនៃធនាគារជាតិនៃកម្ពុជា ..................................................................... ២១
២.២. ស្លាកសញ្ញា Logo របស់ធនាគារជាតិនៃកម្ពុជា .......................................................... ២៣
២.៣. បេសកកម្មចម្បង និងសកម្មភាពរបស់ធនាគារជាតិនៃកម្ពុជា ........................................ ២៤
២.៤. ប្រវត្តិនៃធនាគារជាតិនៃកម្ពុជា ................................................................................. ២៤
២.៤.១. ឯករាជ្យភាពនិងអធិបតេយ្យភាពរូបិយវត្ថុ និងការកកើតឡើងនៃប្រព័ន្ធធនាគារ .... ២៤
២.៤.២. ដំណាក់កាលឆ្នាំ១៩៥៤-១៩៧៥៖ ជាតូបនីយកម្មប្រព័ន្ធធនាគារ
និងការដួលរលំនៃសេដ្ឋកិច្ចនិងរូបិយវត្ថុ ................................................................ ២៥
២.៤.៣. ដំណាក់កាលឆ្នាំ១៩៧៥-១៩៧៩៖ ការលុបបំបាត់ចោលនូវរូបិយវត្ថុ
និងប្រព័ន្ធធនាគារ .................................................................................................. ២៧
២.៤.៤. ដំណាក់កាលឆ្នាំ១៩៧៩-១៩៨៩៖ ការស្តារប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចឡើងវិញ .. ២៨

២.៤.៥. ដំណាក់កាលអន្តរកាលឆ្នាំ១៩៨៩-១៩៩៣៖ កំណែទម្រង់ពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារសេរី ..... ៣០
២.៤.៦. ដំណាក់កាលឆ្នាំ១៩៩៣ ដល់ពេលបច្ចុប្បន្ន៖ ដំណើរទៅរកភាពរីកចម្រើននៃប្រព័ន្ធធនាគារនិងសេដ្ឋកិច្ច..... ៣០
២.៥. មុខងារ និងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា..... ៣២
២.៦. គោលនយោបាយរូបិយវត្ថុ..... ៣៣
២.៦.១. គោលដៅសំខាន់ៗនៃគោលនយោបាយរូបិយវត្ថុ ..... ៣៤
២.៦.២. ប្រភេទនៃគោលនយោបាយរូបិយវត្ថុ..... ៣៦
២.៦.៣. ឧបករណ៍គោលនយោបាយរូបិយវត្ថុ ..... ៣៦
២.៦.៣.១. ប្រាក់បម្រុងកាតព្វកិច្ច ..... ៣៧
២.៦.៣.២. ការធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ..... ៣៨
២.៦.៣.៣. មូលបត្រអាចជួញដូរបាន ..... ៣៩
២.៦.៣.៤. ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ..... ៤១

## ជំពូកទី៣

## ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

៣.១. ការកកើតនិងមូលហេតុនៃដុល្លារូបនីយកម្មនៅកម្ពុជា..... ៤៤
៣.២. ស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា..... ៤៩
៣.៣. គុណសម្បត្តិនៃដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ចកម្ពុជា..... ៥៣
៣.៣.១. ការរួមចំណែករក្សាស្ថិរភាពអត្រាប្តូរប្រាក់នៃរូបិយវត្ថុក្នុងស្រុក និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច..... ៥៣
៣.៣.២. ការទាក់ទាញលំហូរវិនិយោគ ព្រមទាំងលើកកម្ពស់ភាពស៊ីជម្រៅហិរញ្ញវត្ថុនិងបរិយាប័ន្នហិរញ្ញវត្ថុ..... ៥៧
៣.៣.៣. ជំរុញការវិនិយោគក្នុងស្រុកដោយថ្លៃដើមទុនសម្រាប់ប្រាក់ដុល្លារមានកម្រិតទាប..... ៥៩
៣.៣.៤. ការបើកទូលាយសមាហរណកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ..... ៦១
៣.៤. គុណវិបត្តិនៃដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ចកម្ពុជា..... ៦២
៣.៤.១. ការបាត់បង់ចំណូលពីការបោះពុម្ពប្រាក់..... ៦២

៣.៤.២. កាត់បន្ថយទុនបម្រុងអន្តរជាតិ ...................................................... ៦៣
៣.៤.៣. ការអនុវត្តគោលនយោបាយរូបិយវត្ថុមិនមានប្រសិទ្ធភាព ............................ ៦៥
៣.៤.៤. បាត់បង់លទ្ធភាពជាអ្នកឱ្យខ្ចីចុងក្រោយ ...................................................... ៦៧
៣.៤.៥. បង្កើនចំណាយប្រតិបត្តិការ និងហានិភ័យសន្ទនីយភាព ................................ ៦៧
៣.៤.៦. មិនបានចូលរួមលើកស្ទួយអត្តសញ្ញាណជាតិ ................................................ ៦៨

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ............................................................................................ ៦៩
២. អនុសាសន៍ .................................................................................................... ៧០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាងការប៉ាន់ស្មានចំណូលពីការបោះពុម្ពក្រដាសប្រាក់នៅកម្ពុជា ឆ្នាំ១៩៩៤-២០០១ ...........៦៣

# បញ្ជីរូបភាព


រូបភាពទី១៖ រចនាសម្ព័ន្ធនៃធនាគារជាតិនៃកម្ពុជា ........ ២២

រូបភាពទី២៖ ស្លាកសញ្ញា Logo ជាភាសាខ្មែរ ........ ២៣

រូបភាពទី៣៖ ស្លាកសញ្ញា Logo ជាអង់គ្លេស ........ ២៣

រូបភាពទី៤៖ ស្លាកសញ្ញា Logo ជាភាសាបារាំង ........ ២៣

រូបភាពទី៥៖ ប្រាក់ព្យាស់ចរាចរណ៍ក្នុងសម័យអាណាព្យាបាលបារាំង ........ ២៥

រូបភាពទី៦៖ អគារធនាគារជាតិនៃកម្ពុជា កាលពីឆ្នាំ១៩៥៥ ........ ២៦

រូបភាពទី៧៖ ប្រាក់រៀលចរាចរណ៍នៅក្នុងសម័យសង្គមរាស្ត្រនិយម ........ ២៦

រូបភាពទី៨៖ អគារស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាដែលត្រូវបានកម្ទេចចោល ក្នុងសម័យ ប៉ុល ពត ........ ២៨

រូបភាពទី៩៖ រូបិយវត្ថុសន្និកសន្ធាប់ដែលត្រូវបានបោះបង់ចោលក្នុងសម័យ ប៉ុល ពត ........ ២៨

រូបភាពទី១០៖ ការស្រូបយកនិងផ្តល់សន្ទនីយភាពតាមរយៈមូលបត្រអាចជួញដូរបាន និង ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ........ ៤១

# បញ្ជីក្រាហ្វ

ក្រាហ្វទី១៖ អត្រាអតិផរណា និងអត្រាប្តូរប្រាក់ជាមធ្យមពីឆ្នាំ១៩៨៩-១៩៩៥ .......................... ៤៨
ក្រាហ្វទី២៖ កម្រិតដុល្លារូបនីយកម្មនៅកម្ពុជា ...................................................................... ៥០
ក្រាហ្វទី៣៖ កំណើន និងសមាសធាតុរូបិយវត្ថុទូទៅ ............................................................... ៥១
ក្រាហ្វទី៤៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ឆ្នាំ២០១៥-ឆមាសទី១ ឆ្នាំ២០១៧ ...... ៥៤
ក្រាហ្វទី៥៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ឆ្នាំ១៩៩៥-២០១៦............................. ៥៥
ក្រាហ្វទី៦៖ អត្រាអតិផរណានៅកម្ពុជា ឆ្នាំ២០០១-២០១៦ ..................................................... ៥៥
ក្រាហ្វទី៧៖ កំណើន ផ.ស.ស និងចំណូលរបស់ប្រជាជនម្នាក់ៗ ............................................. ៥៦
ក្រាហ្វទី៨៖ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ និងកម្រិតដុល្លារូបនីយកម្ម....................................... ៥៨
ក្រាហ្វទី៩៖ ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទាននៃវិស័យធនាគារធៀបនឹងផ.ស.ស ............ ៥៨
ក្រាហ្វទី១០៖ បរិយាប័ន្នហិរញ្ញវត្ថុកម្ពុជា ........................................................................... ៥៩
ក្រាហ្វទី១១៖ អត្រាការប្រាក់ឥណទានគ្រឹះស្ថានធនាគារ ....................................................... ៦០
ក្រាហ្វទី១២៖ អត្រាការប្រាក់ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ................................................. ៦០
ក្រាហ្វទី១៣៖ សមាមាត្រនៃការនាំចេញសម្លៀកបំពាក់........................................................... ៦១
ក្រាហ្វទី១៤៖ ស្ថានភាពទុនបម្រុងអន្តរជាតិកម្ពុជា ................................................................ ៦៤

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ស្ថានភាពរូបិយវត្ថុនៅកម្ពុជា ឆ្នាំ១៩៩៣-២០០១
ឧបសម្ព័ន្ធទី២៖ អត្រាប្តូរប្រាក់នៅកម្ពុជា ឆ្នាំ១៩៩០-២០០១
ឧបសម្ព័ន្ធទី៣៖ ស្ថានភាពអតិផរណានៅកម្ពុជា ឆ្នាំ១៩៩៤-២០០១
ឧបសម្ព័ន្ធទី៤៖ បណ្តាញនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
ឧបសម្ព័ន្ធទី៥៖ ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១៦-២០១៧
ឧបសម្ព័ន្ធទី៦៖ គណនីវិភាគធនាគារជាតិនៃកម្ពុជា
ឧបសម្ព័ន្ធទី៧៖ គណនីវិភាគធនាគារពាណិជ្ជ
ឧបសម្ព័ន្ធទី៨៖ ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ
ឧបសម្ព័ន្ធទី៩៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា
ឧបសម្ព័ន្ធទី១០៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ឆ្នាំ២០០៧-២០១៧
ឧបសម្ព័ន្ធទី១១៖ ស្ថានភាពវិនិយោគអន្តរជាតិ ឆ្នាំ២០១០-២០១៦
ឧបសម្ព័ន្ធទី១២៖ ស្ថានភាពបំណុលក្រៅប្រទេស ឆ្នាំ២០១០-២០១៦

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

រូបិយវត្ថុត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅតាមតំបន់នីមួយៗ ក្នុងទម្រង់ជាច្រើនប្រភេទ ដូចជា វត្ថុមានតម្លៃ កាស ក្រដាសប្រាក់ និងរូបិយវត្ថុអេឡិចត្រូនិកជាដើម។ ដើម្បីទ្រទ្រង់សេដ្ឋកិច្ច និងសម្រួលដល់ជីវភាពរបស់ប្រជាជន ប្រទេសនីមួយៗបានបង្កើតរូបិយវត្ថុជាតិមួយដែលជាវត្ថុតាង ឆ្លុះបញ្ចាំងពីវប្បធម៌ សាសនា អំណាច និងអត្តសញ្ញាណជាតិរបស់ខ្លួន សម្រាប់ឱ្យប្រជាពលរដ្ឋរបស់ពួកគេអាចប្រើប្រាស់ក្នុងការទូទាត់ទំនិញនិងសេវាកម្ម ការសន្សំ និងការវាស់តម្លៃ។ ការដាក់ឱ្យប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ច ដោយមានធនាគារកណ្តាលជាអ្នកទទួលបន្ទុកបោះផ្សាយរូបិយវត្ថុ មិនត្រឹមតែបម្រើដល់ការប្រកបរបរទទួលទានប្រចាំថ្ងៃ និងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនោះទេ វាថែមទាំងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចអនុវត្តគោលនយោបាយសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព តាមរយៈការធ្វើអន្តរាគមន៍នៅលើទីផ្សារ ការអនុវត្តគោលនយោបាយពន្ធ និងការចំណាយទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាដើម សំដៅសម្រេចគោលដៅជំរុញកំណើនសេដ្ឋកិច្ច ទប់ទល់នឹងហានិភ័យនិងវិបត្តិ និងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ទោះជាយ៉ាងណា ការបើកចំហសេដ្ឋកិច្ច កំណើនពាណិជ្ជកម្មអន្តរជាតិ បម្លាស់ទីនៃអ្នកធ្វើការក្រៅប្រទេស ជំនួយអន្តរជាតិ និងលំហូរមូលធនសេរីពីប្រទេសមួយទៅប្រទេសមួយ បានធ្វើឱ្យរូបិយប័ណ្ណបរទេសជាច្រើនហូរចូលទៅក្នុងសេដ្ឋកិច្ច ជាពិសេសសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍។ វត្តមាននៃរូបិយប័ណ្ណទាំងនេះ បានអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចជ្រើសរើសប្រើប្រាស់ជំនួសរូបិយវត្ថុជាតិ ដោយសារភាពរឹងមាំ និងស្ថិរភាពនៃតម្លៃរូបិយប័ណ្ណទាំងនោះធៀបនឹងរូបិយវត្ថុជាតិ។ ជាទូទៅស្ថានភាពរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍មានលក្ខណៈពហុរូបិយប័ណ្ណ ដោយប្រជាពលរដ្ឋប្រើប្រាស់រូបិយប័ណ្ណបរទេស ជាពិសេស ប្រាក់ដុល្លារអាមេរិក បន្ថែមលើការប្រើប្រាស់រូបិយវត្ថុជាតិរបស់ប្រទេសនោះ ហើយពេលខ្លះរូបិយប័ណ្ណនោះអាចគ្របដណ្តប់ទាំងស្រុងនៅក្នុងសេដ្ឋកិច្ចទៀតផង។

ក្នុងបរិការណ៍សេដ្ឋកិច្ចកម្ពុជា ប្រាក់ដុល្លារអាមេរិកក៏ត្រូវបានធ្វើចរាចរណ៍នៅលើទីផ្សារយ៉ាងលើសលប់ផងដែរ ទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិ "ប្រាក់រៀល"។ ការជ្រើសរើសយកប្រាក់ដុល្លារអាមេរិកមកប្រើប្រាស់របស់ប្រជាពលរដ្ឋខ្មែរ បានកើតឡើងដោយឯកឯង និងមិនត្រូវបានលើកទឹកចិត្តដោយអាជ្ញាធរ ឬដោយការបង្ខំរបស់នរណាម្នាក់ឡើយ។ អស់រយៈពេលជា២ទសវត្សរ៍មកហើយ ប្រជាពលរដ្ឋកម្ពុជាបានប្រើប្រាស់ប្រាក់ដុល្លារអាមេរិកក្នុងការទូទាត់ប្រតិបត្តិការធំៗ និង

ប្រតិបត្តិការសេដ្ឋកិច្ចនៅតាមទីប្រជុំជននិងទីក្រុង ដែលផ្តល់នូវផលប្រយោជន៍និងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ។ មូលហេតុដូចបានរៀបរាប់ខាងលើ ទើបការស្រាវជ្រាវទាក់ទងនឹងស្ថានភាពដុល្លារូបនីយកម្ម នៅក្នុងសេដ្ឋកិច្ចកម្ពុជាត្រូវបានលើកយកមកសិក្សា។

## ២. ចំណោទបញ្ហា

ដោយពិនិត្យឃើញពីសារៈសំខាន់នៃការប្រើប្រាស់រូបិយវត្ថុជាតិ ក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងស្ថិរភាព ហើយដោយការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងសេដ្ឋកិច្ចកម្ពុជាមានទំហំធំគួរឱ្យកត់សម្គាល់ ការសិក្សាលម្អិតទៅលើស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា គឺចាំបាច់ណាស់ ដើម្បីបកស្រាយឱ្យកាន់តែច្បាស់ពីគុណសម្បត្តិនិងគុណវិបត្តិនៃការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងសេដ្ឋកិច្ចនិងថ្លឹងថ្លែងពិចារណាថាគួរទទួលយក ឬមិនទទួលយកដុល្លារូបនីយកម្ម ព្រមទាំងដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់កាន់តែច្បាស់ពីតម្លៃ និងគុណប្រយោជន៍នៃការប្រើប្រាស់ប្រាក់រៀល ហើយពួកគេក៏អាចចូលរួមចំណែកក្នុងយុទ្ធនាការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផងដែរ។

ហេតុដូចនេះហើយ ទើបខ្ញុំបាទសម្រេចជ្រើសរើសយកប្រធានបទ "ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា" មកធ្វើការសិក្សាលើសំណួរស្រាវជ្រាវចំនួនបីដូចខាងក្រោម៖

i/- តើមានកត្តាអ្វីខ្លះដែលជំរុញឱ្យមានការកកើតឡើងនៃដុល្លារូបនីយកម្មនៅកម្ពុជា?

ii/- តើស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជាមានសភាពដូចម្តេចដែរ? និង

iii/- តើដុល្លារូបនីយកម្មមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះចំពោះសេដ្ឋកិច្ចកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

- សិក្សាពីប្រវត្តិនិងការកកើតនៃដុល្លារូបនីយកម្មនៅកម្ពុជា
- សិក្សាពីកត្តាដែលជាមូលហេតុបណ្តាលឱ្យកើតមានដុល្លារូបនីយកម្មនៅកម្ពុជា
- សិក្សាពីស្ថានភាពដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា
- សិក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកចំពោះសេដ្ឋកិច្ចកម្ពុជា និង

- វិភាគពីទម្ងន់នៃគុណសម្បត្តិ និងគុណវិបត្តិនៃដុល្លាវូបនីយកម្ម និងពិចារណាថាតើគួរទទួលយកដុល្លាវូបនីយកម្ម ឬគួរលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិ និងចាប់យកប្រព័ន្ធរូបិយវត្ថុមួយ សេដ្ឋកិច្ចមួយ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់លើស្ថានភាពដុល្លាវូបនីយកម្មជាលក្ខណៈម៉ាក្រូនៅក្នុងសេដ្ឋកិច្ចកម្ពុជា និងពុំបានសិក្សាលម្អិតជាលក្ខណៈមីក្រូទៅលើអង្គភាព ស្ថាប័ន ឬភ្នាក់ងារសេដ្ឋកិច្ចណាមួយនោះទេ។ មិនតែប៉ុណ្ណោះ ឯកសារស្រាវជ្រាវក៏បានសង្កត់ធ្ងន់ផងដែរលើការងាររបស់ធនាគារជាតិនៃកម្ពុជា ពីព្រោះធនាគារកណ្តាលជាតួអង្គដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចដែលមានដុល្លាវូបនីយកម្ម ព្រមទាំងជាអ្នកទទួលបន្ទុកគ្រប់គ្រងដោយផ្ទាល់លើបរិមាណផ្គត់ផ្គង់រូបិយវត្ថុ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងផ្តល់នូវស្ថានភាព និងវិភាគឱ្យបានស៊ីជម្រៅទៅលើដុល្លាវូប-នីយកម្មនៅកម្ពុជា វិភាគពីបញ្ហាប្រឈមនិងសារៈប្រយោជន៍នៃបាតុភូតនេះ សំដៅកំណត់គោលដៅសេដ្ឋកិច្ចនាពេលអនាគត ហើយលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះអាចជាគំនិតមួយសម្រាប់អ្នកធ្វើគោលនយោបាយរូបិយវត្ថុក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ វាជាឯកសារមួយសម្រាប់អ្នកអានដែលជាប្រជាពលរដ្ឋខ្មែរឱ្យស្វែងយល់ពីតម្លៃនៃរូបិយវត្ថុជាតិ និងប្រយោជន៍របស់វាក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងបណ្តុះគំនិតស្រឡាញ់រូបិយវត្ថុជាតិខ្មែរដែលឆ្លុះបញ្ចាំងពីវប្បធម៌ និងអត្តសញ្ញាណជាតិរបស់យើងទាំងអស់គ្នា។ មួយវិញទៀត វាក៏ជាឯកសារសម្រាប់សិស្ស និស្សិត និងជាពិសេសអ្នកស្រាវជ្រាវ ដើម្បីធ្វើជាទុនសម្រាប់ការស្វែងយល់ពីស្ថានភាពដុល្លាវូបនីយកម្មក្នុងប្រទេសកម្ពុជា និងបន្តការសិក្សានិងស្រាវជ្រាវបន្ថែមលើចំណុចដែលខ្វះខាត ឬលើបញ្ហាផ្សេងៗទៀតនៅក្នុងប្រធានបទនេះ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាទៅលើសេដ្ឋកិច្ចដុល្លាវូបនីយកម្មនៃប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រពិពណ៌នា និងប្រើប្រាស់ទិន្នន័យពីរប្រភេទគឺ៖

- ទិន្នន័យចម្បង៖ ការធ្វើកិច្ចសម្ភាសន៍ជាមួយមន្ត្រីជំនាញនៅធនាគារជាតិនៃកម្ពុជា
- ទិន្នន័យបន្ទាប់បន្សំ៖ ទិន្នន័យសេដ្ឋកិច្ចរបស់ធនាគារជាតិនៃកម្ពុជា និងមូលនិធិរូបិយវត្ថុអន្តរជាតិ ឯកសារស្រាវជ្រាវនិងរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ឯកសារស្រាវជ្រាវរបស់ស្ថាប័នអន្តរជាតិដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិ។

សារណានេះនឹងប្រើប្រាស់សូចនាករសេដ្ឋកិច្ចសំខាន់ៗជាច្រើន ដើម្បីយកមកវិភាគដូចជា អនុបាតដុល្លារូបនីយកម្ម (ប្រាក់បញ្ញើជារូបិយប័ណ្ណ/រូបិយវត្ថុទូទៅ) អនុបាតដុល្លារូបនីយកម្មហិរញ្ញវត្ថុ (ប្រាក់បញ្ញើជារូបិយប័ណ្ណ/ប្រាក់បញ្ញើសរុប) អត្រាអតិផរណា អត្រាប្តូរប្រាក់ អត្រាការប្រាក់ និងសូចនាករដទៃទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានសរសេរចែកចេញជា៣ជំពូក ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

- **សេចក្តីផ្តើម៖** លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ទំហំនិងដែនកំណត់ និងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ។
- **ជំពូកទី១៖** រំឭកអំពីទ្រឹស្តីមេរៀនពាក់ព័ន្ធនឹងរូបិយវត្ថុដែលនឹងបកស្រាយពន្យល់លម្អិតអំពីសញ្ញាណនៃរូបិយវត្ថុ ចរិកលក្ខណៈរបស់រូបិយវត្ថុ មុខងារនៃរូបិយវត្ថុ ការវិវឌ្ឍនៃរូបិយវត្ថុ បរិមាណផ្គត់ផ្គង់រូបិយវត្ថុ រង្វាស់នៃបរិមាណផ្គត់ផ្គង់រូបិយវត្ថុ តម្រូវការរូបិយវត្ថុ និងកត្តាដែលជំរុញឱ្យមានតម្រូវការរូបិយវត្ថុ ព្រមទាំងផ្តល់និយមន័យដុល្លារូបនីយកម្ម កំណត់ប្រភេទនៃដុល្លារូបនីយកម្ម និងឥទ្ធិពលនៃដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ច។
- **ជំពូកទី២៖** រៀបរាប់ពីទិដ្ឋភាពទូទៅនៃធនាគារជាតិនៃកម្ពុជា ស្លាកសញ្ញា Logo របស់ធនាគារជាតិនៃកម្ពុជា ប្រវត្តិនៃធនាគារជាតិនៃកម្ពុជា បេសកកម្មចម្បង តួនាទីនិងមុខងារភារកិច្ច ព្រមទាំងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។
- **ជំពូកទី៣៖** បកស្រាយពីការកកើតឡើងនៃដុល្លារូបនីយកម្មនៅកម្ពុជា មូលហេតុដែលជំរុញឱ្យមានការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅកម្ពុជា ស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជាក្នុងពេលបច្ចុប្បន្ន និងការសិក្សាទៅលើគុណសម្បត្តិ និងគុណវិបត្តិរបស់ដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ចកម្ពុជា។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** សរុបខ្លឹមសាររួមនៃសារណា ធ្វើសេចក្តីសន្និដ្ឋានទៅលើការសិក្សាស្រាវជ្រាវ និងផ្តល់ជាអនុសាសន៍សំខាន់ៗសម្រាប់ជាការអភិវឌ្ឍនាពេលអនាគត។

# គម្រោងនៃការស្រាវជ្រាវ



# ជំពូកទី១

# រំឭកទ្រឹស្តី

# ជំពូកទី១
# រំឭកទ្រឹស្តី

## ១.១. អ្វីទៅជារូបិយវត្ថុ?

រូបិយវត្ថុត្រូវបានឱ្យនិយមន័យថាជាវត្ថុទាំងឡាយណាទាំងលក្ខណៈរូបិយឬអរូបិយ ដែលត្រូវបានគេទទួលយកជាទូទៅក្នុងការទូទាត់ទំនិញនិងសេវា ឬក្នុងការសងត្រឡប់មកវិញនូវបំណុល។[1]

យោងតាមវចនានុក្រមរបស់សម្តេចសង្ឃ ជួន ណាត រូបិយវត្ថុ គឺមកពីពាក្យ រូបិយៈ ដែលមានន័យថា ប្រាក់ មាស ឬលោហៈ មានរូបសណ្ឋានផ្សេងៗជាគ្រឿងសម្រាប់ចាយនៅក្នុងប្រទេស ឬជាវត្ថុដទៃក្រៅពីមាស ប្រាក់ និងលោហៈដែលរដ្ឋាភិបាលក្នុងប្រទេសនោះបញ្ញត្តឱ្យប្រើប្រាស់សម្រាប់ចាយជំនួស ដូចយ៉ាងធនបត្រដែលត្រូវបានប្រើប្រាស់សព្វថ្ងៃ។

ជាទូទៅ រូបិយវត្ថុត្រូវមានចរិតលក្ខណៈពិសេស៧គឺ៖

- **ត្រូវបានគេទទួលយកជាទូទៅ (Generally Accepted)**៖ រូបិយវត្ថុត្រូវតែជាវត្ថុទាំងឡាយណាដែលគ្រប់ៗគ្នាព្រមទទួលយកជាទូទៅក្នុងការទូទាត់ទំនិញនិងសេវាកម្ម។
- **ធន់ (Durable)**៖ ដើម្បីអាចប្រើប្រាស់ក្នុងការទូទាត់ដោយមានប្រសិទ្ធភាព រូបិយវត្ថុដាច់ខាតត្រូវមានភាពធន់ ពោលគឺអាចប្រើប្រាស់បានយូរ និងមិនឆាប់ខូចទ្រង់ទ្រាយ ដែលធ្វើឱ្យបាត់បង់តម្លៃរបស់វា។
- **មិនអាចងាយស្រួលផលិតបានដោយមនុស្ស (Not Easily Reproduced by People)**៖ រូបិយវត្ថុដាច់ខាតមិនអាចជាវត្ថុដែលមនុស្សអាចក្លែងបន្លំ ឬផលិតបានដោយងាយស្រួលនោះទេពីព្រោះប្រសិនបើរូបិយវត្ថុអាចត្រូវបានផលិតយ៉ាងងាយស្រួល នោះបរិមាណផ្គត់ផ្គង់រូបិយវត្ថុនៅលើទីផ្សារនឹងកើនឡើងច្រើនជាងបរិមាណផ្គត់ផ្គង់ទំនិញនិងសេវាកម្ម ដែលអាចនាំឱ្យតម្លៃទំនិញនិងសេវាទាំងនោះឡើងថ្លៃជាបន្តបន្ទាប់រហូតដល់កម្រិតមិនអាចគ្រប់គ្រងបាន។
- **ជាវត្ថុដែលកម្រធៀបនឹងវត្ថុដទៃទៀត តែមិនអាចជាវត្ថុដែលកម្រជ្រល់ហួសហេតុនោះទេ (Relatively Scarce But Not Too Scarce)**៖ រូបិយវត្ថុត្រូវមានចរិតលក្ខណៈជាវត្ថុដែលកម្ររកបាន។ ឧទាហរណ៍៖ ប្រាក់ មាស ជាដើម។ ប៉ុន្តែរូបិយវត្ថុមិនអាចជាវត្ថុដែលមិនងាយរកបានទាល់តែសោះនោះទេ ព្រោះវាត្រូវមានចំនួនគ្រប់គ្រាន់ដើម្បីបម្រើដល់តម្រូវការរបស់មនុស្សក្នុងការទូទាត់ថ្លៃទំនិញនិងសេវាកម្ម។

---

[1] Frederic S. Mishkin, (២០១០), *The Economy of Money, Banking and Financial Markets, 9th Edition*, ទំព័រ៥៣

- **អាចដឹកជញ្ជូន ឬកាន់បានដោយងាយស្រួល** (Easily Transported)៖ រូបិយវត្ថុត្រូវតែមានលក្ខណៈងាយស្រួលកាន់ និងអាចយកតាមខ្លួនបាននៅពេលធ្វើដំណើរ។
- **ជាវត្ថុដែលអាចបែងចែកតម្លៃរបស់វាបាន** (Divisible)៖ ក្នុងពេលទូទាត់ រូបិយវត្ថុត្រូវមានលក្ខណៈអាចគណនានិងបែងចែកតម្លៃរបស់វាជាបរិមាណតូចៗបាន។
- **សន្ទនីយភាព** (Liquid)៖ រូបិយវត្ថុអាចត្រូវបានប្រើប្រាស់ក្នុងការទូទាត់ទំនិញនិងសេវាបានភ្លាមៗដោយមិនចាំបាច់បំប្លែងពីវត្ថុមួយទៅវត្ថុមួយ ពោលគឺបម្រើដល់តម្រូវការមនុស្សបានទាន់ពេលវេលា។[2]

## ១.២. មុខងារនៃរូបិយវត្ថុ

រូបិយវត្ថុមានមុខងារបួនសំខាន់ៗ គឺ៖ ១/-មធ្យោបាយដោះដូរ ២/- ខ្នាតវាស់តម្លៃ ៣/- មុខងាររក្សាតម្លៃ និង ៤/- ស្តង់ដារសម្រាប់ការសងបំណុល។

### ១.២.១. មធ្យោបាយដោះដូរ (Medium of Exchange)៖

នៅរាល់ប្រតិបត្តិការទីផ្សារទាំងអស់នៅក្នុងសេដ្ឋកិច្ច រូបិយវត្ថុត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការដោះដូរ ពោលគឺវាត្រូវបានប្រើប្រាស់ដើម្បីទូទាត់ទំនិញនិងសេវាកម្ម។ ការប្រើប្រាស់រូបិយវត្ថុជាមធ្យោបាយដោះដូរបានបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច (Economic Efficiency) តាមរយៈការកាត់បន្ថយពេលវេលាក្នុងការដោះដូរទំនិញនិងសេវាកម្ម។

ឧទាហរណ៍ កញ្ញា ក ជាគ្រូបង្រៀនគណិតវិទ្យា ហើយនៅក្នុងសេដ្ឋកិច្ចដោះដូរទំនិញនឹងទំនិញ ដើម្បីចិញ្ចឹមជីវិត កញ្ញា ក មិនត្រឹមតែត្រូវស្វែងរកកសិករដែលអាចផលិតអាហារដែលនាងពេញចិត្តនោះទេ កសិករនោះថែមទាំងត្រូវការរៀនគណិតវិទ្យាទៀតផង ដើម្បីឱ្យប្រតិបត្តិការដោះដូរសេវាកម្មបង្រៀនជាមួយនឹងអាហារអាចប្រព្រឹត្តទៅបាន។ ពិតណាស់ ការស្វែងរកការដោះដូរបែបនេះចំណាយពេលច្រើននិងមានការលំបាកខ្លាំង។ ពេលវេលាដែលត្រូវបានចំណាយទៅលើដំណើរការដោះដូរទំនិញនិងសេវា ត្រូវបានគេហៅថាជាថ្លៃដើមប្រតិបត្តិការ (Transaction Cost)។ ក្នុងប្រព័ន្ធដោះដូរទំនិញនឹងទំនិញ ថ្លៃដើមប្រតិបត្តិការមានកម្រិតខ្ពស់ដោយសារតែមនុស្សត្រូវបំពេញតម្រូវការភាគីដោះដូរទាំងសងខាងទើបប្រតិបត្តិការដោះដូរអាចធ្វើទៅបាន។ នៅក្នុងឧទាហរណ៍ខាងលើដដែលប្រសិនបើ កញ្ញា ក អាចប្រើប្រាស់រូបិយវត្ថុជាមធ្យោបាយដោះដូរបាន នាងនឹងអាចទទួលបានរូបិយវត្ថុ

[2] *Money: Its Functions and Characteristics*, Toronto: Canadian Foundation for Economic Education, ១៩៩៩

ពីការបង្រៀនគណិតវិទ្យា និងអាចប្រើប្រាស់រូបិយវត្ថុនោះទៅទិញអាហារដែលនាងត្រូវការដោយមិនចាំបាច់ស្វែងរកកសិករដែលត្រូវការការបង្រៀនគណិតវិទ្យារបស់នាងនោះទេ។

ដូចដែលបានបង្ហាញក្នុងឧទាហរណ៍ខាងលើ រូបិយវត្ថុបានលើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ចដោយកាត់បន្ថយថ្លៃដើមប្រតិបត្តិការ និងអនុញ្ញាតឱ្យមនុស្សអាចធ្វើឯកទេសកម្ម (Specialize) លើការងារដែលខ្លួនអាចធ្វើបានល្អប្រសើរជាងគេ។ ដូច្នេះ រូបិយវត្ថុជាប្រេងរំអិលសម្រួលដល់សកម្មភាពសេដ្ឋកិច្ចដោយកាត់បន្ថយថ្លៃប្រតិបត្តិការ ដែលនាំឱ្យមានការធ្វើឯកទេសកម្ម និងការបែងចែកកម្លាំងពលកម្ម សំដៅជំរុញប្រសិទ្ធភាពសេដ្ឋកិច្ច។[3]

### ១.២.២. ខ្នាតវាស់តម្លៃ (Unit of Account)៖

មុខងារទី២នៃរូបិយវត្ថុគឺជាខ្នាតសម្រាប់វាស់តម្លៃទំនិញនិងសេវានៅក្នុងសេដ្ឋកិច្ច។ តម្លៃនៃទំនិញនិងសេវាកម្មត្រូវបានវាស់ដោយប្រើប្រាស់រូបិយវត្ថុជាខ្នាតរង្វាស់ ដូចជាការវាស់ចម្ងាយដោយប្រើប្រាស់ខ្នាតគីឡូម៉ែត្រ ឬការវាស់ទម្ងន់ដោយប្រើប្រាស់ខ្នាតគីឡូក្រាម។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីសារៈសំខាន់នៃមុខងាររូបិយវត្ថុនេះ សូមពិនិត្យមើលឧទាហរណ៍ខាងក្រោម។

ឧទាហរណ៍៖ ប្រសិនបើនៅក្នុងសេដ្ឋកិច្ចមួយមានទំនិញនិងសេវាកម្មចំនួនបីប្រភេទគឺ ផ្លែក្រូច ការបង្រៀនគណិតវិទ្យា និងផ្លែម្នាស់ នោះដើម្បីវាស់ថ្លៃនៃទំនិញនិងសេវាកម្មនីមួយៗបាន ទំនិញនិងសេវាកម្មទាំងបីប្រភេទត្រូវបានវាស់ដោយធៀបទំនិញមួយនឹងទំនិញមួយទៀត ពោលគឺតម្លៃផ្លែក្រូចគិតជាចំនួនផ្លែម្នាស់ តម្លៃផ្លែម្នាស់គិតជាចំនួននៃការបង្រៀនគណិតវិទ្យា និងតម្លៃការបង្រៀនគណិតវិទ្យាគិតជាចំនួនផ្លែក្រូច។ ដូចនេះ ប្រសិនបើមានទំនិញ១០ប្រភេទនៅក្នុងសេដ្ឋកិច្ច នោះនឹងមានតម្លៃគិតជាទំនិញនីមួយៗចំនួន៤៥តម្លៃ។ ការគិតតម្លៃជាទំនិញខុសៗគ្នាបែបនេះបង្កការលំបាកដល់មនុស្សក្នុងការប្រៀបធៀបតម្លៃនៃទំនិញនីមួយៗ។ ដូចនេះ ការប្រើប្រាស់រូបិយវត្ថុជាខ្នាតសម្រាប់វាស់តម្លៃទំនិញគ្រប់ប្រភេទ នឹងបង្កលក្ខណៈងាយស្រួលដល់មនុស្សក្នុងការប្រៀបធៀបតម្លៃទំនិញមួយទៅទំនិញមួយទៀត ព្រមទាំងកាត់បន្ថយថ្លៃដើមប្រតិបត្តិការ ដោយរាល់ទំនិញទាំងអស់ត្រូវបានដាក់តម្លៃដោយប្រើខ្នាតតែមួយ។[4]

---

[3] Frederic S. Mishkin, (២០១០), *The Economy of Money, Banking and Financial Markets, 9th Edition*, ទំព័រ៥៤-៥៥

[4] Cecchetti & Schoenholtz, (២០១៥), *Money, Banking, and Financial Markets, 4th Edition*, ទំព័រ២៤-២៥

**១.២.៣. មុខងាររក្សាតម្លៃ** (Store of Value)៖

រូបិយវត្ថុត្រូវបានប្រើប្រាស់ ដើម្បីរក្សាអំណាចទិញពីពេលទទួលបានប្រាក់ចំណូលរហូតដល់ពេលចំណាយ។ មុខងារនេះមានសារៈសំខាន់ណាស់ ដោយមនុស្សម្នាក់ៗមិនចង់ចំណាយរាល់ប្រាក់ចំណូលដែលខ្លួនរកបានភ្លាមៗនោះទេ ដោយពួកគេចង់សន្សំទុករហូតដល់ពេលណាដែលគេមានបំណងចង់ចំណាយដើម្បីទិញទំនិញ ឬសេវាកម្មដែលគេត្រូវការ។ ដូចនេះ ប្រជាជនដែលទទួលបានប្រាក់ចំណូលប្រចាំខែ ឬប្រចាំឆ្នាំក្តី អាចមានលទ្ធភាពដើម្បីបែងចែកការចំណាយរបស់ខ្លួនពីមួយថ្ងៃទៅមួយថ្ងៃ។ មិនតែប៉ុណ្ណោះ ពួកគេក៏អាចរក្សានិងបង្គរ (Accumulate) រូបិយវត្ថុទុកសម្រាប់ការចំណាយនាពេលអនាគត ដូចជា សម្រាប់ពេលចូលនិវត្តន៍ សម្រាប់ការអប់រំកូនៗ និងសម្រាប់ការប្រកបរបរអាជីវកម្មជាដើម។ ម្យ៉ាងទៀត រូបិយវត្ថុមិនងាយបាត់បង់តម្លៃដូចការរក្សាទំនិញនោះទេ ដោយទំនិញអាចខូចខាតនៅពេលទុកវាកាន់តែយូរ ហើយរូបិយវត្ថុក៏មានលក្ខណៈសន្ទនីយភាពដែលអាចអនុញ្ញាតឱ្យមនុស្សចាយវាយបានគ្រប់ពេលវេលាដើម្បីបំពេញសេចក្តីត្រូវការរបស់ពួកគេ។[5]

**១.២.៤. ស្តង់ដារសម្រាប់ការសងបំណុល** (Standard of Deferred Payment)៖

រូបិយវត្ថុបានអនុញ្ញាតឱ្យមនុស្សអាចផ្តល់កម្ចីដល់គ្នាទៅវិញទៅមក និងអាចឱ្យបំណុលនោះបង្គរជាការប្រាក់រហូតដល់ពេលដែលកូនបំណុលអាចមានលទ្ធភាពសងម្ចាស់បំណុលវិញ។ ប្រសិនបើគ្មានរូបិយវត្ថុដើរតួនាទីជាស្តង់ដារសម្រាប់ការទូទាត់បំណុលនោះទេ នោះមនុស្សនឹងមានការលំបាកក្នុងការឱ្យអ្នកដទៃខ្ចី។ រូបិយវត្ថុអាចបង្កលក្ខណៈងាយស្រួលដល់មនុស្សក្នុងការគណនាបំណុល និងអាចឱ្យមនុស្សប្រើប្រាស់រូបិយវត្ថុដែលខ្ចីបានទៅប្រើប្រាស់ជាដើមទុនក្នុងការប្រកបរបរអាជីវកម្ម ឬសម្រាប់ទិញទំនិញនិងសេវាផ្សេងៗដើម្បីប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេផងដែរ។

## ១.៣. ការវិវឌ្ឍនៃរូបិយវត្ថុ៖ ពីប្រព័ន្ធដោះដូរទំនិញនឹងទំនិញ (Barter) រហូតដល់ប្រព័ន្ធរូបិយវត្ថុមិនមែនក្រដាសប្រាក់ (Cashless System)

### ១.៣.១. ប្រព័ន្ធដោះដូរទំនិញនឹងទំនិញ

ការដោះដូរ គឺជាសកម្មភាពចម្បងមួយក្នុងសេដ្ឋកិច្ច ដែលអាចអនុញ្ញាតឱ្យមនុស្សបំពេញសេចក្តីត្រូវការរបស់ខ្លួនបានដោយផ្លាស់ប្តូរអ្វីដែលគេមានជាមួយនឹងអ្វីដែលគេត្រូវការ។ ប្រព័ន្ធដោះដូរ

[5] Frederic S. Mishkin, (២០១០), *The Economy of Money, Banking and Financial Markets, 9th Edition*, ទំព័រ៥៦

ទំនិញនឹងទំនិញ គឺជាវិធីដ៏សាមញ្ញនិងងាយស្រួល ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្លាស់ប្តូរទំនិញជារូបវន្ត (Physical Exchange) ដូចជាការដោះដូរគ្នារវាងស្បែកសត្វនឹងស្បៀងអាហារ អង្ករនឹងរបស់ប្រើប្រាស់ ជាដើម។ ទោះជាយ៉ាងណា ប្រព័ន្ធដោះដូរនេះមានចំណុចខ្សោយរបស់វាត្រង់ថា នៅពេលចង់ផ្លាស់ប្តូរទំនិញគ្នាម្តងៗ បុគ្គលដែលចង់ធ្វើការដោះដូរនូវមុខទំនិញណាមួយនោះ ត្រូវតែស្វែងរកអ្នកដែលមានប្រភេទទំនិញដែលខ្លួនចង់បាន និងមានបំណងចង់ផ្លាស់ប្តូរទំនិញជាមួយខ្លួន ហើយបន្ទាប់មកគេត្រូវណាត់ជួបគ្នាដើម្បីពិភាក្សាឱ្យមានការព្រមព្រៀងគ្នាលើតម្លៃ និងពេលវេលា ដែលធ្វើឱ្យថ្លៃដើមប្រតិបត្តិការមានកម្រិតខ្ពស់ធៀបនឹងការទូទាត់ដោយប្រើប្រាស់រូបិយវត្ថុ។

### ១.៣.២. រូបិយវត្ថុទំនិញ (Commodity Money)

ដើម្បីឱ្យវត្ថុមួយអាចដើរតួនាទីជារូបិយវត្ថុបាន ទាល់តែវត្ថុនោះត្រូវបានគេទទួលយកជាទូទៅក្នុងការទូទាត់ទំនិញនិងសេវាកម្ម។ ដូចនេះ វត្ថុទាំងឡាយណាដែលមនុស្សគ្រប់រូបឱ្យតម្លៃទៅលើវា ដូចជា លោហៈមានតម្លៃ មាស ប្រាក់ និងអង្ករជាដើម សុទ្ធតែអាចត្រូវបានប្រើប្រាស់ជារូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ រូបិយវត្ថុដែលបង្កើតឡើងពីវត្ថុទាំងនោះត្រូវបានគេហៅថា រូបិយវត្ថុទំនិញ ហើយក្នុងរយៈពេលជាច្រើនសតវត្សរ៍មកហើយ រូបិយវត្ថុប្រភេទនេះត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគ្រប់សេដ្ឋកិច្ចទាំងអស់។ ប៉ុន្តែ គុណវិបត្តិនៃប្រព័ន្ធទូទាត់រូបិយវត្ថុទំនិញ គឺទម្រង់នៃរូបិយវត្ថុទំនិញភាគច្រើនជាលោហៈមានតម្លៃដែលមានទម្ងន់ធ្ងន់និងទំហំធំ ជាការពិបាកក្នុងការយកតាមខ្លួន ឬដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយ នៅពេលទូទាត់ប្រតិបត្តិការធំៗ។[6]

### ១.៣.៣. រូបិយវត្ថុក្រឹត្យ (Fiat Money)

ការវិវឌ្ឍបន្ទាប់ពីរូបិយវត្ថុទំនិញ គឺការប្រើប្រាស់ក្រដាសប្រាក់ជារូបិយវត្ថុសម្រាប់ការទូទាត់។ ជាដំបូងឡើយ ក្រដាសប្រាក់តែងធានាតម្លៃរបស់វាដោយអ្នកដែលកាន់វាអាចបំប្លែង (Convert) ក្រដាសប្រាក់ជាកាស ឬលោហៈមានតម្លៃក្នុងបរិមាណណាមួយ។ បន្ទាប់មក ក្រដាសប្រាក់ក៏បានវិវឌ្ឍទៅជារូបិយវត្ថុក្រឹត្យ ដែលត្រូវបានរដ្ឋាភិបាលអនុម័តឱ្យប្រើប្រាស់ជាមធ្យោបាយទូទាត់ស្របទៅតាមច្បាប់កំណត់ ដែលគេឱ្យឈ្មោះថាជារូបិយវត្ថុនីត្យានុកូល (Legal Tender)។ រូបិយវត្ថុនីត្យានុកូល គឺជារូបិយវត្ថុដែលត្រូវបានគេទទួលយកមកទូទាត់ជាទូទៅនៅក្នុងសេដ្ឋកិច្ចដោយយោងទៅតាមច្បាប់ កំណត់ ប៉ុន្តែរូបិយវត្ថុក្នុងទម្រង់នេះមិនអាចបំប្លែងជាកាស ឬលោហៈមានតម្លៃបានឡើយ។

[6] Cecchetti & Schoenholtz, (២០១៥), *Money, Banking, and Financial Markets, 4th Edition*, ទំព័រ២៦-២៨

រូបិយវត្ថុបែបនេះមានគុណសម្បត្តិរបស់វាត្រង់មានទំហំតូច និងមិនធ្ងន់ដូចលោហៈមានតម្លៃ ឬកាស ឡើយ។ គួរបញ្ជាក់ថា ក្រដាសប្រាក់អាចត្រូវបានប្រើប្រាស់ជារូបិយវត្ថុបាន លុះត្រាតែប្រជាពលរដ្ឋ មានជំនឿទុកចិត្តមកលើអាជ្ញាធរដែលបោះផ្សាយវា ហើយការបោះផ្សាយត្រូវបានអភិវឌ្ឍឱ្យជឿន លឿនខ្លាំងគ្រប់គ្រាន់អាចទប់ទល់នឹងការក្លែងបន្លំក្រដាសប្រាក់បាន។

### ១.៣.៤. មូលប្បទានបត្រ (Check)

ដោយប្រតិបត្តិការទូទាត់ទំនិញនិងសេវានៅក្នុងសេដ្ឋកិច្ចកាន់តែមានទំហំធំឡើងៗ មនុស្ស បានបង្កើតមធ្យោបាយទូទាត់មួយប្រភេទទៀត ដើម្បីដោះស្រាយដល់បញ្ហានៃការដឹកជញ្ជូនរូបិយវត្ថុ និងបង្កើនសុវត្ថិភាពនៃការកាន់រូបិយវត្ថុ ជៀសវាងមានការធ្លាក់បួន់ ឬបាត់បង់ជាយថាហេតុ។ មធ្យោបាយ ទូទាត់នោះ គឺមូលប្បទានបត្រ។ មូលប្បទានបត្រ ជាបញ្ជាផ្ទេរប្រាក់ទៅកាន់ធនាគារឱ្យផ្ទេរប្រាក់ ដែលមានក្នុងគណនីរបស់អ្នកទូទាត់ (Payer) ទៅឱ្យអ្នកទទួលការទូទាត់ (Payee)។ មូលប្បទានបត្រ បានសម្រួលដល់ការទូទាត់ ដោយមិនចាំបាច់ឱ្យអ្នកទូទាត់កាន់សាច់ប្រាក់ជាច្រើនតាមខ្លួននោះទេ។ ដូចនេះ ការប្រើប្រាស់មូលប្បទានបត្របានបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធទូទាត់នៅក្នុងសេដ្ឋកិច្ច ដោយ មូលប្បទានបត្រអាចជួយកាត់បន្ថយចំណាយទៅលើថ្លៃដឹកជញ្ជូន អាចទូទាត់ក្នុងបរិមាណធំទៅតាម សមតុល្យដែលមានក្នុងគណនី និងផ្តល់សុវត្ថិភាពដល់អ្នកប្រើប្រាស់ក្នុងករណីចោរលួច ឬបាត់បង់។

ទោះជាយ៉ាងណា មូលប្បទានបត្រក៏មានចំណុចខ្សោយចំនួនពីរផងដែរ គឺ ១/- ការទូទាត់ ដោយប្រើប្រាស់មូលប្បទានបត្រទាមទារនូវពេលវេលាដើម្បីបំពេញដំណើរការទូទាត់ ដែលជាបញ្ហា សម្រាប់អ្នកដែលត្រូវការសាច់ប្រាក់ប្រើប្រាស់ភ្លាមៗក្រោយពេលទូទាត់ និង ២/- ដំណើរការផាត់ទាត់ មូលប្បទានបត្រ (Check Clearance) ត្រូវចំណាយថ្លៃប្រតិបត្តិការខ្ពស់ ដូចជានៅសហរដ្ឋអាមេរិក ដំណើរការ ផាត់ទាត់មូលប្បទានបត្រត្រូវបានប៉ាន់ស្មានថាចំណាយថ្លៃប្រតិបត្តិការអស់ ១០ប៊ីលាន ដុល្លារអាមេរិកក្នុងមួយឆ្នាំ។[7]

### ១.៣.៥. ប្រព័ន្ធទូទាត់អេឡិចត្រូនិក (Electronic Payment)

ការជឿនលឿននៃប្រព័ន្ធកុំព្យូទ័រ និងភាពទូលំទូលាយនៃប្រព័ន្ធអ៊ីនធឺណេត បានអនុញ្ញាតឱ្យ ការទូទាត់ថ្លៃទំនិញនិងសេវាកម្មតាមបែបអេឡិចត្រូនិកមានតម្លៃទាប។ ហេតុដូចនេះ ធនាគារនាពេល បច្ចុប្បន្នបានដំឡើងគេហទំព័រសម្រាប់ឱ្យអតិថិជនរបស់ពួកគេអាចទូទាត់ទំនិញ និងសេវាបានភ្លាមៗ

[7] Cecchetti & Schoenholtz, (២០១៥), *Money, Banking, and Financial Markets, 4th Edition*, ទំព័រ២៨-៣១

តាមប្រព័ន្ធអ៊ីនធឺណេត ដោយចំណាយពេលតិច និងមិនចាំបាច់ធ្វើដំណើរ ហើយចំណាយទៅលើថ្លៃប្រតិបត្តិការក៏មានកម្រិតទាបជាងដំណើរការទូទាត់មូលប្បទានបត្រផងដែរ។ លើសពីនេះទៅទៀត ការទូទាត់ក៏អាចធ្វើឡើងដោយស្វ័យប្រវត្តិជារៀងរាល់ថ្ងៃ ខែ ឬឆ្នាំ ទៅតាមតម្រូវការរបស់អតិថិជននីមួយៗ ដែលនេះមិនត្រឹមតែសន្សំសំចៃពេលវេលា និងសម្រួលដល់ការទូទាត់ វាថែមទាំងជួយការពារអតិថិជនពីការខកខានបង់ប្រាក់ដែលអាចឱ្យពួកគាត់ទទួលពិន័យ។

### ១.៣.៦. រូបិយវត្ថុអេឡិចត្រូនិក (E-Money)

ដោយការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកទទួលបានប្រជាប្រិយភាពគួរឱ្យកត់សម្គាល់ រូបិយវត្ថុក៏ចាប់ផ្តើមបាត់រូបរាងបន្តិចម្តងៗរហូតដល់មានទម្រង់ជាអរូបិយ និងត្រូវបានប្រើប្រាស់តាមរយៈប្រព័ន្ធអេឡិចត្រូនិក ដែលគេហៅថា រូបិយវត្ថុអេឡិចត្រូនិក។ ទម្រង់ដំបូងនៃរូបិយវត្ថុអេឡិចត្រូនិកគឺប័ណ្ណឥណពន្ធ (Debit card)។ ប័ណ្ណឥណពន្ធអនុញ្ញាតឱ្យអតិថិជនធនាគារអាចទូទាត់ទំនិញនិងសេវាកម្ម តាមរយៈការផ្ទេរមូលនិធិដោយផ្ទាល់ពីគណនីរបស់ពួកគេទៅកាន់គណនីរបស់អ្នកលក់ទំនិញ និងសេវាកម្ម។ ឧទាហរណ៍ នៅតាមផ្សារទំនើបមួយចំនួននាពេលបច្ចុប្បន្ន គេសង្កេតឃើញមានម៉ាស៊ីនឆូតប័ណ្ណនៅកន្លែងគិតលុយ (Electronic Funds Transfer at Point of Sale –EFTPOS) ដែលអាចឱ្យអតិថិជនឆូតប័ណ្ណឥណពន្ធដើម្បីទូទាត់ថ្លៃទំនិញដែលបានទិញ។

បន្ទាប់មក រូបិយវត្ថុអេឡិចត្រូនិកក៏បានអភិវឌ្ឍក្លាយទៅជាទម្រង់មួយប្រភេទទៀតគឺប័ណ្ណវៃឆ្លាត (Smart Card) ដែលមានបន្ទះឈីប (Chip) អាចផ្ទុកព័ត៌មានរបស់គណនីអតិថិជនបាន។ ប័ណ្ណនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដោយមិនចាំបាច់មានទំនាក់ទំនងជាមួយធនាគារឡើយ។ ឧទាហរណ៍ ស្ថានីយ៍ប្រេងឥន្ធនៈអាចបោះផ្សាយប័ណ្ណវៃឆ្លាតឱ្យអតិថិជនរបស់ពួកគេសម្រាប់ទូទាត់នៅពេលចាក់សាំង ហើយអតិថិជនអាចបង់ប្រាក់ជាមុន ឬបង់ប្រាក់នៅកាលកំណត់ណាមួយក្រោយពេលប្រើប្រាស់ប័ណ្ណនោះសម្រាប់ទូទាត់។

ទម្រង់បន្ទាប់នៃរូបិយវត្ថុអេឡិចត្រូនិក គឺសាច់ប្រាក់អេឡិចត្រូនិក (E-Cash) ដែលត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធអ៊ីនធឺណេតសម្រាប់ការទិញទំនិញនិងសេវាកម្មអនឡាញ (Online)។ ដើម្បីចាប់ផ្តើមប្រតិបត្តិការនេះបាន អ្នកប្រើប្រាស់ត្រូវបើកគណនីនៅធនាគារដែលអាចភ្ជាប់មកប្រព័ន្ធអ៊ីនធឺណេតបាន ហើយត្រូវផ្ទេរទឹកប្រាក់ចូលទៅក្នុងកុំព្យូទ័ររបស់ខ្លួន។ នៅពេលដែលអតិថិជនចង់ទិញអ្វីមួយដោយប្រើប្រាស់សាច់ប្រាក់អេឡិចត្រូនិក ពួកគេគ្រាន់តែចូលទៅកាន់គេហទំព័រនៃ

ហាងលក់ទំនិញ និងដាក់បញ្ជាទិញទំនិញតែម្តង ហើយសាច់ប្រាក់អេឡិចត្រូនិកនឹងត្រូវបានផ្ទេរជាស្វ័យប្រវត្តិចូលទៅក្នុងគណនីរបស់ឈ្មួញដែលជាអ្នកលក់។[8]

## ១.៤. បរិមាណផ្គត់ផ្គង់រូបិយវត្ថុ (Money Supply)

បរិមាណផ្គត់ផ្គង់រូបិយវត្ថុ គឺជាបរិមាណសរុបនៃរូបិយវត្ថុដែលមាននៅក្នុងសេដ្ឋកិច្ចក្នុងរយៈពេលកំណត់ណាមួយ។ បរិមាណផ្គត់ផ្គង់រូបិយវត្ថុត្រូវបានគេវាស់ទៅតាមការកំណត់និយមន័យនៃរូបិយវត្ថុ ដែលមានដូចខាងក្រោម៖

- $M_1$ = រូបិយវត្ថុនៅក្នុងចរាចរណ៍ (Currency in Circulation) + មូលប្បទានបត្រធ្វើដំណើរ (Traveler's Checks) + ប្រាក់បញ្ញើតាមតម្រូវការ (Demand Deposits) + ប្រាក់បញ្ញើសម្រាប់ប្រើប្រាស់មូលប្បទានបត្រផ្សេងៗទៀត (Other Checkable Deposits)។
- $M_2 = M_1$ + ប្រាក់បញ្ញើមានកាលកំណត់ដែលមានតម្លៃចារឹកតូច (Small-denomination Time Deposits) + ប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើទីផ្សាររូបិយវត្ថុ (Savings Deposits and Money Market Deposit Accounts) + កិច្ចសន្យាទិញត្រឡប់មកវិញរយៈពេលមួយយប់ (Overnight Repurchase Agreements) + ភាគហ៊ុនមូលនិធិសង្គហៈនៅក្នុងទីផ្សាររូបិយវត្ថុដែលមានលក្ខណៈមិនមែនស្ថាប័ន (Non-institutional Money Market Mutual Fund Shares)។
- $M_3 = M_2$ + ប្រាក់បញ្ញើមានកាលកំណត់ដែលមានតម្លៃចារឹកធំ (Large-denomination Time Deposits) + ភាគហ៊ុនមូលនិធិសង្គហធននៅក្នុងទីផ្សាររូបិយវត្ថុដែលមានលក្ខណៈស្ថាប័ន (Institutional Money Market Mutual Fund Shares) + កិច្ចសន្យាទិញត្រឡប់មកវិញមានកាលកំណត់ (Term Repurchase Agreements) + ប្រាក់បញ្ញើអឺរ៉ូ-ដុល្លារ (Eurodollars)។
- $L = M_3$ + ទ្រព្យសកម្មផ្សេងៗទៀតដែលមានលក្ខណៈសន្ទនីយភាព (Other Liquid Assets) ដូចជា ប័ណ្ណរតនាគារ (Treasury Bills) សញ្ញាប័ណ្ណសន្សំអាមេរិក (U.S. Savings Bonds) កិច្ចសន្យាធានារបស់ធនាគារ (Bankers' Acceptances) ប្រាក់បញ្ញើអឺរ៉ូ-ដុល្លារមានកាលកំណត់ (Term Eurodollars) និងផលបត្រពាណិជ្ជកម្ម (Commercial Papers) ជាដើម។[9]

---

[8] Frederic S. Mishkin, (២០១០), *The Economy of Money, Banking and Financial Markets, 9th Edition*, ទំព័រ៥៨-៥៩

[9] Bradley R. Schiller, (២០០៨), *The Economy Today, 11th Edition,* ទំព័រ២៥៥-២៥៨

## ១.៥. តម្រូវការរូបិយវត្ថុ (Money Demand)

នៅក្នុងសេដ្ឋកិច្ច តម្រូវការរូបិយវត្ថុ គឺជាបរិមាណរូបិយវត្ថុសរុបដែលប្រជាជនជ្រើសរើសកាន់នៅក្នុងដៃ ឬនៅក្នុងគណនីតាមតម្រូវការ (Demand Account) ជាជាងរក្សាទុកសន្សំ ឬវិនិយោគទៅលើឧបករណ៍ហិរញ្ញវត្ថុ ដូចជា ប័ណ្ណរតនាគារ ប័ណ្ណភាគហ៊ុន សញ្ញាប័ណ្ណរដ្ឋាភិបាល ជាដើម។

### ១.៥.១. មូលហេតុនៃការកាន់រូបិយវត្ថុ (Motives for Holding Money)

លោក John Maynard Keynes សេដ្ឋវិទូសញ្ជាតិអង់គ្លេស បានពន្យល់ថា មនុស្សជ្រើសរើសកាន់រូបិយវត្ថុជាជាងកាន់ទ្រព្យសកម្មដទៃទៀត ដោយសារមូលហេតុចំនួនបី។[10]

- **ដើម្បីធ្វើប្រតិបត្តិការ (Transaction Motive)៖** ជារៀងរាល់ថ្ងៃ មនុស្សម្នាក់ៗធ្វើប្រតិបត្តិការដោះដូរទំនិញនិងសេវាកម្មមិនឈប់ឈរ សំដៅបំពេញតម្រូវការជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ដូច្នេះ ដើម្បីដំណើរការប្រតិបត្តិការដោះដូរទាំងនោះ មនុស្សត្រូវការរូបិយវត្ថុកាន់នៅក្នុងដៃសម្រាប់សម្រួលដល់ការរស់នៅរបស់ពួកគេ។ ឧទាហរណ៍ បុគ្គលគ្រប់រូបត្រូវការរូបិយវត្ថុដើម្បីទិញចំណីអាហារ បង់ថ្លៃសេវាសាធារណៈផ្សេងៗ ឬចំណាយទៅលើទំនិញប្រើប្រាស់ រីឯសហគ្រាស និងក្រុមហ៊ុនវិញ ក៏ដូចគ្នាផងដែរ នីតិបុគ្គលទាំងនេះត្រូវការសាច់ប្រាក់គ្រប់គ្រាន់សម្រាប់បង្វិលឱ្យអ្នកផ្គត់ផ្គង់ បង់ថ្លៃចំណាយប្រចាំថ្ងៃ និងផ្តល់ប្រាក់បៀវត្សឱ្យបុគ្គលិក។
- **ដើម្បីបង្ការទុកមុន (Precautionary Motive)៖** មូលហេតុមួយទៀតដែលមនុស្សជ្រើសរើសកាន់រូបិយវត្ថុ គឺដើម្បីបំពេញនូវតម្រូវការដែលមិនបានព្រាងទុក និងការពារទុកមុនចំពោះហេតុការណ៍កើតឡើងជាយថាហេតុដែលទាមទារឱ្យមានការចំណាយភ្លាមៗ។ ក្នុងបរិការណ៍នេះ អ្នកកាន់រូបិយវត្ថុមិនរំពឹងថាត្រូវចំណាយរូបិយវត្ថុដែលពួកគេកាន់នោះទេ ប៉ុន្តែពួកគេចង់ត្រៀមរូបិយវត្ថុទុកសម្រាប់ដោះស្រាយនៅពេលមានភាពអាសន្នកើតឡើង។
- **ដើម្បីការធ្វើព្រឹទ្ធិកម្ម (Speculative Motive)៖** ការធ្វើព្រឹទ្ធិកម្ម គឺជាការពិចារណាទៅលើថ្លៃឱកាសនៃការកាន់រូបិយវត្ថុធៀបនឹងការវិនិយោគលើឧបករណ៍ហិរញ្ញវត្ថុផ្សេងៗ ដូចជាមូលបត្រកម្មសិទ្ធិ សញ្ញាប័ណ្ណ ជាដើម។ អ្នកកាន់រូបិយវត្ថុដើម្បីធ្វើព្រឹទ្ធិកម្មតែងរង់ចាំឱកាសវិនិយោគទៅលើឧបករណ៍ហិរញ្ញវត្ថុ ដោយពួកគេតែងតែវាយតម្លៃទៅលើស្ថានភាពទីផ្សារ ហើយប្រសិនបើពួកគេរំពឹងថាអត្រាការប្រាក់នៅលើទីផ្សារនឹងកើនឡើង នោះពួកគេនឹងយករូបិយវត្ថុ

[10] Stephen L. Slavin, (២០០៨), *Economics*, ទំព័រ៣០៦-៣០៩

ដែលគេកាន់ទៅវិនិយោគលើទ្រព្យសកម្មទាំងនោះ ដើម្បីយកចំណេញលើការប្រាក់ដែលត្រូវបានរំពឹងថានឹងទទួលបាន។

### ១.៥.២. កត្តាដែលជះឥទ្ធិពលដល់តម្រូវការរូបិយវត្ថុ

កត្តាដែលជះឥទ្ធិពលដល់តម្រូវការរូបិយវត្ថុមានបួន គឺ កម្រិតថ្លៃ ចំណូល អត្រាការប្រាក់ និងលទ្ធភាពនៃការទទួលបានឥណទាន។ ការប្រែប្រួលទៅលើកត្តាទាំងបួននេះអាចផ្លាស់ប្តូរឥរិយាបថមនុស្សក្នុងការកាន់រូបិយវត្ថុ។

- **កម្រិតថ្លៃ៖** នៅពេលដែលថ្លៃនៃទំនិញនិងសេវាកើនឡើង មនុស្សនឹងត្រូវការរូបិយវត្ថុបន្ថែមដើម្បីបំពេញប្រតិបត្តិការទូទាត់ប្រចាំថ្ងៃរបស់ពួកគេ។ ឧទាហរណ៍ អង្ករមានតម្លៃ៥.០០០រៀលក្នុងមួយគីឡូក្រាម ពីរខែក្រោយមកស្រាប់តែតម្លៃអង្ករបានកើនឡើង២០០រៀល ដល់ ៥.២០០រៀលក្នុងមួយគីឡូក្រាម ដែលទាមទារឱ្យមានការកាន់រូបិយវត្ថុច្រើនជាងមុនដើម្បីយកទៅទិញអង្ករនេះ។ ទោះជាយ៉ាងណា ការកាន់រូបិយវត្ថុច្រើនជាងតម្រូវការអាចធ្វើឱ្យមនុស្សទទួលរងនូវការខាតបង់ ដោយសារតែការបន្តឡើងថ្លៃនៃទំនិញនិងសេវាជារៀងរាល់ឆ្នាំ ពោលគឺអំណាចទិញរបស់រូបិយវត្ថុចាប់ផ្តើមថយចុះបន្តិចម្តងៗ នៅពេលដែលមនុស្សកាន់វាកាន់តែយូរ។ ដូចនេះ ការឡើងថ្លៃនៃទំនិញនិងសេវា ឬអតិផរណាអាចធ្វើឱ្យមនុស្សកាន់រូបិយវត្ថុច្រើនជាងមុន ប៉ុន្តែក្នុងកម្រិតមួយសមស្របនឹងតម្រូវការពួកគេ ដើម្បីកាត់បន្ថយការខាតបង់ពីការថយចុះនៃអំណាចទិញរបស់រូបិយវត្ថុ។
- **កម្រិតចំណូល៖** ចំណូលរបស់មនុស្សកាន់តែច្រើន នោះចំណាយក៏កាន់តែច្រើនផងដែរ ដែលនាំឱ្យបរិមាណរូបិយវត្ថុដែលពួកគេត្រូវការសម្រាប់ទូទាត់កើនឡើង។ ផ្ទុយមកវិញ នៅពេលដែលមានចំណូលទាប នោះមនុស្សនឹងរក្សាទុករូបិយវត្ថុសម្រាប់ការដាក់សន្សំជាជាងការចំណាយទៅលើទំនិញនិងសេវាដែលគេត្រូវការ ដែលធ្វើឱ្យតម្រូវការរូបិយវត្ថុថយចុះ។
- **អត្រាការប្រាក់៖** នៅក្នុងសេដ្ឋកិច្ចដែលមានប្រព័ន្ធហិរញ្ញវត្ថុរីកចម្រើន ការកាន់រូបិយវត្ថុបានបាត់បង់ប្រជាប្រិយភាព ដោយសារការកាន់រូបិយវត្ថុក្នុងដៃមិនបានផ្តល់ជាធនលាភឬការប្រាក់ដល់អ្នកដែលកាន់វានោះទេ។ ដើម្បីទទួលបានប្រាក់ចំណេញ មនុស្សចាប់ផ្តើមងាកមកវិនិយោគមូលធនរបស់ពួកគេទៅលើមូលបត្រដែលអាចផ្តល់ឱ្យពួកគេនូវធនលាភឬការប្រាក់ ជាពិសេសនៅពេលអត្រាការប្រាក់ទីផ្សារកើនឡើង។ ដូចនេះ អត្រាការប្រាក់មានទំនាក់ទំនងអវិជ្ជមានជាមួយនឹងតម្រូវការរូបិយវត្ថុ ដោយមនុស្សរមែងកាន់រូបិយវត្ថុតិចជាងមុននៅពេលដែលអត្រា

ការប្រាក់កើនឡើង ហើយនៅពេលអត្រាការប្រាក់ថយចុះវិញ ពួកគេនឹងបន្តកាន់រូបិយវត្ថុ ពីព្រោះថ្លៃឱកាសនៃការកាន់រូបិយវត្ថុធៀបនឹងការវិនិយោគលើមូលបត្រមានកម្រិតទាប។

- **លទ្ធភាពនៃការទទួលបានឥណទាន៖** នៅពេលមនុស្សអាចទទួលបានឥណទានបានកាន់តែងាយស្រួល នោះពួកគេមិនចាំបាច់កាន់រូបិយវត្ថុឡើយ។ បច្ចុប្បន្ន ការប្រើប្រាស់ប័ណ្ណឥណទានបានសម្រួលដល់ប្រតិបត្តិការទូទាត់ទំនិញនិងសេវា តាមរយៈការទិញជឿទំនិញនិងសេវាដោយមិនចាំបាច់មានរូបិយវត្ថុក្នុងដៃ។ ឧទាហរណ៍ បុគ្គលិកធ្វើការភាគច្រើនទទួលប្រាក់បៀវត្សរបស់ពួកគេនៅចុងខែនីមួយៗ ដែលធ្វើឱ្យពួកគេអាចមិនមានរូបិយវត្ថុគ្រប់គ្រាន់សម្រាប់ទូទាត់ទំនិញនិងសេវានៅដើមខែឬនៅពាក់កណ្តាលខែ ប៉ុន្តែជាមួយនឹងប័ណ្ណឥណទាន ពួកគេអាចប្រើប្រាស់ប័ណ្ណនេះដើម្បីផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់ពួកគេបាន ដោយមិនចាំបាច់រង់ចាំដល់ពេលបើកប្រាក់បៀវត្សឡើយ។ ដូច្នេះ មនុស្សអាចទទួលបានឥណទានកាន់តែច្រើន នោះបរិមាណរូបិយវត្ថុដែលពួកគេត្រូវការគឺកាន់តែតិច។

ជារួម តម្រូវការរូបិយវត្ថុប្រែប្រួលនៅពេល៖ ១/- អត្រាការប្រាក់កើនឡើង តម្រូវការនៃការកាន់រូបិយវត្ថុថយចុះ ២/- កម្រិតថ្លៃ ឬអតិផរណាកើនឡើង តម្រូវការនៃការកាន់រូបិយវត្ថុកើនឡើង ៣/- កម្រិតចំណូលកើនឡើង តម្រូវការនៃការកាន់រូបិយវត្ថុកើនឡើង និង ៤/- លទ្ធភាពនៃការទទួលបានឥណទានកើនឡើង តម្រូវការនៃការកាន់រូបិយវត្ថុថយចុះ។

## ១.៦. ដុល្លារូបនីយកម្ម

លោក Kurt Schuler បានឱ្យនិយមន័យដុល្លារូបនីយកម្មថាជាបាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសមួយ បានជ្រើសរើសប្រើប្រាស់ប្រាក់ដុល្លារអាមេរិកឬរូបិយប័ណ្ណបរទេសដទៃទៀតជំនួសឬទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិនៃប្រទេសនោះ។[11] ដុល្លារូបនីយកម្មជាបាតុភូតដែលគេរមែងឃើញកើតមានឡើងនៅក្នុងប្រទេសកំពុងលូតលាស់ ឬប្រទេសកំពុងអភិវឌ្ឍន៍ដែលបានជួបប្រទះអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយ។ ដោយប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណដែលរឹងមាំនិងមានស្ថិរភាពតម្លៃ ពេលខ្លះរដ្ឋាភិបាលអាចដោះស្រាយវិបត្តិអស្ថិរភាពដែលកើតមាននៅក្នុងសេដ្ឋកិច្ចរបស់គេដោយសម្រេចទទួលយកប្រាក់ដុល្លារអាមេរិកជារូបិយវត្ថុប្រើប្រាស់ជាផ្លូវការនៅក្នុងប្រទេសតែម្តង ហើយក្នុងករណីខ្លះទៀតដុល្លារូបនីយកម្មអាចកើតឡើងដោយខ្លួនឯង ដោយសារប្រជាជន

[11] Kurt Schuler, (២០០០), *Basics of Dollarization*

បានចាប់ផ្តើមមើលឃើញពីតម្លៃនៃប្រាក់ដុល្លារ និងងាកមករក្សាទុកប្រាក់ដុល្លារជាទ្រព្យសម្បត្តិ និងប្រើប្រាស់វាសម្រាប់ទូទាត់នៅក្នុងជីវភាពប្រចាំថ្ងៃ។

## ១.៧. ប្រភេទដុល្លារូបនីយកម្ម

ដុល្លារូបនីយកម្មត្រូវបានបែងចែកចេញជាបីប្រភេទធំៗ គឺដុល្លារូបនីយកម្មផ្លូវការ ដុល្លារូប-នីយកម្មពាក់កណ្តាលផ្លូវការ និងដុល្លារូបនីយកម្មមិនផ្លូវការ។

### ១.៧.១. ដុល្លារូបនីយកម្មផ្លូវការ (Official Dollarization)

ដុល្លារូបនីយកម្មផ្លូវការ ឬដុល្លារូបនីយកម្មពេញលេញ (Full dollarization) គឺជាស្ថានភាពដែលរូបិយប័ណ្ណបរទេសត្រូវបានអនុម័តជាផ្លូវការដោយច្បាប់ជារូបិយវត្ថុនីត្យានុកូល (Legal Tender) សម្រាប់ប្រើប្រាស់នៅក្នុងប្រទេសមួយ។ ដូច្នេះ មិនត្រឹមតែរូបិយប័ណ្ណបរទេសអាចត្រូវបានប្រើប្រាស់ស្របច្បាប់ដោយវិស័យឯកជន វាថែមទាំងត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលនៃប្រទេសនោះក្នុងការទូទាត់ទៀតផង ដូចជា ចំណាយរដ្ឋាភិបាលទៅលើការអភិវឌ្ឍ ប្រាក់បៀវត្សមន្ត្រីរាជការ និងការប្រមូលពន្ធ ជាដើម។ មូលហេតុចម្បងនៃដុល្លារូបនីយកម្មផ្លូវការ គឺដោយសារការសម្រេចចិត្តផ្នែកនយោបាយ ឬកត្តាសេដ្ឋកិច្ច ដូចជា អស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពទន់ខ្សោយនៃប្រព័ន្ធហិរញ្ញវត្ថុ។ សម្រាប់ប្រទេសដុល្លារូបនីយកម្មមួយចំនួន រដ្ឋាភិបាលអាចនឹងអនុម័តរូបិយប័ណ្ណបរទេសដល់ទៅពីរជារូបិយវត្ថុនីត្យានុកូលនៃប្រទេស ដោយសារតែទំហំនៃការប្រើប្រាស់រូបិយប័ណ្ណទាំងនេះនៅក្នុងប្រទេសរបស់ខ្លួន។ ឧទាហរណ៍ ប្រទេសអង់ដូរ៉ាជាប្រទេសដែលរដ្ឋាភិបាលអនុញ្ញាតឱ្យប្រើប្រាស់រូបិយប័ណ្ណពីរជារូបិយវត្ថុនីត្យានុកូលគឺ ប្រាក់ហ្វ្រង់បារាំង (French Franc) និងប្រាក់ប៉េស្តាអេស្ប៉ាញ (Spanish Peseta)។

### ១.៧.២. ដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការ (Semi-official Dollarization)

ដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការ គឺសំដៅទៅលើស្ថានភាពដែលរូបិយប័ណ្ណបរទេស និងរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់ដោយសេរីនៅក្នុងសេដ្ឋកិច្ចក្នុងស្រុក ដោយប្រជាពលរដ្ឋភាគច្រើនយល់ថារដ្ឋាភិបាលទទួលយកការប្រើប្រាស់រូបិយប័ណ្ណបរទេស បើទោះបីជាមិនមានការប្រកាសជាផ្លូវការពីការទទួលស្គាល់ជាផ្លូវការក៏ដោយ។ ធនាគារកណ្តាលរបស់ប្រទេសដុល្លារូបនីយកម្មពាក់កណ្តាលផ្លូវការមានការលំបាកជាប់គាំងក្នុងការធ្វើសកម្មភាពគោលនយោបាយរូបិយវត្ថុ ដូច

ប្រទេសដុល្លារូបនីយកម្មផ្លូវការដែរ។ គេរមែងឃើញថានៅប្រទេសទាំងនោះរូបិយប័ណ្ណបរទេស តែងតែគ្របដណ្តប់ទៅលើប្រាក់បញ្ញើនៅក្នុងធនាគារ។ រីឯរូបិយវត្ថុជាតិវិញភាគច្រើន គឺត្រូវបាន ប្រើប្រាស់ក្នុងការអនុវត្តផែនការថវិកាជាតិដូចជា ការទូទាត់ពន្ធ និងបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ។ ចំពោះប្រតិបត្តិការទូទាត់វិញ ប្រជាពលរដ្ឋអាចប្រើប្រាស់រូបិយវត្ថុ ឬរូបិយប័ណ្ណបរទេសក៏បានអាស្រ័យ លើបទពិសោធន៍នៃប្រទេសនោះ។[12]

**១.៧.៣. ដុល្លារូបនីយកម្មមិនផ្លូវការ** (Unofficial Dollarization)

ដុល្លារូបនីយកម្មមិនផ្លូវការ កើតឡើងនៅពេលដែលប្រជាពលរដ្ឋនៃប្រទេសមួយរក្សាទុក ទ្រព្យសម្បត្តិរបស់ពួកគេជារូបិយប័ណ្ណបរទេស ទោះបីជារូបិយប័ណ្ណនោះមិនត្រូវបានអនុញ្ញាតឱ្យ ប្រើប្រាស់ក្នុងការទូទាត់ដោយច្បាប់ក៏ដោយ ពោលគឺមិនមែនជារូបិយវត្ថុនីត្យានុកូល។ ដុល្លារូបនីយកម្ម មិនផ្លូវការ រាប់បញ្ចូលទាំងករណីដែលប្រជាពលរដ្ឋត្រូវបានអនុញ្ញាតឱ្យរក្សាទុកទ្រព្យសកម្មជា រូបិយប័ណ្ណបរទេស និងករណីមិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកទ្រព្យសកម្មជារូបិយប័ណ្ណបរទេស។

ជាទូទៅ ដុល្លារូបនីយកម្មមិនផ្លូវការតែងវិវឌ្ឍជាបីដំណាក់កាល។ ដំណាក់កាលទីមួយ គឺ នៅពេលដែលប្រជាពលរដ្ឋចាប់ផ្តើមរក្សាទុកទ្រព្យសកម្មដូចជា សញ្ញាប័ណ្ណនិងប្រាក់បញ្ញើចារឹកជា រូបិយប័ណ្ណបរទេស ដែលគេហៅថា "ការជំនួសទ្រព្យសកម្ម" (Asset Substitution)។ ឥរិយាបថបែប នេះកើតឡើង ដោយសារតែពួកគេមានបំណងចង់ការពារតម្លៃនៃទ្រព្យសម្បត្តិរបស់ពួកគេទៅនឹង អតិផរណានៃរូបិយវត្ថុក្នុងស្រុក។ ក្នុងដំណាក់កាលទី២ ប្រជាពលរដ្ឋចាប់ផ្តើមទុកប្រាក់បញ្ញើរបស់ ពួកគេនៅធនាគារក្នុងស្រុកជារូបិយប័ណ្ណបរទេស (ប្រសិនបើអនុញ្ញាតដោយរដ្ឋាភិបាល) ហើយ ក្រោយមកពួកគេក៏ចាប់ផ្តើមប្រើប្រាស់រូបិយប័ណ្ណបរទេសជាមុខងារមធ្យោបាយដោះដូរ និងសន្សំ។ សេដ្ឋវិទូឱ្យឈ្មោះបាតុភូតនេះថា "ការជំនួសរូបិយវត្ថុ" (Currency Substitution)។ ទោះជាយ៉ាងណា ប្រាក់ឈ្នួល ការយកពន្ធ និងចំណាយប្រចាំថ្ងៃដូចជា ចំណាយទៅលើការទិញម្ហូបអាហារ និងថ្លៃទឹក ថ្លៃអគ្គិសនីជាដើម ត្រូវបានទូទាត់ដោយរូបិយវត្ថុក្នុងស្រុក។ ប៉ុន្តែសម្រាប់ការទូទាត់ទំនិញដែលមាន តម្លៃថ្លៃដូចជា រថយន្ត ផ្ទះ ដីធ្លី ជាដើម ត្រូវបានទូទាត់ជារូបិយប័ណ្ណបរទេស។ ក្នុងដំណាក់កាល ចុងក្រោយនៃដុល្លារូបនីយកម្មមិនផ្លូវការ ប្រជាពលរដ្ឋទាំងអស់ចាប់ផ្តើមគិតតម្លៃនៃទំនិញនិងសេវា

[12] Kurt Schuler, (២០០០), *Basics of Dollarization*

ជារូបិយប័ណ្ណបរទេស ហើយការទូទាត់ជារូបិយវត្ថុក្នុងស្រុកត្រូវធ្វើឡើងដោយគិតតាមអត្រាប្តូរប្រាក់ជាក់លាក់មួយ។[13]

## ១.៨. ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ច

ដុល្លារូបនីយកម្មផ្តល់ទាំងផលប្រយោជន៍ និងផលប៉ះពាល់ដល់សេដ្ឋកិច្ចនៃប្រទេសមួយ។ ទម្ងន់នៃផលប្រយោជន៍ និងផលប៉ះពាល់ គឺអាស្រ័យទៅតាមបរិការណ៍សេដ្ឋកិច្ចនិងនយោបាយនៃប្រទេសនីមួយៗ ប៉ុន្តែ ជាទូទៅ ដុល្លារូបនីយកម្មមានគុណសម្បត្តិនិងគុណវិបត្តិដូចតទៅ៖

### ១.៨.១. គុណសម្បត្តិនៃដុល្លារូបនីយកម្ម

ជាធម្មតា ប្រទេសដែលស្ថិតនៅក្នុងស្ថានភាពដុល្លារូបនីយកម្ម តែងជាប្រទេសដែលមានអស្ថិរភាពថ្លៃរូបិយវត្ថុ (អតិផរណាខ្ពស់) និងអស្ថិរភាពសេដ្ឋកិច្ច។ ដើម្បីស្តារស្ថានភាពសេដ្ឋកិច្ចរបស់គេឡើងវិញ រូបិយប័ណ្ណដែលមានតម្លៃនិងមានភាពរឹងមាំដូចជាប្រាក់ដុល្លារអាមេរិក ត្រូវបានប្រទេសទាំងនោះអនុម័តជារូបិយវត្ថុនីត្យានុកូល ឬប្រជាជននៃប្រទេសទាំងនោះទទួលយកមកប្រើប្រាស់ជាមធ្យោបាយទូទាត់ សន្សំ និងខ្នាតសម្រាប់វាស់តម្លៃ។ ហេតុដូចនេះ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកអាចជួយឱ្យសេដ្ឋកិច្ចដែលមានអស្ថិរភាពវិលត្រឡប់មកស្ថិរភាពវិញ និងធ្វើឱ្យអត្រាអតិផរណាត្រឡប់មកកម្រិតទាបវិញផងដែរ តាមរយៈការជំនួសមុខងាររូបិយវត្ថុនៃសេដ្ឋកិច្ចនោះ។ ម្យ៉ាងទៀត ការទទួលយកប្រាក់ដុល្លារអាមេរិកក៏បានផ្សារភ្ជាប់ប្រព័ន្ធហិរញ្ញវត្ថុ ធនាគារ និងសេដ្ឋកិច្ចនៃប្រទេសនោះជាមួយនឹងប្រព័ន្ធហិរញ្ញវត្ថុ ធនាគារ និងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកផងដែរ។ ការដាក់ចេញគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលអាមេរិក នឹងមានឥទ្ធិពលទៅលើសេដ្ឋកិច្ចនៃប្រទេសកំពុងប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ដែលពេលខ្លះអាចទទួលអំណោយផលពីគោលនយោបាយដែលបានដាក់ចេញនោះទៀតផង។ ឧទាហរណ៍ ប្រសិនបើធនាគារកណ្តាលអាមេរិកសម្រេចចិត្តកាត់បន្ថយអត្រាការប្រាក់គោល នោះអត្រាការប្រាក់ឥណទាននៃប្រទេសដុល្លារូបនីយកម្មនឹងមានកម្រិតទាបដែលអាចជំរុញការវិនិយោគនៅក្នុងស្រុកឱ្យបានច្រើនជាងមុន សំដៅរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច។ លើសពីនេះ ដុល្លារូបនីយកម្មបានសម្រួលដល់ការទូទាត់និងការធ្វើពាណិជ្ជកម្មអន្តរជាតិ ដោយសកម្មភាពទាំងនោះភាគច្រើនត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ដែលអាចកាត់បន្ថយហានិភ័យ

[13] Kurt Schuler, (២០០០), *Basics of Dollarization*

អត្រាប្តូរប្រាក់ និងអាចជៀសផុតពីភាពមិនត្រូវគ្នានៃរូបិយប័ណ្ណ (Currency Mismatch) ដូចជាការរកចំណូលបានជារូបិយប័ណ្ណខុសពីរូបិយប័ណ្ណដែលត្រូវបានយកទៅទូទាត់ការចំណាយ។[14]

## ១.៨.២. គុណវិបត្តិនៃដុល្លារូបនីយកម្ម

ចំពោះគុណវិបត្តិវិញ ដុល្លារូបនីយកម្មអាចធ្វើឱ្យប្រទេសជាតិរងការខាតបង់ពីការបោះពុម្ពក្រដាសប្រាក់ (Seigniorage) ដោយសារតែទំហំនៃតម្រូវការរូបិយវត្ថុមានការធ្លាក់ចុះ និងមានកម្រិតទាបធៀបនឹងតម្រូវការប្រាក់ដុល្លារអាមេរិក ឬបើក្នុងករណីដែលប្រទេសនោះទទួលយកប្រាក់ដុល្លារជារូបិយវត្ថុនីត្យានុកូលវិញ ប្រទេសនោះនឹងបាត់បង់ការរកចំណូលពីការបោះពុម្ពក្រដាសប្រាក់ទាំងស្រុងតែម្តង។ ម៉្យាងទៀត ប្រទេសដុល្លារូបនីយកម្មអាចបាត់បង់ឯករាជ្យភាពនិងអធិបតេយ្យភាពខាងផ្នែករូបិយវត្ថុ និងគោលនយោបាយរូបិយវត្ថុ ដោយសារតែប្រាក់ដុល្លារអាមេរិកត្រូវបានបោះផ្សាយនិងគ្រប់គ្រងដោយធនាគារកណ្តាលអាមេរិក។ នៅពេលដែលធនាគារកណ្តាលអាមេរិកសម្រេចចិត្តដាក់ចេញគោលនយោបាយរឹតត្បិតតាមរយៈការដំឡើងអត្រាការប្រាក់គោល ប្រទេសដុល្លារូបនីយកម្មនឹងទទួលរងឥទ្ធិពលពីការកើនឡើងនៃអត្រាការប្រាក់ឥណទានជាប្រាក់ដុល្លារ និងការឡើងថ្លៃនៃប្រាក់ដុល្លារ ដែលអាចមានផលអវិជ្ជមានទៅលើការវិនិយោគ និងការនាំចេញនៃប្រទេសនោះ។ ទន្ទឹមនេះ ប្រទេសដុល្លារូបនីយកម្មក៏ងាយនឹងរងគ្រោះពីវិបត្តិហិរញ្ញវត្ថុ ឬសេដ្ឋកិច្ច ដែលបានកើតឡើងនៅសហរដ្ឋអាមេរិកផងដែរ ហើយសេដ្ឋកិច្ចប្រទេសដុល្លារូបនីយកម្មអាចនឹងរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិនោះ ដោយសារមិនមានឧបករណ៍គោលនយោបាយគ្រប់គ្រាន់និងមានប្រសិទ្ធភាពសម្រាប់ទប់ទល់នឹងវិបត្តិ ដូចជាការបាត់បង់តួនាទីជាអ្នកឱ្យខ្ចីចុងក្រោយរបស់ធនាគារកណ្តាល ដែលធ្វើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមិនអាចស្វែងរកសន្ទនីយភាពបានគ្រប់គ្រាន់ និងទាន់ពេលវេលាដើម្បីដោះស្រាយវិបត្តិហិរញ្ញវត្ថុ។ មិនតែប៉ុណ្ណោះ រូបិយវត្ថុ គឺជាអត្តសញ្ញាណរបស់ជាតិ ការបោះបង់ចោលរូបិយវត្ថុខ្លួនឯងហើយទទួលយករូបិយប័ណ្ណប្រទេសដទៃមកប្រើប្រាស់ គឺហាក់បីដូចជាការបោះបង់ចោលអត្តសញ្ញាណជាតិរបស់ខ្លួន ហើយឱ្យតម្លៃទៅលើអត្តសញ្ញាណជាតិសាសន៍ដទៃ។[15]

[14] Cohen, (២០០០), *Dollarization: Pros and Cons*

[15] Cohen, (២០០០), *Dollarization: Pros and Cons*

# ជំពូកទី២

# ធនាគារជាតិនៃកម្ពុជា

# ជំពូកទី២
# ធនាគារជាតិនៃកម្ពុជា

## ២.១. ទិដ្ឋភាពទូទៅនៃធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា គឺជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា ដែលជាស្ថាប័នស្វយ័តសាធារណៈមានលក្ខណៈជាពាណិជ្ជកម្មនិងឧស្សាហកម្ម។ ធនាគារជាតិនៃកម្ពុជាជានីតិបុគ្គលមានសមត្ថភាពគតិយុត្តិពេញលេញនិងជាអាទ៍មានសមត្ថភាពក្នុងការៈ ១/- ឱ្យប្រាក់គេខ្ចី ខ្ចីប្រាក់ពីគេ និងចុះកិច្ចសន្យាផ្សេងៗទៀត ២/- ប្តឹងនិងការពារនៅមុខតុលាការ និង ៣/- ធ្វើលទ្ធកម្ម កាន់កាប់ និងផ្ទេរចលនទ្រព្យ និងអចលនទ្រព្យ ក្នុងគោលដៅនៃការប្រកបរបរអាជីវកម្មរបស់ខ្លួន។ ធនាគារជាតិនៃកម្ពុជាអាចបើកគណនីជូនៈ ស្ថាប័នរដ្ឋឬអង្គភាពរដ្ឋបាលកណ្តាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាឱ្យធ្វើអាជីវកម្ម និងធនាគារកណ្តាលបរទេសនិងស្ថាប័នហិរញ្ញវត្ថុសាធារណៈអន្តរជាតិ។ គួរបញ្ជាក់ថា ធនាគារជាតិនៃកម្ពុជាមិនអាចបើកគណនីឱ្យសហគ្រាសឧស្សាហកម្មឬពាណិជ្ជកម្មបានទេ ទោះបីសហគ្រាសទាំងនោះជារបស់រដ្ឋក៏ដោយ។

អង្គការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា គឺក្រុមប្រឹក្សាភិបាល ដែលជាគណៈគ្រប់គ្រងមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលនេះត្រូវបានដឹកនាំដោយទេសាភិបាល និងមានសមាជិក៧រូប គឺទេសាភិបាល ទេសាភិបាលរង និងសមាជិក៥រូបទៀត ដែល១រូបតំណាងប្រមុខរាជរដ្ឋាភិបាល ១រូបតំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូបតំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច ១រូបតំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា និង១រូបទៀតតំណាងឱ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលមានភារកិច្ចជាអាទ៍ៈ រៀបចំគោលនយោបាយសម្រាប់កិច្ចប្រតិបត្តិការរបស់ធនាគារកណ្តាល ចេញប្រកាស បទបញ្ជា សារាចរ និងសេចក្តីណែនាំផ្សេងៗដើម្បីគ្រប់គ្រងកិច្ចការធនាគារកណ្តាល ចងក្រងបទបញ្ជាផ្ទៃក្នុង តាក់តែងលក្ខន្តិកៈបុគ្គលិក បង្កើតនាយកដ្ឋាននានារបស់ធនាគារកណ្តាល បង្កើតគណៈកម្មាធិការត្រួតពិនិត្យបញ្ជីគណនេយ្យ និងបង្កើតគណៈកម្មាធិការសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈនៃបុគ្គលិក។

ក្នុងកម្រិតបច្ចេកទេស ធនាគារជាតិនៃកម្ពុជាមានអគ្គនាយកដ្ឋានចំនួនប្រាំគឺ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា និងអគ្គាធិការដ្ឋាន ដែលក្នុងនោះរួមមាន២១នាយកដ្ឋានដឹកនាំដោយប្រធាននាយកដ្ឋាន។ នាយកដ្ឋាន និងអគ្គនាយកដ្ឋាន មានតួនាទី

អនុវត្តមុខងារប្រចាំថ្ងៃនៃប្រតិបត្តិការធនាគារកណ្តាល និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជាមានទីស្នាក់ការកណ្តាលស្ថិតនៅក្នុងទីក្រុងភ្នំពេញ ដែលជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ គិតត្រឹមឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាមានសាខានៅទូទាំង២១ ខេត្ត-ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន៖ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ចាម បាត់ដំបង ព្រៃវែង សៀមរាប កំពង់ធំ តាកែវ ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រះសីហនុ កោះកុង ព្រះវិហារ ក្រចេះ រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង បន្ទាយមានជ័យ និងស្វាយរៀង។

**រូបភាពទី១៖ រចនាសម្ព័ន្ធនៃធនាគារជាតិនៃកម្ពុជា**




ប្រភព៖ គេហទំព័រធនាគារជាតិនៃកម្ពុជា[16]

[16] ធនាគារជាតិនៃកម្ពុជា, (២០១៥), *រចនាសម្ព័ន្ធ*, នៅគេហទំព័រ៖ https://www.nbc.org.kh/about_the_bank/structure_of_nbc.php, ចូលមើលនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៧

## ២.២. ស្លាកសញ្ញា Logo របស់ធនាគារជាតិនៃកម្ពុជា

រូបភាពទី២៖ ស្លាកសញ្ញា Logo ជាភាសាខ្មែរ

ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

រូបភាពទី៣៖ ស្លាកសញ្ញា Logo ជាអង់គ្លេស

NATIONAL BANK OF CAMBODIA

Riel. Stability. Development.

រូបភាពទី៤៖ ស្លាកសញ្ញា Logo ជាភាសាបារាំង

BANQUE NATIONALE DU CAMBODGE

Riel. Stabilité. Développement.

ស្លាកសញ្ញា Logo ធនាគារជាតិនៃកម្ពុជា មានអក្សរ រ ពណ៌ប្រាក់ ជាតំណាង និងរង្វង់គួរស្រូវពណ៌មាសព័ទ្ធជុំវិញ។

រ ៖ តំណាងឱ្យប្រាក់រៀលបានបោះផ្សាយ

គួរស្រូវ ៖ តំណាងឱ្យវិស័យកសិកម្មដែលមានគួរស្រូវបីជួរអមសងខាងអក្សរ រ ហើយក្នុងមួយជួរមានប្រាំពីរគ្រាប់ (៧គ្រាប់តំណាងឱ្យថ្ងៃ ៧ មករា)។

## ២.៣. បេសកកម្មចម្បង និងសកម្មភាពរបស់ធនាគារជាតិនៃកម្ពុជា

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀលដែលជារូបិយវត្ថុជាតិ និងជាអ្នករក្សាស្ថិរភាពរូបិយវត្ថុ។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាជាអ្នកផ្តល់និងដកហូតអាជ្ញាប័ណ្ណ ព្រមទាំងដាក់ចេញបទប្បញ្ញត្តិនិងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រចាំ ចេញផ្សាយរបាយការណ៍និងព្រឹត្តបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ ដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រងបំណុលនិងឥណទេយ្យក្រៅប្រទេស។

## ២.៤. ប្រវត្តិនៃធនាគារជាតិនៃកម្ពុជា

### ២.៤.១. ឯករាជ្យភាពនិងអធិបតេយ្យភាពរូបិយវត្ថុ និងការកកើតឡើងនៃប្រព័ន្ធធនាគារ

ក្រោមការគ្រប់គ្រងរបស់អាណាព្យាបាលបារាំង ប្រទេសកម្ពុជាបានទទួលអំណោយផលពីការការពារពីប្រទេសបារាំងខាងផ្នែកព្រំដែន និងការធ្វើទំនើបកម្មសេដ្ឋកិច្ច។ នៅឆ្នាំ១៨៧៥ ធនាគារឥណ្ឌូចិនបានទទួលសិទ្ធិពិសេសក្នុងការបោះផ្សាយរូបិយវត្ថុក្នុងតំបន់ឥណ្ឌូចិន ដែលគ្របដណ្តប់លើប្រទេសចំនួនបី គឺប្រទេសកម្ពុជា វៀតណាម និងឡាវ។ ចាប់ពីឆ្នាំ១៨៩១ ធនាគារឥណ្ឌូចិនបានបោះផ្សាយក្រដាសប្រាក់ព្យ៉ាស់ (Piaster) សម្រាប់ជាមធ្យោបាយទូទាត់ សន្សំ និងខ្នាតកំណត់តម្លៃទំនិញនិងសេវា។ នៅឆ្នាំ១៩៤៨ សមាគតរដ្ឋឥណ្ឌូចិន (États Associés d'Indochine) បានចាប់កំណើតឡើងក្នុងក្របខ័ណ្ឌសហព័ន្ធបារាំង ដែលនាំឱ្យមានកំណែទម្រង់របបរូបិយវត្ថុឥណ្ឌូចិន និងលុបចោលសិទ្ធិពិសេសក្នុងការបោះផ្សាយរូបិយវត្ថុរបស់ធនាគារឥណ្ឌូចិន។ នៅឆ្នាំ១៩៥២ វិទ្យាស្ថានបោះផ្សាយប្រាក់ឥណ្ឌូចិននៃរដ្ឋកម្ពុជា ឡាវ វៀតណាម ត្រូវបានបង្កើតឡើង ដោយមានទីស្នាក់ការកណ្តាលនៅទីក្រុងភ្នំពេញ និងបានបោះផ្សាយរូបិយវត្ថុសម្រាប់ប្រើប្រាស់ក្នុងប្រទេសទាំងបី។

បន្ទាប់ពីស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាណាព្យាបាលបារាំងអស់រយៈពេល ៩ទសវត្សរ៍រួចមក ប្រទេសកម្ពុជាបានទទួលឯករាជ្យពេញលេញខាងផ្នែកនយោបាយនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ក្រោមការធ្វើព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យលើឆាកអន្តរជាតិរបស់ សម្តេចព្រះបាទនរោត្តមសីហនុវរ្ម័ន ព្រះមហាវីរៈក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជានៅតែ

បន្តស្ថិតនៅក្រោមឥទ្ធិពលរបស់ប្រទេសបារាំង ដោយសារប្រតិបត្តិការសេដ្ឋកិច្ចទាំងអស់ត្រូវពឹងផ្អែកលើរូបិយវត្ថុឥណ្ឌូចិនប្រាក់ព្យ៉ាស់ (Piaster)។ ដោយពិនិត្យឃើញពីសារៈសំខាន់និងភាពចាំបាច់នៃអធិបតេយ្យភាព និងឯករាជ្យភាពនៃរូបិយវត្ថុនិងសេដ្ឋកិច្ច សហភាពសមាគតរដ្ឋឥណ្ឌូចិន (The Union des États Associés d´Indochine) បានជួបប្រជុំចតុភាគី (បារាំង កម្ពុជា វៀតណាម និងឡាវ) នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៥៤ នៅទីក្រុងប៉ារីស ដើម្បីស្វែងរកដំណោះស្រាយក្នុងការទាមទារឯករាជ្យផ្នែករូបិយវត្ថុឱ្យប្រទេសសមាគតរដ្ឋនីមួយៗមានធនាគារកណ្តាលមួយ និងរូបិយវត្ថុមួយ។ នៅទីបំផុតប្រទេសកម្ពុជាបានទទួលឯករាជ្យខាងផ្នែករូបិយវត្ថុ និងបានបង្កើតធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ ហើយវិទ្យាស្ថានបោះផ្សាយប្រាក់ឥណ្ឌូចិនក៏ត្រូវបានបិទទ្វារដើម្បីបញ្ចប់ជាស្ថាពរនូវសម្ព័ន្ធភាពនៃការប្រើប្រាស់រូបិយវត្ថុរួមជាមួយប្រទេសវៀតណាម និងឡាវ។ មិនតែប៉ុណ្ណោះ ប្រាក់រៀលក៏ត្រូវបានដាក់ឱ្យចរាចរដោយជោគជ័យនៅក្នុងខែកញ្ញា ឆ្នាំ១៩៥៥ ដែលបានអនុញ្ញាតឱ្យកម្ពុជាអាចកំណត់នូវតម្លៃរូបិយវត្ថុ បរិមាណរូបិយវត្ថុត្រូវបោះផ្សាយ បុរេប្រទានរូបិយវត្ថុផ្តល់ជូនរាជរដ្ឋាភិបាល ព្រមទាំងគោលនយោបាយពាណិជ្ជកម្ម និងសារពើពន្ធ។

**រូបភាពទី៥៖ ប្រាក់ព្យ៉ាស់ចរាចរណ៍ក្នុងសម័យអាណាព្យាបាលបារាំង**







ប្រភព៖ គេហទំព័រធនាគារជាតិនៃកម្ពុជា[17]

## ២.៤.២. ដំណាក់កាលឆ្នាំ១៩៥៤-១៩៧៥៖ ជាតូបនីយកម្មប្រព័ន្ធធនាគារ និងការដួលរលំនៃសេដ្ឋកិច្ចនិងរូបិយវត្ថុ

ចាប់តាំងពីការកកើតដំបូងរហូតដល់ឆ្នាំ១៩៧០ ធនាគារជាតិនៃកម្ពុជាបានបម្រើយ៉ាងជិតស្និទ្ធដល់គោលនយោបាយកសាងជាតិនៃសម័យសង្គមរាស្ត្រនិយម។ ក្នុងអំឡុងពេលនោះ ធនាគារ

[17] ធនាគារជាតិនៃកម្ពុជា, (២០១៥), https://www.nbc.org.kh/, ចូលមើលនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៧

ជាតិនៃកម្ពុជាមានការប្រែប្រួលជាសំខាន់នៅក្នុងឆ្នាំ១៩៦៤ ដោយបានប្រែក្លាយពីទម្រង់ជាស្ថាប័នពាក់កណ្តាលស្វយ័តទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈ ដែលមានលក្ខណៈឧស្សាហកម្មនិងពាណិជ្ជកម្ម។ នាពេលនោះ ធនាគារឯកជនជាតិនិងបរទេសដែលកំពុងធ្វើប្រតិបត្តិការត្រូវបានបង្កើតជាធនាគារដែលរដ្ឋកាន់កាប់ រួមមាន ធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម ធនាគារឥណទានជាតិ ធនាគារអភិវឌ្ឍន៍ និងធនាគារកសិកម្មជនបទ។ ទន្ទឹមនឹងនោះដែរ មន្ទីររាជសហករណ៍ដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៦ ត្រូវបានរៀបចំនិងគ្រប់គ្រងសហករណ៍បីគឺ សហករណ៍ផលិតកម្មសហករណ៍ឧបភោគបរិភោគ និងសហករណ៍ឥណទាន។ សហករណ៍ឥណទានបានធ្វើសកម្មភាពឥណទានយ៉ាងទូលំទូលាយទូទាំងប្រទេសនៅក្រៅប្រព័ន្ធធនាគារ ដើម្បីគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រនៅតាមទីជនបទ។ សហករណ៍ឥណទាននេះ ជាសំខាន់ត្រូវបានបង្កើតឡើងមុនការបង្កើតធនាគារកសិកម្មជនបទនាឆ្នាំ១៩៧០។

**រូបភាពទី៦៖ អគារធនាគារជាតិនៃកម្ពុជា កាលពីឆ្នាំ១៩៥៤**



**រូបភាពទី៧៖ ប្រាក់រៀលចរាចរណ៍នៅក្នុងសម័យសង្គមរាស្ត្រនិយម**



ប្រភព៖ គេហទំព័រធនាគារជាតិនៃកម្ពុជា[18]

[18] ធនាគារជាតិនៃកម្ពុជា, (២០១៥), https://www.nbc.org.kh/, ចូលមើលនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៧

ចាប់ពីឆ្នាំ១៩៧០ រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ប្រព័ន្ធធនាគារត្រូវបានធ្វើសេរីភាវូបនីយកម្មសាជាថ្មី ដើម្បីបង្កលក្ខណៈឱ្យធនាគារឯកជនអាចធ្វើសកម្មភាពទន្ទឹមនឹងធនាគាររដ្ឋទាំងឡាយក្រោមបទប្បញ្ញត្តិ និងការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ ទោះជាយ៉ាងណា ឯកជនភាវូបនីយកម្មក្រុមហ៊ុនរដ្ឋ និងសេរីភាវូបនីយកម្មពាណិជ្ជកម្មបរទេសមានដំណើរការយឺត ហើយភាពអសន្តិសុខ និងចំណាយខ្ពស់ទៅលើថ្លៃដឹកជញ្ជូនបានធ្វើឱ្យរោងចក្រ សហគ្រាស និងក្រុមហ៊ុនបិទទ្វារជាបន្តបន្ទាប់។ លើសពីនេះ ជំនួយរបស់សហរដ្ឋអាមេរិកបានក្លាយជាប្រភពតែមួយគត់សម្រាប់ហិរញ្ញប្បទាន និងការផ្គត់ផ្គង់ ដែលមានចំណែករហូតដល់ជាង៩០% នៃថវិកាជាតិ។ ប្រាក់រៀលបានបន្តធ្លាក់ថ្លៃរហូតដល់កម្រិតមិនអាចគ្រប់គ្រងបាន ដោយសារលំហូរចូលនៃប្រាក់ដុល្លារអាមេរិកមកក្នុងជីវភាពប្រចាំថ្ងៃ ការបោះផ្សាយប្រាក់រៀលសម្រាប់ចំណាយផ្នែកយោធានិងរដ្ឋាភិបាល និងការលំបាកក្នុងការផ្គត់ផ្គង់ ដែលនាំឱ្យថ្លៃទំនិញកើនឡើងយ៉ាងខ្លាំង។

### ២.៤.៣. ដំណាក់កាលឆ្នាំ១៩៧៥-១៩៧៩៖ ការលុបបំបាត់ចោលនូវរូបិយវត្ថុ និងប្រព័ន្ធធនាគារ

ជាអកុសល នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ (របបប៉ុលពត) បានឡើងកាន់អំណាច ធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារ អគារស្នាក់ការកណ្តាលត្រូវបានកម្ទេច ហើយរូបិយវត្ថុជាតិនិងប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង ដោយពួកប៉ុលពតបានយល់ឃើញថារូបិយវត្ថុនិងប្រព័ន្ធធនាគារជាប្រភពនៃការកេងប្រវ័ញ្ច (Source of Exploitation)។ ប្រជាជនរស់នៅក្នុងទីក្រុងភ្នំពេញត្រូវបានជម្លៀសទៅកាន់ខេត្តនានា និងបង្ខំឱ្យធ្វើហត្ថពលកម្មយ៉ាងធ្ងន់ធ្ងរ។ ប៉ុលពតបានបង្ខំឱ្យអនុវត្តយ៉ាងឆាប់រហ័សនូវប្រព័ន្ធដ៏តឹងរ៉ឹងនៃសមូហភាវូបនីយកម្ម និងការគ្រប់គ្រងបែបផ្តាច់ការទៅលើជីវភាពសង្គម។

របបប៉ុលពតបានបន្សល់ទុកនូវបញ្ហាប្រឈមជាច្រើន ដោយសារបញ្ញវន្តជាច្រើនរូបត្រូវបានសម្លាប់ដោយរបបប៉ុលពត និងខ្លះទៀតបានភៀសខ្លួនចេញពីប្រទេសទៅជ្រកកោននៅប្រទេសដទៃ ហើយបន្ទាប់ពីសង្គ្រាម អ្នកចេះដឹង អ្នកជំនាញ និងអ្នកមានបទពិសោធន៍មានចំនួនតិចតួចបំផុត។ អ្នកនៅរស់រានមានជីវិតនិងមានសមត្ថភាពមួយចំនួនដែលនៅសេសសល់ក្នុងប្រទេស មានការភ័យខ្លាចក្នុងការធ្វើការ ដោយសារពួកគេមានគំនិតថារបបប៉ុលពតអាចនឹងវិលត្រឡប់មកវិញ។ លើសពីនេះទៀត ក្រៅពីកង្វះធនធានមនុស្ស ក៏មានកង្វះយ៉ាងធ្ងន់ធ្ងរនៃធនធានហិរញ្ញវត្ថុផងដែរ។ ក្នុងពេលដែលសេដ្ឋកិច្ចនៅទន់ខ្សោយនៅឡើយ ហើយការផ្គត់ផ្គង់សាច់ប្រាក់ស្ទើរតែមិនមានសោះដោយសារតែគោលនយោបាយរបស់របបប៉ុលពត សកម្មភាពសេដ្ឋកិច្ចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយ

ដោះដូរទំនិញនឹងទំនិញ ចំណែកប្រាក់ខែមន្ត្រីរាជការស៊ីវិលត្រូវបានទូទាត់ដោយប្រើអង្ករ ត្រី ប្រេង ជាដើម។

រូបភាពទី៨៖ អគារស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជាដែលត្រូវបានកម្ទេចចោលក្នុងសម័យ ប៉ុល ពត



រូបភាពទី៩៖ រូបិយវត្ថុសន្លឹកសន្ទាប់ដែលត្រូវបានបោះបង់ចោលក្នុងសម័យ ប៉ុល ពត




ប្រភព៖ គេហទំព័រធនាគារជាតិនៃកម្ពុជា[19]

## ២.៤.៤. ដំណាក់កាលឆ្នាំ១៩៧៩-១៩៨៩៖ ការស្តារប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចឡើងវិញ

ក្នុងដំណាក់កាលនេះ ប្រវត្តិស្ថាប័នរូបិយវត្ថុនិងធនាគារកម្ពុជាបានកត់ត្រានូវវីរភាពដ៏ថ្លៃថ្លា ការលះបង់ខ្ពស់បំផុត និងការសម្រេចលទ្ធផលគួរជាទីមោទនៈ។ ប្រការនេះបានសម្តែងឡើងតាមរយៈ ការបង្កើតធនាគារកណ្តាល ការបោះផ្សាយប្រាក់រៀលឡើងវិញ និងការរួមចំណែកស្តារជីវភាពសង្គ្រោះ ប្រជាជាតិឱ្យរួចផុតពីគ្រោះទុរ្ភិក្សក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩។

ទោះបីជាអគារធនាគារជាតិនៃកម្ពុជាត្រូវបានកម្ទេចឱ្យលោយជាផេះផង់ក៏ដោយ ក៏ទីស្នាក់ការ កណ្តាលត្រូវបានបើកជាបណ្តោះអាសន្ននៅលើអគារនៃអតីតធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម ដែល មានតែសម្បកអគារ។ គ្មានប្រភពហិរញ្ញវត្ថុ គ្មានសេសសល់មរតកធនាគារពីមុនមក ទាំងឯកសារ បទពិសោធន៍ និងធនធានមនុស្ស អ្នកចេះដឹងត្រូវបានកាប់សម្លាប់ ត្រូវបែកខ្ញែកទៅគ្រប់ទិសទី ខ្លះបាក់ ស្មារតីមិនហ៊ានចូលបម្រើការងារដោយខ្លាចការឃាឃីនៃរបបប៉ុលពតជាថ្មីទៀត។ ក្នុងស្ថានភាពដែល ប្រជាជនកម្ពុជាមានរាងកាយស្គមស្គាំង បាក់កម្លាំង និងគ្រួសារបែកបាក់មិនទាន់ជួបជុំគ្នា តែតាមរយៈ ការប្រមូលផ្តុំកម្លាំងចិត្ត សាមគ្គីភាព ការធ្វើការមិនស្គាល់ថ្ងៃ-យប់ ការឆ្លងកាត់គ្រោះអសន្តិសុខគ្រប់

[19] ធនាគារជាតិនៃកម្ពុជា, (២០១៥), https://www.nbc.org.kh/, ចូលមើលនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧

កន្លែង និងការខិតខំប្រឹងប្រែងធ្វើការផងរៀនផងពីជំនាញការដែលផ្តល់មកតាមរយៈជំនួយស្តួចស្តើង នៃប្រទេសជាមិត្ត និងអន្តរជាតិ ប្រព័ន្ធធនាគារមួយត្រូវបានកសាងឡើងវិញពីចំណុចសូន្យដោយបាតដៃទទេ។

នៅថ្ងៃទី១០ខែតុលា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានបង្កើតធនាគារកណ្តាលនៃប្រទេសកម្ពុជាឡើងវិញ តាមអនុក្រឹត្យលេខ១១២១ អ.ន.ក្រ ដោយមានឈ្មោះថា "ធនាគារជាតិនៃប្រជាជនកម្ពុជា"។ ធនាគារជាតិនៃប្រជាជនកម្ពុជាបានរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីនដឹកនាំ និងសកម្មភាពប្រតិបត្តិការនៅទីស្នាក់ការកណ្តាលរបស់ខ្លួន ហើយបានពង្រីកបណ្តាញទៅតាមបណ្តាខេត្ត-ក្រុងទាំង២០យ៉ាងឆាប់រហ័សបំផុត។ ក្រោមការជួយឧបត្ថម្ភពីវៀតណាម ធនាគារជាតិនៃប្រជាជនកម្ពុជាបានទទួលជំនួយបច្ចេកទេសតាមរយៈជំនាញការវៀតណាមដែលជួយផ្តល់ជាអនុសាសន៍ និងការបញ្ជូនមន្ត្រីជំនាញទៅសិក្សានិងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈនៅប្រទេសវៀតណាម។ ក្នុងរយៈពេលត្រឹមតែ៦ខែប៉ុណ្ណោះក្រោយការបង្កើតធនាគារជាតិនៃប្រជាជនកម្ពុជា ប្រាក់រៀលថ្មីត្រូវបានបោះផ្សាយ និងដាក់ឱ្យធ្វើចរាចរឡើងវិញ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដើម្បីធ្វើជាមធ្យោបាយដោះដូរ ជាខ្នាតវាស់តម្លៃ និងជាឧបករណ៍សន្សំសម្រាប់ឱ្យប្រជាពលរដ្ឋប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងដើម្បីជួយឱ្យជីវភាពសង្គមវិលមករកប្រក្រតីភាពវិញ។ ប្រាក់រៀលបានបម្រើការទូទាត់យ៉ាងឆាប់រហ័ស ជាពិសេសការទូទាត់ប្រាក់បៀវត្សនិងការផ្តល់ឥណទាន ព្រមទាំងបានបង្កើតឡើងវិញនូវសកម្មភាពធនាគារនិងប្រព័ន្ធថវិការដ្ឋ។ ការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញនេះត្រូវបានប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជាអបអរសាទរ និងស្វាគមន៍យ៉ាងខ្លាំង ហើយគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ ក្រោយថ្ងៃមហាជ័យជម្នះ ៧មករា និងជាជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោល-នយោបាយសេដ្ឋកិច្ចផងដែរ។

ក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨៩ ប្រទេសកម្ពុជាបានប្រើប្រាស់ប្រព័ន្ធធនាគារមួយថ្នាក់ (Mono-banking System) ដែលធនាគារជាតិនៃប្រជាជនកម្ពុជាបានដើរតួនាទីសំខាន់ៗបី គឺជាអាជ្ញាធររូបិយវត្ថុ ជារតនាគារជាតិ និងជាគ្រឹះស្ថានធនាគារតែមួយគត់ដែលផ្តល់សេវាធនាគារ ដូចជាសេវាទទួលប្រាក់បញ្ញើ សេវាផ្តល់ឥណទាន និងសេវាទូទាត់។ តាមរយៈគោលនយោបាយឥណទានចំពោះក្រុមសាមគ្គីបង្កបង្កើនផល និងសហគ្រាសរដ្ឋ ធនាគារជាតិនៃកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការស្តារសកម្មភាពសេដ្ឋកិច្ចឡើងវិញដូចជា មុខរបរនេសាទ ការស្តារដើកសិកម្ម ការដាំដុះ ដំណាំកៅស៊ូនិងឈើ សិប្បកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ជាពិសេស គឺការប្រមូលទិញកសិផលដែលធ្វើឱ្យផលិតផលកសិកម្មបានរីកចម្រើនបានយ៉ាងឆាប់រហ័ស។

### ២.៤.៥. ដំណាក់កាលអន្តរកាលឆ្នាំ១៩៨៩-១៩៩៣៖ កំណែទម្រង់ពីសេដ្ឋកិច្ចផែនការទៅសេដ្ឋកិច្ចទីផ្សារសេរី

នៅឆ្នាំ១៩៨៩ សភាពការណ៍សេដ្ឋកិច្ចកម្ពុជាមានការវិវត្តប្រែប្រួលជាវិជ្ជមានគួរឱ្យកត់សម្គាល់ ដោយរាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ច ពីរបបសេដ្ឋកិច្ចផែនការមជ្ឈការឱ្យទៅជារបបសេដ្ឋកិច្ចទីផ្សារសេរី។ នាពេលនោះ រដ្ឋបានទទួលស្គាល់កម្មសិទ្ធិឯកជនលើដីធ្លីនិងមធ្យោបាយដឹកជញ្ជូន និងបានធ្វើកំណែទម្រង់សហគ្រាសរដ្ឋ។ ទន្ទឹមនោះ ប្រព័ន្ធធនាគារក៏បានចាប់ផ្តើមធ្វើកំណែទម្រង់ផងដែរ ស្របតាមយន្តការទីផ្សារ។ អគារស្នាក់ការធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញនៅឆ្នាំ១៩៩០។ នៅឆ្នាំ១៩៩២ ធនាគារជាតិនៃប្រជាជនកម្ពុជាត្រូវបានប្តូរឈ្មោះទៅជា "ធនាគារជាតិនៃកម្ពុជា" និងបានប្រែក្លាយប្រព័ន្ធធនាគារពីមួយថ្នាក់ទៅជាប្រព័ន្ធធនាគារពីរថ្នាក់ (Two-tier Banking System) ដូចសព្វថ្ងៃនេះ ហើយបានបើកទូលាយការធ្វើអាជីវកម្មលើវិស័យធនាគារ ដោយអនុញ្ញាតឱ្យធនាគារពាណិជ្ជបង្កើតឡើងក្រោមច្បាប់ក្នុងស្រុក ឬក្រោមទម្រង់ជាសាខាធនាគារបរទេស។ ប្រការនេះតម្រូវឱ្យធនាគារជាតិនៃកម្ពុជាពង្រឹងតួនាទីកណ្តាល បង្កើនសមត្ថភាពគ្រប់គ្រងណែនាំ តាមដាន និងត្រួតពិនិត្យបណ្តាធនាគារពាណិជ្ជ ដែលពេលនោះមានចំនួន៣២ធនាគារ។

លទ្ធផលនៃការបោះឆ្នោតទូទាំងប្រទេសលើកទី១នាឆ្នាំ១៩៩៣ បាននាំមកនូវបរិយាកាសថ្មីដល់ប្រជាជាតិទាំងមូលក៏ដូចប្រព័ន្ធធនាគារដែរ។ នោះគឺការបើកទ្វារចំហរទៅកាន់ពិភពលោក ការឧបត្ថម្ភគាំទ្រយ៉ាងទូលំទូលាយពីសហគមន៍អន្តរជាតិ ការអនុវត្តរបបសេដ្ឋកិច្ចទីផ្សារ ការវិលមកកសាងសង្គមជាតិវិញនៃប្រជាជនកម្ពុជាគ្រប់ទិសទីនិងគ្រប់និន្នាការនយោបាយ ការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការកសាងនីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស។ លក្ខណៈជាប្រព័ន្ធធនាគារមាន២ថ្នាក់តាមបែបសេដ្ឋកិច្ចទីផ្សារសេរី ដែលថ្នាក់ទី១ មានធនាគារជាតិនៃកម្ពុជា និងថ្នាក់ទី២ មានធនាគារពាណិជ្ជ ក៏ត្រូវបានរៀបចំនិងពង្រឹងជាបន្តបន្ទាប់ទាំងរចនាសម្ព័ន្ធនិងយន្តការការងារ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាបានធ្វើឱ្យសម្រេចជាមូលដ្ឋានក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពតម្លៃប្រាក់រៀល ស្ថិរភាពអត្រាប្តូរប្រាក់ និងការបង្កើនទុនបម្រុងអន្តរជាតិ។

### ២.៤.៦. ដំណាក់កាលឆ្នាំ១៩៩៣ ដល់ពេលបច្ចុប្បន្ន៖ ដំណើរទៅរកភាពរីកចម្រើននៃប្រព័ន្ធធនាគារនិងសេដ្ឋកិច្ច

ចាប់តាំងពីឆ្នាំ១៩៩៣ ក្នុងដំណើរនៃការអនុវត្តសេដ្ឋកិច្ចទីផ្សារ ធនាគារជាតិនៃកម្ពុជាមិនទាន់មាននៅឡើយនូវឧបករណ៍គោលនយោបាយរូបិយវត្ថុពេញលេញនិងមានប្រសិទ្ធភាព សម្រាប់កំណត់

និងដឹកនាំគោលនយោបាយរូបិយវត្ថុ ដើម្បីរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានសម្រាប់រក្សាស្ថិរភាពថ្លៃ។ ជាអាទិ៍ អត្រាការប្រាក់មិនមានឥទ្ធិពលទៅលើនិន្នាការសន្សំ ប្រតិបត្តិការទីផ្សារចំហមិនទាន់អាចធ្វើបានដោយគ្មានប័ណ្ណរតនាគារ សញ្ញាប័ណ្ណរដ្ឋាភិបាល។ល។ កត្តាទាំងនេះបានរាំងដល់ការគ្រប់គ្រងបរិមាណរូបិយវត្ថុក្នុងចរាចរណ៍។

ប្រព័ន្ធធនាគារកម្ពុជានៅមានភាពទន់ខ្សោយទាំងខាងដែនប្រតិបត្តិការ និងវិសាលភាពដែនដី។ នៅថ្នាក់ទី១ ទីស្នាក់ការកណ្តាលនៃធនាគារជាតិនៃកម្ពុជាទើបនឹងបានរៀបចំរចនាសម្ព័ន្ធ និងចាត់តាំងក្បាលម៉ាស៊ីនបានពេញលេញក្នុងឆ្នាំ១៩៩៨។ សាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងកំពុងស្ថិតក្នុងសភាពស្រពិចស្រពិលតាំងពីឆ្នាំ១៩៩៣មក ដែលនាំឱ្យថមថយខាងប្រតិបត្តិការ និងធ្លាក់ទន់ខ្សោយខាងការដឹកនាំនិងគ្រប់គ្រង។ នៅថ្នាក់ទី២ ធនាគារពាណិជ្ជទាំងឡាយបានបង្កើតឡើងក្នុងដំណាក់កាលដែលសេដ្ឋកិច្ចជាតិកំពុងត្រូវបានរៀបចំសណ្តាប់ធ្នាប់តាមបែបផែនសេដ្ឋកិច្ចទីផ្សារហើយស្ថិរភាពនយោបាយ សេដ្ឋកិច្ច និងសង្គម នាពេលនោះនៅផុយស្រួយនៅឡើយ។ ហេតុនេះហើយ សកម្មភាពប្រតិបត្តិការធនាគារក៏មិនទាន់ត្រូវបានពង្រីកឱ្យទូលំទូលាយនៅឡើយដែរ។ ទន្ទឹមនោះ សកម្មភាពមីក្រូហិរញ្ញវត្ថុបានកើតឡើងដោយឯកឯង ទៅតាមសំណូមពររបស់ប្រជាជននៅតាមតំបន់នានា ហើយទាមទារឱ្យមានការរៀបចំបទប្បញ្ញត្តិគ្រប់គ្រងនិងត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់។

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ត្រូវបានអនុម័តដោយរដ្ឋសភា ដើម្បីពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងពង្រឹងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ។ ច្បាប់នេះបានកំណត់មុខងារ-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាជាធនាគារកណ្តាលនៃប្រទេស និងជាអាជ្ញាធរអាណាព្យាបាលលើប្រព័ន្ធធនាគារទាំងមូល ហើយមានបេសកកម្មចម្បង គឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ ដើម្បីគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានទទួលការគាំទ្រយ៉ាងកក់ក្តៅពីសំណាក់រាជរដ្ឋាភិបាល ពីធនាគារកណ្តាលក្រៅប្រទេស ព្រមទាំងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ជាពិសេសមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

បន្ទាប់មក ដើម្បីជាមូលដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងទីផ្សារប្តូរប្រាក់ និងត្រួតពិនិត្យសុខភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ច្បាប់ចំនួនពីរទៀតក៏ត្រូវបានអនុម័តដែលរួមមាន៖ i/- ច្បាប់ស្តីពីការគ្រប់គ្រងការប្តូរប្រាក់ អនុម័តនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧ និង ii/- ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អនុម័តនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩។ អនុវត្តតាមស្មារតីនៃច្បាប់ស្តីពី

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានចាប់ផ្តើមអនុវត្តកម្មវិធីកំណែទម្រង់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅមកលើប្រព័ន្ធធនាគារកម្ពុជា។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ត្រូវបានតម្រូវឱ្យបំពេញដើមទុនរបស់ពួកគេឱ្យបានគ្រប់គ្រាន់តាមកម្រិតដើមទុនអប្បបរមាដែលបានកំណត់ និងតម្រូវឱ្យគ្រឹះស្ថានទាំងនោះរៀបចំនិងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដើម្បីកាត់បន្ថយនូវហានិភ័យផ្សេងៗ។

នៅឆ្នាំ២០០១ ដើម្បីបន្តពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាឱ្យមានដំណើរការទៅដោយរលូន មានសុវត្ថិភាព និងមានកម្រិតសមាហរណកម្មប្រហាក់ប្រហែលនឹងប្រទេសក្នុងតំបន់ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត ចក្ខុវិស័យនិងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ សំដៅកំណត់ផែនការយុទ្ធសាស្ត្រតាមលំដាប់លំដោយអាទិភាពក្នុងការពង្រឹងនិងអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ ដោយយល់ឃើញពីសារៈសំខាន់នៃឯកសារយុទ្ធសាស្ត្រនេះ និងដើម្បីអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយនូវកម្មវិធីផ្សេងៗទៀត រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះជាបន្តបន្ទាប់ក្នុងរយៈពេល៥ឆ្នាំម្តងគឺៈ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។

## ២.៥. មុខងារ និងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានមុខងារ និងភារកិច្ចដូចតទៅៈ

- កំណត់គោលដៅគោលនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា
- ត្រិះរិះរក អនុវត្ត និងត្រួតពិនិត្យគោលនយោបាយរូបិយវត្ថុ និងគ្រប់គ្រងការប្តូរប្រាក់ឱ្យសម្រេចទៅតាមគោលដៅដែលបានកំណត់
- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផល ហើយលើកជាសំណើនិងវិធានការជូនរាជរដ្ឋាភិបាល
- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឯទៀតដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើម ព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ

- ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ
- ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ទទួលខុសត្រូវ និងអនុវត្តក្នុងនាមព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិសាធារណៈ ក្នុងកិច្ចការធនាគារ ឥណទាន និងរូបិយវត្ថុ
- ដំឡើងតារាងជញ្ជីងទូទាត់
- ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាមួយប្រទេសក្រៅ
- ចូលរួមក្នុងការបង្កើត និងការត្រួតពិនិត្យទីផ្សាររូបិយវត្ថុ និងទីផ្សាហិរញ្ញវត្ថុ
- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ មូលបត្រត្បូងថ្ម និងលោហធាតុមានតម្លៃ ព្រមទាំងចេញបទបញ្ជានិងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ និង
- កំណត់អត្រាការប្រាក់។

## ២.៦. គោលនយោបាយរូបិយវត្ថុ

នៅក្នុងសេដ្ឋកិច្ច រាជរដ្ឋាភិបាលអាចដាក់ចេញនិងអនុវត្តគោលនយោបាយសេដ្ឋកិច្ចចំនួនពីរប្រភេទធំៗ គឺ គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ។ នៅក្នុងបរិការណ៍សេដ្ឋកិច្ចកម្ពុជា ធនាគារជាតិនៃកម្ពុជាជាស្ថាប័នដែលទទួលបន្ទុកដឹកនាំ កំណត់ និងអនុវត្តគោលនយោបាយរូបិយវត្ថុ រីឯគោលនយោបាយសារពើពន្ធវិញត្រូវបានដឹកនាំ កំណត់ និងអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ខណៈគោលនយោបាយសារពើពន្ធផ្តោតជាសំខាន់លើគោលនយោបាយពន្ធ ចំណាយរាជរដ្ឋាភិបាល និងការផ្ទេរមូលនិធិពីរាជរដ្ឋាភិបាលទៅកាន់ប្រជាពលរដ្ឋ គោលនយោបាយរូបិយវត្ថុគឺជាគោលនយោបាយដែលប្រើប្រាស់បរិមាណផ្គត់ផ្គង់រូបិយវត្ថុ ដើម្បីជំរុញដល់សកម្មភាពវិនិយោគនៅក្នុងសេដ្ឋកិច្ច ដែលជាលទ្ធផលនឹងជំរុញដល់ផលិតកម្ម និងកំណើនសេដ្ឋកិច្ច។ គោលនយោបាយរូបិយវត្ថុត្រូវបានអនុវត្តយ៉ាងសកម្មទាំងនៅប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ ដើម្បីរួមចំណែកដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ សម្រាប់កម្ពុជា ការអនុវត្តគោលនយោបាយរូបិយវត្ថុត្រូវបានធ្វើឡើងប្រកបដោយភាពទុនភ្លន់និងប្រុងប្រយ័ត្ន ដោយអតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាប ក្នុងអត្រាមធ្យមប្រចាំឆ្នាំទាបជាង ៥% ដែលជាអត្រាសមស្របសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានកម្រិត

ដុល្លារូបនីយកម្មខ្ពស់ ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ ព្រមទាំងឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តនៅមានកម្រិតនិងមានភាពអសកម្មនៅឡើយ។

### ២.៦.១. គោលដៅសំខាន់ៗនៃគោលនយោបាយរូបិយវត្ថុ

គោលដៅចម្បងបំផុតនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ គឺស្ថិរភាពថ្លៃ។ ស្ថិរភាពថ្លៃដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតទាប និងស្ថិរភាពនៃអតិផរណា ត្រូវបានបណ្តាធនាគារកណ្តាលនៅលើពិភពលោកចាត់ទុកថាជាគោលដៅដ៏សំខាន់បំផុត ពីព្រោះការកើនឡើងនៃកម្រិតថ្លៃទំនិញនិងសេវាអាចបង្កើតឱ្យមានភាពមិនប្រាកដប្រជានៅក្នុងសេដ្ឋកិច្ច ដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់អ្នកប្រើប្រាស់ អ្នកវិនិយោគ និងរដ្ឋាភិបាល ហើយជាលទ្ធផលបង្កើតឱ្យមានប្រព័ន្ធហិរញ្ញវត្ថុដែលមិនមានប្រសិទ្ធភាពនិងប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។ លើសពីនេះ អតិផរណាខ្ពស់ហួសហេតុអាចធ្វើឱ្យសាធារណជនបាត់ជំនឿទុកចិត្តទៅលើរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ដែលអាចបង្កឱ្យមានភាពរឹកររនៅក្នុងសង្គម ដោយប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមិនអាចទប់ទល់នឹងការបន្តឡើងថ្លៃនៃទំនិញនិងសេវាបាន។

ក្រៅពីគោលដៅរក្សាស្ថិរភាពថ្លៃដ៏ចម្បងនេះ ធនាគារកណ្តាលក៏មានគោលដៅផ្សេងៗចំនួន៥ទៀតផងដែរសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលរួមមាន កម្រិតខ្ពស់នៃភាពមានការងារធ្វើ កំណើនសេដ្ឋកិច្ច ស្ថិរភាពទីផ្សារហិរញ្ញវត្ថុ ស្ថិរភាពអត្រាការប្រាក់ និងស្ថិរភាពអត្រាប្តូរប្រាក់។

- **កម្រិតខ្ពស់នៃភាពមានការងារធ្វើ (High Employment)៖** ភាពមិនមានការងារធ្វើអាចប៉ះពាល់ដល់លទ្ធភាពនៃការផលិត និងប្រសិទ្ធភាពនៅក្នុងសេដ្ឋកិច្ច ដោយធនធានទំនេរទាំងនោះអាចត្រូវបានរួមចំណែកបង្កើនការផលិតនៅក្នុងសេដ្ឋកិច្ច។ម្យ៉ាងទៀត ភាពអត់ការងារធ្វើអាចបង្កជាទុក្ខសោកដល់មនុស្ស ដោយសារបញ្ហាហិរញ្ញវត្ថុក្នុងគ្រួសារ ការបាត់បង់ការគោរពពីអ្នកដទៃ និងការកើនឡើងនៃឧក្រិដ្ឋកម្មក្នុងសង្គម។ ដូច្នេះហើយបានជាគោលនយោបាយរូបិយវត្ថុត្រូវបានកំណត់ក្នុងគោលដៅលើកកម្ពស់ភាពមានការងារធ្វើនៅក្នុងសេដ្ឋកិច្ច។
- **កំណើនសេដ្ឋកិច្ច (Economic Growth)៖** កំណើនសេដ្ឋកិច្ចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងគោលដៅកម្រិតខ្ពស់នៃភាពមានការងារធ្វើ ដោយសារនៅពេលអត្រានិកម្មភាពមានកម្រិតទាប នោះវិនិយោគិននឹងមកវិនិយោគដើម្បីបង្កើនលទ្ធភាពផលិតដែលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ប៉ុន្តែប្រសិនបើអត្រានិកម្មភាពមានកម្រិតខ្ពស់ ហើយរោងចក្រជាច្រើនមានសភាពទំនេរ នោះវិនិយោគិនក៏មិនសម្រេចចិត្តវិនិយោគផងដែរ។ ដូចនេះ នៅពេល

ធនាគារកណ្តាលមានបំណងចង់ជំរុញកំណើនសេដ្ឋកិច្ច ធនាគារកណ្តាលអាចដាក់ចេញគោលនយោបាយរូបិយវត្ថុដែលលើកទឹកចិត្តដោយផ្ទាល់ដល់ក្រុមហ៊ុនឱ្យវិនិយោគបន្ថែម ឬលើកទឹកចិត្តដល់សាធារណជនឱ្យដាក់សន្សំ ដើម្បីអាចអនុញ្ញាតឱ្យធនាគារមានមូលនិធិគ្រប់គ្រាន់សម្រាប់ផ្តល់ហិរញ្ញប្បទានទៅឱ្យក្រុមហ៊ុនដើម្បីវិនិយោគ។

- **ស្ថិរភាពទីផ្សារហិរញ្ញវត្ថុ** (Financial Market Stability)៖ ទីផ្សារហិរញ្ញវត្ថុ គឺជាកម្លាំងជំរុញមួយដ៏សំខាន់សម្រាប់សេដ្ឋកិច្ច ដោយដើរតួនាទីជាអន្តរការីដែលកៀរគរមូលនិធិពីអ្នកដែលមានអតិរេកមូលធន (មានមូលធនលើស) ទៅឱ្យអ្នកដែលមានឱនភាពមូលធន (មានកង្វះមូលធន) ដើម្បីជំរុញការវិនិយោគនិងសកម្មភាពសេដ្ឋកិច្ច។ ដូច្នេះ ការលើកកម្ពស់ស្ថិរភាពទីផ្សារហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ ក្នុងការបញ្ចៀសវិបត្តិហិរញ្ញវត្ថុដែលអាចប៉ះពាល់ដល់បណ្តាញលំហូរមូលធនទៅកាន់អ្នកដែលត្រូវការដើមទុនសម្រាប់វិនិយោគ សុខភាពប្រព័ន្ធហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច។
- **ស្ថិរភាពអត្រាការប្រាក់** (Interest Rate Stability)៖ ការប្រែប្រួលអត្រាការប្រាក់ជាញឹកញាប់អាចបង្កើតឱ្យមានភាពមិនប្រាកដប្រជានៅក្នុងសេដ្ឋកិច្ច ដែលអាចនាំឱ្យភ្នាក់ងារសេដ្ឋកិច្ចពិបាកក្នុងការសម្រេចចិត្តនិងរៀបចំផែនការអនាគត។ ឧទាហរណ៍ បុគ្គលម្នាក់ដែលមានបំណងចង់ទិញផ្ទះអាចស្ទាក់ស្ទើរក្នុងការសម្រេចចិត្តខ្ចីប្រាក់ពីធនាគារ ដោយសារភាពមិនប្រាកដប្រជានៃអត្រាការប្រាក់ រីឯក្រុមហ៊ុនវិញក៏មានការពិបាកក្នុងការរៀបចំផែនការវិនិយោគដោយសារភាពមិនច្បាស់លាស់នេះផងដែរ។ ដូចនេះ ធនាគារជាតិនៃកម្ពុជាមានតួនាទីដាក់ចេញគោលនយោបាយរូបិយវត្ថុដើម្បីធានាឱ្យបាននូវស្ថិរភាពអត្រាការប្រាក់ ដើម្បីសម្រួលដល់សកម្មភាពឥណទាន ព្រមទាំងជំរុញការវិនិយោគនិងការប្រើប្រាស់នៅក្នុងសេដ្ឋកិច្ច។
- **ស្ថិរភាពអត្រាប្តូរប្រាក់** (Exchange Rate Stability)៖ អត្រាប្តូរប្រាក់ដើរតួនាទីយ៉ាងសំខាន់នៅក្នុងពាណិជ្ជកម្មអន្តរជាតិ។ ការកើនឡើងនៃតម្លៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណផ្សេងៗអាចប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់សហគ្រាស-ក្រុមហ៊ុនកម្ពុជា ដែលនាំចេញផលិតផលទៅក្រៅប្រទេស ដោយផលិតផលកម្ពុជានឹងមានតម្លៃថ្លៃជាងផលិតផលប្រទេសដទៃ ដែលនាំឱ្យក្រុមហ៊ុនទាំងនោះអាចជួបនឹងវិបត្តិ។ ផ្ទុយមកវិញ បើតម្លៃប្រាក់រៀលធ្លាក់ចុះធៀបនឹងរូបិយប័ណ្ណផ្សេងៗ នោះផលិតផលនាំចេញរបស់កម្ពុជានឹងមានលទ្ធភាពប្រកួតប្រជែងជាងផលិតផលដទៃ ដែលអាចឱ្យប្រទេសកម្ពុជានាំចេញបានច្រើនជាងមុន ប៉ុន្តែផលិតផលនាំចូលនឹងមានតម្លៃថ្លៃជាងមុន (អតិផរណា) ហើយក្នុងរយៈពេលវែង ប្រសិនបើវត្ថុធាតុដើមត្រូវបាន

នាំចូលពីបរទេស នោះវានឹងអាចបង្កជាការលំបាកដល់ក្រុមហ៊ុនក្នុងស្រុកផងដែរ។ ហេតុដូចនេះ ការរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់នឹងជួយដល់តុល្យភាពនៃជញ្ជីងពាណិជ្ជកម្ម និងលើកកម្ពស់ការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងសេដ្ឋកិច្ច។

### ២.៦.២. ប្រភេទនៃគោលនយោបាយរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុ ត្រូវបានបែងចែកជាពីរប្រភេទធំៗគឺ៖

- **គោលនយោបាយរូបិយវត្ថុវិត្ថារកម្ម ឬ ពង្រីក** (Expansionary Monetary Policy)៖ ជាគោលនយោបាយរូបិយវត្ថុអនុវត្ត នៅពេលដែលធនាគារជាតិនៃកម្ពុជាមានបំណងចង់ជំរុញការវិនិយោគ ភាពមានការងារធ្វើ និងកំណើនសេដ្ឋកិច្ច ដោយការចាក់បញ្ចូលបរិមាណផ្គត់ផ្គង់រូបិយវត្ថុទៅក្នុងទីផ្សារ តាមរយៈការបញ្ចុះអត្រាការប្រាក់គោល ការបន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ច និងការទិញមូលបត្រក្នុងប្រតិបត្តិការទីផ្សារចំហ។
- **គោលនយោបាយរូបិយវត្ថុរឹតត្បិត** (Contractionary Monetary Policy)៖ ជាគោលនយោបាយរូបិយវត្ថុអនុវត្តនៅពេលដែលសេដ្ឋកិច្ចកំពុងមានកម្តៅខ្លាំង (Overheating) ដែលទាមទារឱ្យមានការស្រូបយកបរិមាណផ្គត់ផ្គង់រូបិយវត្ថុពីទីផ្សារ ដោយការដំឡើងអត្រាការប្រាក់គោល ការដំឡើងអត្រាប្រាក់បម្រុងកាតព្វកិច្ច និងការលក់មូលបត្រក្នុងប្រតិបត្តិការទីផ្សារចំហរ។ គោលបំណងនៃការអនុវត្តគោលនយោបាយបែបនេះ គឺដើម្បីកាត់បន្ថយអតិផរណាឱ្យនៅកម្រិតសមស្រប និងពង្រឹងថ្លៃប្រាក់រៀល។

### ២.៦.៣. ឧបករណ៍គោលនយោបាយរូបិយវត្ថុ

ឧបករណ៍គោលនយោបាយរូបិយវត្ថុ គឺជាឧបករណ៍ដែលធនាគារជាតិនៃកម្ពុជាប្រើប្រាស់ដើម្បីមានឥទ្ធិពលទៅលើតម្រូវការនិងបរិមាណផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច សំដៅសម្រេចគោលដៅនៃគោលនយោបាយរូបិយវត្ថុ។ ដើម្បីឱ្យស្របទៅតាមស្ថានភាពនិងបរិការណ៍សេដ្ឋកិច្ចកម្ពុជាដែលមានលក្ខណៈខុសពីសេដ្ឋកិច្ចប្រទេសដទៃ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបានប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុចំនួនបួន គឺ ប្រាក់បម្រុងកាតព្វកិច្ច ការធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ មូលបត្រអាចជួញដូរបាន និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា។

### ២.៦.៣.១. ប្រាក់បម្រុងកាតព្វកិច្ច (Reserve Requirements)៖

ប្រាក់បម្រុងកាតព្វកិច្ច គឺជាប្រាក់បម្រុងមួយផ្នែកដែលគ្រឹះស្ថានធនាគាររក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដើម្បីការពារហានិភ័យសន្ទនីយភាពក្នុងពេលដែលអតិថិជនមកដកប្រាក់ក្នុងពេលតែមួយ។ ជាទូទៅ ទំហំប្រាក់បម្រុងកាតព្វកិច្ចត្រូវបានគណនាដោយប្រើអត្រាប្រាក់បម្រុងកាតព្វកិច្ចធៀបនឹងចំនួនប្រាក់បញ្ញើសរុបនិងកម្ចីផ្សេងៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ អត្រាប្រាក់បម្រុងកាតព្វកិច្ច គឺជាអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជាប្រើសម្រាប់គណនាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលត្រូវរក្សាទុកជាមធ្យមក្នុងរយៈពេលតម្កល់ (រយៈពេល១៤ថ្ងៃប្រតិទិនបន្តបន្ទាប់) ដោយកំណត់យកពីប្រាក់បញ្ញើនិងកម្ចីផ្សេងៗរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលបំណងធានានូវការគ្រប់គ្រងសន្ទនីយភាពប្រកបដោយសុវត្ថិភាពនិងភាពរឹងមាំ ព្រមទាំងរួមចំណែកការពារប្រព័ន្ធធនាគារនៅពេលមានហានិភ័យសន្ទនីយភាពដែលអាចកើតឡើងជាយថាហេតុ។

**ការគណនាប្រាក់បម្រុងកាតព្វកិច្ច៖**

**ប្រាក់បម្រុងកាតព្វកិច្ច = អត្រាប្រាក់បម្រុងកាតព្វកិច្ច x ប្រាក់បញ្ញើសរុប**

ការដំឡើងឬទម្លាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច នឹងមានឥទ្ធិពលដល់បរិមាណផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងប្រព័ន្ធធនាគារ ដែលជាលទ្ធផលធ្វើឱ្យអត្រាការប្រាក់និងអតិផរណាប្រែប្រួល។ លើសពីនេះ អត្រាប្រាក់បម្រុងកាតព្វកិច្ចមិនត្រឹមតែជាឧបករណ៍គោលនយោបាយរូបិយវត្ថុប៉ុណ្ណោះទេ តែថែមទាំងជាឧបករណ៍គោលនយោបាយម៉ាក្រូប្រុងប្រយ័ត្ន ដែលត្រូវបានប្រើសម្រាប់កាត់បន្ថយហានិភ័យហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ។ អត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលត្រូវបានកំណត់ទាបជាងអត្រាជារូបិយប័ណ្ណ ដើម្បីលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យរក្សាប្រាក់បម្រុងជាប្រាក់រៀល សំដៅរួមចំណែកលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ បច្ចុប្បន្ន អត្រាប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀលមានកម្រិត ៨% និងជារូបិយប័ណ្ណមានកម្រិត ១២,៥% សំដៅលើកទឹកចិត្តនិងជំរុញគ្រឹះស្ថានធនាគារឱ្យកេណ្ឌប្រមូលប្រាក់បញ្ញើ និងផ្តល់ឥណទានជាប្រាក់រៀល ព្រមទាំងរួមចំណែកការពារប្រព័ន្ធធនាគារ នៅពេលមានហានិភ័យសន្ទនីយភាពដែលអាចកើតឡើងជាយថាហេតុ។ ប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ ៤,៥% ត្រូវទទួលបានអត្រាការប្រាក់ ១/២ នៃអត្រាអន្តរធនាគារនៃទីក្រុងឡុងដ៍ (London Interbank Offered Rate –LIBOR) គិតលើមូលដ្ឋាន១ខែ។ ដូច្នេះ ឧបករណ៍នេះមិនមានលក្ខណៈសកម្មក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុទេ។ ម៉្យាងទៀត

អត្រាប្រាក់បម្រុងកាតព្វកិច្ចពុំត្រូវបានផ្លាស់ប្តូរញឹកញាប់នោះទេ ដោយសារការដំឡើងឬបន្ថយអត្រានេះអាចប៉ះពាល់ដល់ដំណើរការអាជីវកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ព្រោះគ្រឹះស្ថានទាំងនេះត្រូវធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រនិងផែនការអាជីវកម្មរបស់ពួកគេ ដើម្បីអនុលោមទៅតាមការកំណត់របស់ធនាគារជាតិនៃកម្ពុជា។

ក្នុងអំឡុងវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៧-២០០៨ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានដំឡើងពី ៨% ទៅ ១៦% ចំពោះរូបិយប័ណ្ណ ដើម្បីរឹតត្បិតកម្រិតសន្ទនីយភាពនៅក្នុងសេដ្ឋកិច្ចក្នុងបរិការណ៍ដែលកំណើនឥណទាននិងអត្រាអតិផរណាមានកម្រិតខ្ពស់។ បន្ទាប់មក នៅខែមករា ឆ្នាំ២០០៩ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានបន្ថយមកត្រឹម ១២% វិញ ដើម្បីគាំទ្រកំណើនសេដ្ឋកិច្ចនិងបន្ទាប់ពីស្ថានភាពអតិផរណាចាប់ផ្តើមមានភាពប្រសើរឡើងវិញ។ តាមរយៈការបន្តមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្រោយពីឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុសកល និងក្នុងគោលដៅបន្តពង្រឹងការប្រើប្រាស់រូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជា បានសម្រេចដំឡើងអត្រាប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រូបិយប័ណ្ណបន្តិចវិញដោយមានកម្រិត ១២,៥% ចាប់ពីខែកញ្ញា ឆ្នាំ២០១២ រហូតមកទល់បច្ចុប្បន្ន។ ចំណែកឯអត្រាប្រាក់បម្រុងកាតព្វកិច្ចជាប្រាក់រៀលត្រូវបានរក្សានៅកម្រិត ៨% ដោយពុំមានការប្រែប្រួល។ម្យ៉ាងទៀត ក្រោយពីសង្កេតឃើញថា កំណើនឥណទាននិងលំហូរចូលនៃប្រភពទុនពីបរទេសបានកើនឡើងគួរកត់សម្គាល់ ដែលកំណើនទាំងនេះបានភ្ជាប់ជាមួយនូវហានិភ័យចំពោះវិស័យធនាគារក៏ដូចជាវិស័យហិរញ្ញវត្ថុទាំងមូល ធនាគារជាតិនៃកម្ពុជាបានសម្រេចអនុវត្តការដាក់ប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់កម្ចីអនិវាសជន ចាប់ពីខែមេសា ឆ្នាំ២០១៥ មក ដោយមានអត្រា ១២,៥% ដូចទៅនឹងប្រាក់បញ្ញើជារូបិយប័ណ្ណផងដែរ ដើម្បីផ្តល់សញ្ញាពីកំណើនខ្ពស់នៃឥណទាន សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុនិងគាំទ្រកំណើនប្រកបដោយចីរភាព។

## ២.៦.៣.២. ការធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

នៅក្នុងបរិការណ៍សេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់គឺកត្តាមួយដ៏ចម្បងក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ។ ដូចនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់យ៉ាងប្រុងប្រយ័ត្នដើម្បីផ្គត់ផ្គង់ប្រាក់រៀលស្របតាមតម្រូវការទីផ្សារ។ ការកើនឡើងនូវជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល បានធ្វើឱ្យប្រាក់រៀលត្រូវបានប្រើប្រាស់កាន់តែច្រើនក្នុងសកម្មភាពអាជីវកម្ម និងជីវភាពប្រចាំថ្ងៃ។ ឆ្លើយតបនឹងកំណើនតម្រូវការនេះ និងដើម្បីរក្សាស្ថិរភាព

អត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ តាមរយៈការលក់ប្រាក់រៀលដល់ទីផ្សារដែលបច្ចុប្បន្នមានតួអង្គចម្បងពីរ គឺគ្រឹះស្ថានធនាគារ និងអាជីវករប្តូរប្រាក់។

លើសពីនេះ អន្តរាគមន៍នេះបានផ្តល់សន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុសម្រាប់ធ្វើប្រតិបត្តិការប្រចាំថ្ងៃ ជាពិសេស ការផ្តល់ឥណទានជាប្រាក់រៀល ដោយបានស្រូបយកប្រាក់ដុល្លារអាមេរិកពីសេដ្ឋកិច្ចកម្ពុជា។ ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់ទៅតាមគោលដៅដែលបានកំណត់ ធនាគារជាតិនៃកម្ពុជាកំណត់អត្រាប្តូរប្រាក់ផ្លូវការ ដែលជាអត្រាទិញ-លក់រវាងរូបិយវត្ថុជាតិ និងរូបិយប័ណ្ណបរទេសផ្សេងទៀត និងដាក់ឱ្យប្រើប្រាស់សម្រាប់រាល់ប្រតិបត្តិការរវាងធនាគារជាតិនៃកម្ពុជាជាមួយនឹងភាគីពាក់ព័ន្ធ។ មិនតែប៉ុណ្ណោះ ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាសាធារណជន អាចប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការនេះទៅតាមគោលដៅរៀងៗខ្លួន ហើយអត្រានេះក៏ជាអត្រាប្តូរប្រាក់គោលប្រើដោយវិស័យឯកជនផងដែរ។ សរុបរួមមក ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីគ្រប់គ្រងឱ្យបាននូវកម្រិតសមស្របនៃការផ្គត់ផ្គង់រូបិយវត្ថុក្នុងចរាចរណ៍ សំដៅរក្សាស្ថិរភាពថ្លៃនិងជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។

### ២.៦.៣.៣. មូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposit –NCD)

ក្នុងគោលដៅជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារនិងរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយជាផ្លូវការនូវមូលបត្រអាចជួញដូរបាន នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៣ ដើម្បីអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុប្រើប្រាស់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការអន្តរធនាគារ។ មូលបត្រអាចជួញដូរបាន គឺជាប័ណ្ណបំណុលរយៈពេលខ្លីមានការប្រាក់ ដែលបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា។ មូលបត្រនេះត្រូវបានចេញផ្សាយជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ដើម្បីជួយដល់បណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការវិនិយោគសន្ទនីយភាពរយៈពេលខ្លីរបស់ខ្លួន។ ការអនុវត្តកន្លងមកបានបង្ហាញថា ការចេញផ្សាយ NCDs បានស្រូបយកសន្ទនីយភាពទាំងជាដុល្លារអាមេរិកនិងជារៀលពីគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ។

ក្រោយពេលដែលធនាគារជាតិនៃកម្ពុជាបានចេញផ្សាយ NCD តម្រូវការនៅលើទីផ្សារមានកម្រិតទាបនៅឡើយ ដោយសារមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនប៉ុណ្ណោះបានប្រើប្រាស់ NCD ក្នុងការគ្រប់គ្រងសន្ទនីយភាពដែលនៅសល់។ ដើម្បីជំរុញតម្រូវការ NCD នៅលើទីផ្សារ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការជាបន្តបន្ទាប់ដូចខាងក្រោម៖

- ដំឡើងអត្រាការប្រាក់ NCD ពី ១/២ ទៅ ៣/៤ នៃអត្រា LIBOR
- ទទួលទិញ NCD មកវិញក្នុងអត្រាអប្បហារ (Discount Rate)
- កាត់បន្ថយតម្លៃចារឹកនៃ NCD ពី ២ប៊ីលានរៀល មក ២០០លានរៀល សម្រាប់ NCD ចារឹកជាប្រាក់រៀល និងពី ៥០០ពាន់ដុល្លារអាមេរិក មក ៥០ពាន់ដុល្លារអាមេរិក សម្រាប់ NCD ចារឹកជាប្រាក់ដុល្លារអាមេរិក
- បញ្ឈប់ការទទួលប្រាក់បញ្ញើមានកាលកំណត់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលដាក់នៅធនាគារជាតិនៃកម្ពុជាចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ និង
- អភិវឌ្ឍប្រព័ន្ធ Online Trading Platform ដើម្បីជំរុញឱ្យមានប្រតិបត្តិការជួញដូរមូលបត្រអាចជួញដូរបាននៅលើទីផ្សារបន្ទាប់។ ការអភិវឌ្ឍនេះត្រូវបានចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលទី១ ដែលអ្នកចូលរួមអាចតាមដានពីសមតុល្យ និងឥណប្រតិទាននៃមូលបត្រអាចជួញដូរបាន និងដំណាក់កាលទី២ ដែលអនុញ្ញាតឱ្យអ្នកចូលរួមអាចដាក់លក់មូលបត្រដែលបានទិញទៅឱ្យធនាគារផ្សេងៗ និងអាចស្វែងរកទិញមូលបត្រដែលធនាគារផ្សេងដាក់លក់ផងដែរ។

ដើម្បីបន្តអភិវឌ្ឍ NCD ឱ្យក្លាយជាឧបករណ៍គ្រប់គ្រងសន្ទនីយភាពកាន់តែមានប្រសិទ្ធភាព និងមានភាពទាក់ទាញសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានកែប្រែឥណប្រតិទាន NCD ដោយផ្អែកលើមូលដ្ឋានសប្តាហ៍ ៧ថ្ងៃ ១៤ថ្ងៃ ២៨ថ្ងៃ ៩១ថ្ងៃ ១៨២ថ្ងៃ និងបង្កើនឥណប្រតិទាននៃ NCD ដែលចេញផ្សាយរហូតដល់ ៣៦៤ ថ្ងៃ។ ការផ្លាស់ប្តូរនេះក៏ដើម្បីឱ្យ NCD មានឥណប្រតិទានសមស្របនិងគ្រប់គ្រាន់ក្នុងការដាក់ជាវត្ថុធានាសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាដែលមានរយៈពេល ១ឆ្នាំ។

យោងទៅលើស្ថានភាពនៃការវិវត្តនៃទីផ្សារ ធនាគារជាតិនៃកម្ពុជាបានសម្រេចកំណត់អត្រាការប្រាក់ NCD ចារឹកជាដុល្លារអាមេរិកដែលមានឥណប្រតិទានរយៈពេលខ្លីទាបជាងមុនដើម្បីលើកទឹកចិត្តគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ងាកទៅវិនិយោគសន្ទនីយភាពដែលនៅសល់ក្នុងទីផ្សារអន្តរធនាគារវិញ។ អត្រាការប្រាក់ NCD ចារឹកជាដុល្លារអាមេរិកត្រូវបានគណនាដោយប្រើប្រាស់អត្រា LIBOR ជាគោល។ រីឯអត្រាការប្រាក់ NCD ចារឹកជាប្រាក់រៀលត្រូវបានកំណត់ឱ្យមានការប្រែប្រួលតាមមេគុណប្រាប់ទិស (Slope) របស់ LIBOR។

### ២.៦.៣.៤. ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity-Providing Collateralized Operation –LPCO)

ក្នុងគោលដៅរួមចំណែកអភិវឌ្ឍទីផ្សារអន្តរធនាគារ ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនិងការធ្វើអន្តរការិយកម្មរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលខ្វះសន្ទនីយភាព និងគ្រឹះស្ថានដែលមានសន្ទនីយភាពលើស ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រតិបត្តិការផ្តល់សន្ទនីយភាពជាប្រាក់រៀលដោយមានការប្រើប្រាស់មូលបត្រអាចជួញដូរបានជាវត្ថុធានា នៅខែតុលា ឆ្នាំ២០១៦។ ប្រតិបត្តិការ LPCO បានទទួលការសាទរនិងគាំទ្រពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ប៉ុន្តែដោយសារប្រតិបត្តិការនេះកំពុងស្ថិតនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅឡើយ ការចូលរួមរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅមានកម្រិត ដែលទាមទារឱ្យមានការអភិវឌ្ឍនិងពេលវេលាបន្ថែមសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការស្វែងយល់ឱ្យបានស៊ីជម្រៅ និងអាចអនុវត្តប្រកបដោយប្រសិទ្ធភាព។

**រូបភាពទី១០៖ ការស្រូបយកនិងផ្តល់សន្ទនីយភាពតាមរយៈមូលបត្រអាចជួញដូរបាន និង ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា**




ប្រតិបត្តិការនេះត្រូវបានធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម៖

- បង្កើតឱ្យមានអត្រាការប្រាក់គោល (Benchmark Rate) សម្រាប់ទីផ្សារអន្តរធនាគារ ដើម្បីបម្រើដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ

- ជំរុញតម្រូវការ NCDs ដែលជាឧបករណ៍ធានាក្នុងទីផ្សារអន្តរធនាគារ
- ជំរុញការប្រើប្រាស់ប្រាក់រៀល ស្របតាមគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលដោយសារៈ i/- ប្រតិបត្តិការ LPCO ផ្តល់សន្ទនីយភាពជាប្រាក់រៀលដែលផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ផ្តល់ឥណទានជាប្រាក់រៀលកាន់តែច្រើនជាងមុន និង ii/- ផ្តល់លទ្ធភាពឱ្យធនាគារជាតិនៃកម្ពុជាស្រូបយកប្រាក់ដុល្លារអាមេរិកពីក្នុងទីផ្សារតាមរយៈការប្រើប្រាស់ NCDs ជាពិសេស NCDs ចារិកជាប្រាក់ដុល្លារអាមេរិកសម្រាប់ការដាក់ធានា
- ផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុត្រៀមខ្លួន ក្នុងការបង្កើនប្រតិបត្តិការជាប្រាក់រៀលសម្រាប់ពេលខាងមុខ ដោយសារធនាគារជាតិនៃកម្ពុជាអាចនឹងតម្រូវឱ្យគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុធ្វើប្រតិបត្តិការជាប្រាក់រៀល (ឧទាហរណ៍ ការផ្តល់ឥណទាន) ក្នុងកម្រិតណាមួយ (ឧទាហរណ៍ ១០% នៃសំពៀតឥណទានសរុប)
- ជួយគាំទ្រវិស័យកសិកម្ម ជាពិសេសក្នុងស្ថានភាពថ្មីៗនេះដែលវិស័យកសិកម្មកំពុងតែមានតម្រូវការមូលនិធិដើម្បីប្រមូលទិញកសិផល។ ដោយប្រាក់រៀលត្រូវបានប្រើប្រាស់ច្រើនបំផុតក្នុងវិស័យកសិកម្ម ដូច្នេះ ការផ្តល់សន្ទនីយភាពជាប្រាក់រៀលនឹងគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម និង
- រួមចំណែកបន្ទាបអត្រាការប្រាក់ជារៀលដែលកំពុងស្ថិតនៅក្នុងកម្រិតខ្ពស់នាពេលបច្ចុប្បន្ន។

តាមរយៈការសិក្សាបឋមរបស់ធនាគារជាតិនៃកម្ពុជាលើប្រតិបត្តិការ LPCO បានបង្ហាញថាប្រតិបត្តិការ LPCO មានសារៈសំខាន់ដូចជា៖

**១/- កាត់បន្ថយថ្លៃដើមមូលនិធិ៖** មុនពេលដែលប្រតិបត្តិការ LPCO ត្រូវបានដាក់ឱ្យដំណើរការ គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដែលមានតម្រូវការមូលនិធិជារៀល បានចុះកិច្ចព្រមព្រៀងដើម្បីទទួលបានប្រភពមូលនិធិពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងស្រុកមួយផ្នែក និងដៃគូអន្តរជាតិមួយផ្នែកទៀត។ ប៉ុន្តែមូលនិធិដែលទទួលបានពីប្រភពទាំងពីរនេះមានកម្រិតនិងមានតម្លៃខ្ពស់ ព្រមទាំងមានលក្ខណៈប្រមូលផ្តុំ

**២/- បង្កើនសន្ទនីយភាពជារៀល៖** ប្រតិបត្តិការ LPCO បានបង្កើនសន្ទនីយភាពជារៀលដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការប្រាក់រៀលដែលបន្តកើនឡើងក្នុងសេដ្ឋកិច្ច ក៏ដូចជាផ្តល់លទ្ធភាពដល់គ្រឹះស្ថានដែលមានបំណងបង្កើនសំពៀតឥណទានជារៀល ជាពិសេសទៅកាន់វិស័យកសិកម្ម និង

**៣/- កាត់បន្ថយគម្លាតរវាងអត្រាការប្រាក់កម្ចីជាប្រាក់រៀលនិងដុល្លារអាមេរិក៖** បច្ចុប្បន្ន ឥណទានជារៀលដែលគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុផ្តល់ដល់អតិថិជន មានអត្រាការប្រាក់ខ្ពស់ជាងឥណទានជាប្រាក់ដុល្លារអាមេរិក ដោយសារហេតុផលមួយចំនួន ដែលក្នុងនោះក៏មានការលើកឡើងពីកង្វះប្រភពមូលនិធិជាប្រាក់រៀល។ ដូច្នេះការដាក់ឱ្យដំណើរការប្រតិបត្តិការ LPCO នេះបានជួយបង្កើនប្រភពមូលនិធិជាប្រាក់រៀលនៅក្នុងសេដ្ឋកិច្ច និងបានរួមចំណែកកាត់បន្ថយគម្លាតរវាងអត្រាការប្រាក់កម្ចីជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកឱ្យកាន់តែមានកម្រិតតូច។

ដើម្បីបន្តអភិវឌ្ឍប្រតិបត្តិការ LPCO ឱ្យកាន់តែប្រសើរនិងមានភាពទាក់ទាញសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានកែប្រែលក្ខខណ្ឌមួយចំនួនរបស់ប្រតិបត្តិការនេះ និងបានបង្កើនឥណប្រតិទានរហូតដល់ ១ឆ្នាំ។

# ជំពូកទី៣

# ឥទ្ធិពលនៃដុល្លារូបនីយកម្ម

# មកលើសេដ្ឋកិច្ចកម្ពុជា

# ជំពូកទី៣

# ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

## ៣.១. ការកើតនិងមូលហេតុនៃដុល្លារូបនីយកម្មនៅកម្ពុជា

ដុល្លារូបនីយកម្មនៅកម្ពុជាចាប់ផ្តើមពីវិបត្តិ បទពិសោធន៍ និងព្រឹត្តិការណ៍មួយចំនួនដែលធ្វើឱ្យរង្គោះរង្គើជំនឿទុកចិត្តរបស់សាធារណជនមកលើសមត្ថភាពរបស់អាជ្ញាធរ ក្នុងការរក្សាតម្លៃរូបិយវត្ថុជាតិ "ប្រាក់រៀល"។ ជាការពិត ប្រាក់ដុល្លារអាមេរិកបានចាប់ផ្តើមចរាចរណ៍នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីក្នុងអំឡុងរបបសាធារណរដ្ឋខ្មែររបស់លោកឧត្តមសេនីយ៍ លន់ នល់ មកម្ល៉េះ (ឆ្នាំ១៩៧០-១៩៧៥) ប៉ុន្តែប្រាក់រៀលនៅតែជារូបិយវត្ថុដែលត្រូវបានប្រើប្រាស់ជាទូទៅចំពោះប្រតិបត្តិការទូទាត់ក្នុងស្រុក។ វិបត្តិដំបូងបានកើតឡើងពីឆ្នាំ១៩៧៥-១៩៧៩ នៅពេលដែលគ្រប់ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ដែលរួមមាន ទីផ្សារ ពាណិជ្ជកម្ម ក្រដាសប្រាក់ ប្រព័ន្ធធនាគារត្រូវបានបំផ្លាញចោលទាំងស្រុង។ ក្រោមការដឹកនាំរបស់របបប៉ុលពត ប្រព័ន្ធរូបិយវត្ថុត្រូវបានបំបាត់ចោលទាំងស្រុង ហើយប្រជាជនទាំងអស់ក៏ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញដើម្បីទៅធ្វើស្រែចម្ការនៅតាមខេត្តវិញ។

ប្រវត្តិនៃការបង្កើតរូបិយវត្ថុជាតិនៅកម្ពុជាមានរយៈពេលខ្លី បើធៀបនឹងប្រទេសនានា នៅក្នុងពិភពលោកនិងតំបន់។ ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូងនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៥៤ ហើយរូបិយវត្ថុជាតិ "ប្រាក់រៀល" ក៏ត្រូវបានបង្កើតឡើងផងដែរ នៅឆ្នាំ១៩៥៥។ ប្រជាជនកម្ពុជាបានទទួលស្គាល់យ៉ាងទូលំទូលាយលើប្រាក់រៀលក្រោយពីការដាក់ឱ្យចរាចរ ក៏ប៉ុន្តែជំនឿទុកចិត្តលើប្រាក់រៀលត្រូវបានបំផ្លាញទាំងស្រុងនៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ដែលអូសបន្លាយអស់រយៈពេលជិត៣០ឆ្នាំ។

បន្ទាប់ពីមានរដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០ កម្ពុជាបានធ្លាក់ក្នុងអស្ថិរភាពនយោបាយ និងសេដ្ឋកិច្ចដែលធ្វើឱ្យសាធារណជនបាត់បង់ជំនឿទុកចិត្តទៅលើរដ្ឋាភិបាល សេដ្ឋកិច្ច និងរូបិយវត្ថុជាតិ។ សង្គ្រាមបានកើតឡើងនៅគ្រប់ទីកន្លែង ប្រទេសកម្ពុជាបានទទួលរងការបំផ្លិចបំផ្លាញ ហើយផលិតកម្មបានថយចុះជាលំដាប់។ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដុនដាបជាខ្លាំង ប្រទេសទាំងមូលត្រូវពឹងផ្អែកលើជំនួយបរទេស។ អតិផរណាបានកើនឡើងកាន់តែខ្លាំងឡើងៗដោយសារកង្វះការផ្គត់ផ្គង់ក្នុងស្រុក ហើយថវិការដ្ឋត្រូវបំពេញបន្ថែមដោយបុរេប្រទានពីធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជានាពេលនោះបានបោះពុម្ពប្រាក់ជាច្រើនបន្ថែម ដើម្បីបំពេញឱនភាពថវិការដ្ឋ ជាពិសេស

សម្រាប់ការបើកប្រាក់បៀវត្សជូនមន្ត្រីរដ្ឋ។ យោងតាមការសិក្សាលើអតិផរណាសម័យនោះបង្ហាញថា ថ្លៃទំនិញនានាបានឡើងថ្លៃជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស ឧទាហរណ៍ ដូចជា ថ្លៃគុយទាវមួយចាន ដែលមានតម្លៃ ៥០រៀល បានឡើងថ្លៃដល់ ៥០០រៀល រួចឡើងដល់ ១.០០០រៀល ហើយថ្លៃមេជ្រូកមួយបានឡើងថ្លៃដល់ ១លានរៀល គឺស្មើនឹងប្រាក់បៀវត្សមន្ត្រីថ្នាក់មធ្យមម្នាក់ក្នុងរយៈពេលពីរឆ្នាំ។ ភាពមិនច្បាស់លាស់នៃស្ថានភាពនយោបាយ និងអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចទាំងក្នុងនិងក្រៅប្រទេស (កំណើនអត្រាអតិផរណា ឱនភាពថវិការដ្ឋ កំណើនការនាំចូល និងការធ្លាក់ចុះនៃផលិតកម្មក្នុងស្រុក។ល។) បានធ្វើឱ្យប្រជាជនបាត់បង់ជំនឿទុកចិត្តយ៉ាងខ្លាំងទៅលើប្រាក់រៀល។ គួរកត់សម្គាល់ថា នៅក្នុងសម័យ លន់ នល់ ប្រាក់ដុល្លារអាមេរិកបានហូរចូលកាន់តែច្រើនតាមរយៈជំនួយអាមេរិក ហើយការរក្សាទុកនិងប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ត្រូវបានគេសង្កេតឃើញមាននៅក្នុងមជ្ឈដ្ឋានអ្នកមានបុព្វសិទ្ធិដែលស្ថិតនៅក្បែរអ្នកកាន់អំណាច ឈ្មួញរកស៊ីលួចលាក់ក្នុងសង្គ្រាម និងអ្នកទទួលផលពីជំនួយរបស់អាមេរិក។ លើសពីនេះ រូបិយវត្ថុជាតិត្រូវបានបាត់បង់ទាំងស្រុងក្នុងសម័យ ប៉ុល ពត (១៩៧៥-១៩៧៩)។ សង្គមទាំងមូលត្រូវបានប្រែក្លាយទៅជាសង្គមទាសភាព គ្មានកម្មសិទ្ធិឯកជន គ្មានទីផ្សារ គ្មានរូបិយវត្ថុ និងគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់។ បទពិសោធន៍ដ៏ខ្លោចផ្សាទាំងនេះ គឺជាឫសគល់ចម្បងនៃការបាត់បង់ជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិមកដល់សព្វថ្ងៃ។

ដំបូង ការដឹកនាំរបស់ខ្មែរក្រហមមានចេតនាបោះផ្សាយរូបិយវត្ថុ និងបង្កើតប្រព័ន្ធធនាគារតាមរបៀបពួកគេ។ នៅខែមករា ឆ្នាំ១៩៧៥ ក្រដាសប្រាក់ថ្មីដែលបោះពុម្ពនៅប្រទេសចិន ត្រូវបានដឹកជញ្ជូនតាមផ្លូវលំហូជីមិញ។ នៅខែឧសភា ឆ្នាំ១៩៧៥ ប្រាក់រៀលត្រូវបានសម្រេចដាក់ក្នុងចរាចរណ៍ជាបណ្តើរៗ។ ការផ្គត់ផ្គង់សាច់ប្រាក់បានបញ្ជូនដល់បណ្តាខេត្ត នៅខែសីហា ឆ្នាំ១៩៧៥ ហើយរូបិយវត្ថុថ្មីត្រូវបានដាក់ឱ្យចរាចរជាផ្លូវការក្នុងតំបន់ភាគខាងជើង និងភាគពាយ័ព្យនៃខេត្តកំពង់ចាម។ ប៉ុន្តែ គណៈកម្មាធិការកណ្តាល និង ប៉ុល ពត បានពិចារណាថា ការប្រើប្រាស់ក្រដាសប្រាក់ឬមិនប្រើ មានពាក់ព័ន្ធទៅនឹងខ្លឹមសារនៃរបបប៉ុលពត។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជា បានសម្រេចមិនបោះផ្សាយរូបិយវត្ថុថ្មីទេ។ ការសម្រេចនេះត្រូវបានប្រកាស ៤ខែក្រោយនៅក្នុងសន្និបាតគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជាលើកទី៤។[20] ការបំផ្លាញទីស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា ហាក់ដូចជាពុំមែនជាការសម្រេចរបស់របបប៉ុលពតទេ តែទំនងជាការទន្រ្ទានពីក្រុមមកពីទីស្នាក់ការទិសបូព៌ា ដែលត្រូវបានសន្និដ្ឋានថាបានលួចយក

[20] Philip SHORT, (២០០៥), *Pol Pot: The History of a Nightmare*

មាស២០០គីឡូក្រាម ហើយបានធ្វើឱ្យផ្ទុះអគារដើម្បីឱ្យមានការយល់ឃើញថាមានចោរមកប្លន់ក្នុងពេលមានការច្របូកច្របល់។

ក្រោយពីថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រទេសជាតិនិងប្រជាជនកម្ពុជាទាំងមូលបានរួចផុតពីសម័យកាលខ្មៅងងឹតនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយសេដ្ឋកិច្ចជាតិក៏បានចាប់ផ្តើមមានសកម្មភាពឡើងវិញបន្តិចម្តងៗពីបាតដៃទទេ។ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញ ហើយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ប្រាក់រៀលក៏ត្រូវបានដាក់ឱ្យចរាចរឡើងវិញ។ ជំនឿទុកចិត្តលើប្រាក់រៀលត្រូវបានចាប់ផ្តើមស្តារឡើងវិញពីចំណុចសូន្យ។ នាពេលនោះ ការដោះដូរភាគច្រើនត្រូវបានធ្វើឡើងដោយទំនិញនឹងទំនិញនៅឡើយ ហើយវត្ថុមានតម្លៃដូចជា មាស ប្រាក់ ចលនវត្ថុមួយចំនួនដូចជាកង់ និងស្បៀងអាហារមួយចំនួនដូចជាអង្ករ ត្រី សាច់ ថ្នាំជក់ ត្រូវបានប្រើប្រាស់ជាមធ្យោបាយដោះដូរ។ នៅក្នុងបរិការណ៍ដែលសេដ្ឋកិច្ច និងថវិការដ្ឋនៅទន់ខ្សោយ ផលិតកម្មក្នុងស្រុកនៅមានកម្រិតទាបខ្លាំង និងការពឹងផ្អែកលើជំនួយពីប្រទេសជាមិត្ត ការពង្រឹងជំនឿទុកចិត្តមកលើរូបិយវត្ថុជាតិជារឿងដ៏លំបាកបំផុត។ ទោះជាយ៉ាងណាក៏ដោយនាដើមទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋបានធ្វើយុទ្ធនាការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាបន្តបន្ទាប់តាមរយៈការបើកប្រាក់បៀវត្សជូនមន្ត្រីរដ្ឋជាប្រាក់រៀល ហើយប្រជាជនក៏ចាប់ផ្តើមប្រើប្រាស់ប្រាក់រៀលទន្ទឹមនឹងវត្ថុមានតម្លៃនានាផងដែរ ។

នៅក្នុងពាក់កណ្តាលទី២ នៃទសវត្សរ៍ឆ្នាំ១៩៨០ រដ្ឋបានចាប់ផ្តើមធ្វើកំណែទម្រង់ពីសេដ្ឋកិច្ចផែនការមជ្ឈការទៅសេដ្ឋកិច្ចទីផ្សារសេរីជាងមុន និងបានអនុញ្ញាតបន្តិចម្តងៗឱ្យមានវត្តមានជំនួយផ្នែកមនុស្សធម៌របស់អង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងជំនួយហិរញ្ញវត្ថុពីគ្រួសារខ្មែរនៅបរទេស។ ការបើកលទ្ធភាពនេះបានធ្វើឱ្យប្រាក់ដុល្លារអាមេរិកហូរចូលក្នុងសេដ្ឋកិច្ចកម្ពុជាសន្សឹមៗ។ លើសពីនេះ កត្តាដែលធ្វើឱ្យប្រជាជនកម្ពុជាបាត់បង់ជំនឿទុកចិត្តមកលើប្រាក់រៀលជាថ្មីម្តងទៀតនោះ គឺនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ រដ្ឋបានជួបប្រទះនឹងឱនភាពថវិកាយ៉ាងខ្លាំង ដែលតម្រូវឱ្យធនាគារជាតិនៃកម្ពុជាបោះពុម្ពរូបិយវត្ថុបន្ថែម ដើម្បីបំពេញការចំណាយរបស់រដ្ឋ ដែលបន្ទាប់មកបានធ្វើឱ្យអត្រាអតិផរណាកើនឡើងរហូតដល់៣ខ្ទង់នៅឆ្នាំ១៩៩២ ហើយតម្លៃប្រាក់រៀលបានថយចុះយ៉ាងខ្លាំងផងដែរ។ វិបត្តិថវិកា និងវិបត្តិរូបិយវត្ថុ គួបផ្សំនឹងការហូរចូលយ៉ាងសន្ធឹកសន្ធាប់របស់ប្រាក់ដុល្លារអាមេរិកពីឆ្នាំ១៩៩១-១៩៩២ ដោយសារការចំណាយរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) បានធ្វើឱ្យប្រជាជនកម្ពុជាទទួលយកប្រើប្រាស់ និងរក្សាទុកប្រាក់ដុល្លារអាមេរិកកាន់តែទូលំទូលាយនៅទូទាំង

ប្រទេស។ កងរក្សាសន្តិសុខ ជំនាញការ មន្ត្រី និងក្រុមការងាររបស់ UNTAC មានវត្តមានស្ទើរគ្រប់ទីកន្លែងនៃប្រទេស ហើយបានប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងប្រតិបត្តិការរបស់ខ្លួនរាប់ចាប់តាំងពីការបើកប្រាក់បៀវត្ស ការជួលកន្លែងស្នាក់នៅ រហូតដល់ការចំណាយលើម្ហូបអាហារ។

ក្នុងឆ្នាំ១៩៩១-៩២ វត្តមានអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) គឺជាប្រតិបត្តិការដ៏ធំ និងចំណាយច្រើនបំផុតក្នុងប្រវត្តិសាស្ត្ររបស់សហប្រជាជាតិ ដោយចំណាយទឹកប្រាក់ចំនួន ១,៧ប៊ីលានដុល្លារអាមេរិក។ បន្ទាប់មក ប្រាក់ដុល្លារបានហូរចូលយ៉ាងគំហុកក្នុងសេដ្ឋកិច្ច បង្កើតជាវិបត្តិថ្មីមួយចំពោះរូបិយវត្ថុជាតិ ខណៈដែលធនាគារជាតិនៃកម្ពុជាមិនបានរៀបចំខ្លួនដើម្បីគ្រប់គ្រងហេតុការណ៍នេះ។ នាពេលនោះ ធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជតែមួយប៉ុណ្ណោះ (Cambodian Commercial Bank បង្កើតឡើងក្នុងឆ្នាំ១៩៩១ ជាធនាគារបុត្តសម្ព័ន្ធរបស់ធនាគារ Siam Commercial Bank) បានអនុវត្តរាល់ប្រតិបត្តិការរបស់ UNTAC និងទទួលប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសក្នុងទំហំកាន់តែច្រើនឡើងៗ។ ប្រាក់ដុល្លារអាមេរិកយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានយកមកប្រើប្រាស់សម្រាប់ការទូទាត់ក្នុងសេដ្ឋកិច្ចកម្ពុជា។ ប្រជាជនកម្ពុជាបានចាប់ផ្តើមស្គាល់ពីតម្លៃរបស់ប្រាក់ដុល្លារអាមេរិក ហើយបានប្រើប្រាស់កាន់តែច្រើនឡើងៗក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងជំនួញ។ ដោយការរក្សាបាននូវស្ថិរភាពនិងការបើកចំហនៃសេដ្ឋកិច្ច សកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ និងវិនិយោគបរទេសបានកើនឡើងជាបន្តបន្ទាប់ និងបានជំរុញដល់ការរីកចម្រើនសេដ្ឋកិច្ច។ ជាលទ្ធផល ប្រាក់ដុល្លារអាមេរិកទទួលបានការពេញនិយមកាន់តែច្រើន និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ស្ទើរគ្រប់សកម្មភាពជំនួញ ជាពិសេស ប្រតិបត្តិការដែលមានទំហំទឹកប្រាក់ធំ និងនៅតាមទីប្រជុំជន។ បន្ទាប់មក ប្រាក់ដុល្លារអាមេរិកត្រូវបានចាប់ផ្តើមប្រើប្រាស់ជាមធ្យោបាយដោះដូរ ឯកតាគណនី និងជាយថាហេតុជាឧបករណ៍រក្សាតម្លៃ ទន្ទឹមនឹងរូបិយវត្ថុក្នុងស្រុក។

ដុល្លារូបនីយកម្មមិនមែនជាលទ្ធផលនៃសេចក្តីសម្រេចផ្នែកនយោបាយទេ គឺកើតឡើងដោយសារការបាត់បង់ជំនឿទុកចិត្តរបស់សាធារណជនចំពោះរូបិយវត្ថុជាតិ និងការថមថយនៃគោលនយោបាយរាជរដ្ឋាភិបាល។ នៅដើមទសវត្សរ៍ទី៩០ ខណៈដែលចំណូលពន្ធគយនៅមានកម្រិតទាប ដោយសារអសកម្មភាពនៃសេដ្ឋកិច្ច របបនយោបាយសារពើពន្ធមានកម្រិតទាប និងកង្វះការឧបត្ថម្ភពីអន្តរជាតិ បានធ្វើឱ្យថវិកាជាតិទទួលហិរញ្ញប្បទានយ៉ាងសំខាន់ពីធនាគារកណ្តាល ដែលបណ្តាលឱ្យបំណុលរបស់រដ្ឋាភិបាលនៅធនាគារកណ្តាលបានកើនឡើងបួនដង ក្នុងចន្លោះឆ្នាំ១៩៩០ដល់ ឆ្នាំ១៩៩៣។ ការផ្គត់ផ្គង់រូបិយវត្ថុ (M2) បានកើនឡើង ២៥១% ក្នុងឆ្នាំ១៩៩០ ២៩% ក្នុងឆ្នាំ១៩៩១

និងលើសពី ២០០% ក្នុងឆ្នាំ១៩៩២។ ជាលទ្ធផល គឺការធ្លាក់ចុះយ៉ាងខ្លាំងនៃតម្លៃប្រាក់រៀល និងអតិផរណាបីខ្ទង់ដែលបង្កើតនូវវិបត្តិបន្ថែមទៀតចំពោះអ្នកប្រើប្រាស់ជាសក្តានុពលនៃប្រាក់រៀល។

ប្រទេសកម្ពុជាជួបប្រទះនឹងអតិផរណាកម្រិតខ្ពស់រហូតដល់ឆ្នាំ១៩៩២។ ការណ៍នេះបណ្តាលឱ្យប្រជាជនកម្ពុជារងគ្រោះពីការបាត់បង់អំណាចទិញនៃប្រាក់រៀលយ៉ាងឆាប់រហ័ស។ ទន្ទឹមនោះ ការអនុវត្តគោលនយោបាយសារពើពន្ធក៏មិនស្ថិតក្នុងភាពអាចគ្រប់គ្រងបានល្អ ដែលបណ្តាលឱ្យមានការធ្វើរូបិយវត្ថុកម្ម (Monetization) នៃឱនភាពសារពើពន្ធ។

**ក្រាហ្វទី១៖ អត្រាអតិផរណា និងអត្រាប្តូរប្រាក់ជាមធ្យមពីឆ្នាំ១៩៨៩-១៩៩៥**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[21]

ជារួម ដុល្លារូបនីយកម្មនៅក្នុងប្រទេសកម្ពុជាបណ្តាលមកពីកត្តា៤យ៉ាង គឺ៖ កត្តាប្រវត្តិសាស្ត្រ កត្តានយោបាយ កត្តាសេដ្ឋកិច្ច និងកត្តាសង្គម។ កត្តាទាំងអស់នេះ បានរួមចំណែកក្នុងការជំរុញឱ្យមានការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងទូលំទូលាយនៅក្នុងសេដ្ឋកិច្ច។ ដុល្លារូបនីយកម្មបានក្លាយជាបាតុភូតរីករាលដាលទូទាំងពេញប្រទេសកម្ពុជា ក៏ដូចជាចំពោះប្រទេសដទៃទៀតក្នុងពិភពលោកដែរ ដែលអតិផរណាមានកម្រិតខ្ពស់ និងមានភាពប្រែប្រួលមិននឹងនរយូរអង្វែង។ ខណៈមានអតិផរណាខ្ពស់ខ្លាំង ចំណែកមួយភាគដ៏ធំនៃប្រតិបត្តិការទូទាត់ក្នុងស្រុកតែងត្រូវបានគិតជារូបិយប័ណ្ណបរទេសជាជាងរូបិយវត្ថុជាតិ។ ប្រជាជនមួយចំនួនក៏មានប្រតិកម្មប្តូរទ្រព្យសកម្មមួយផ្នែករបស់ខ្លួនទៅជារូបិយប័ណ្ណបរទេស ដែលមានស្ថិរភាព មានភាពរឹងមាំ និងមានកម្រិតអតិផរណាទាបជាង ក្នុង

[21] Tal Nay Im, Michel Dabadie & Nguon Sokha, (២០០៧), *Dollarization in Cambodia*

គោលបំណងរក្សាតម្លៃទ្រព្យសកម្មរបស់ពួកគេ។ ការប្តូររូបិយវត្ថុជាតិទៅជារូបិយប័ណ្ណបរទេសបាន ដាក់សម្ពាធទៅលើអត្រាប្តូរប្រាក់ដែលនាំឱ្យរូបិយវត្ថុជាតិមាននិន្នាការចុះតម្លៃ។

## ៣.២. ស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា

ប្រទេសកម្ពុជា ជាប្រទេសដែលមានសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ប៉ុន្តែមិនទាំងស្រុងឡើយ ពោលគឺដុល្លារូបនីយកម្មនៅកម្ពុជាមានលក្ខណៈពហុរូបិយវត្ថុ (Monetary Plurality) ដោយសារក្រៅ ពីប្រាក់ដុល្លាអាមេរិកនិងប្រាក់រៀលរូបិយប័ណ្ណរបស់ប្រទេសជិតខាងដូចជា ប្រាក់បាតថៃ និងប្រាក់ដុង វៀតណាមក៏មាននៅក្នុងចរាចរណ៍ផងដែរ នៅតាមតំបន់ជាប់ព្រំប្រទល់ប្រទេសថៃនិងវៀតណាម និងក្នុងចំណោមពាណិជ្ជករមួយចំនួន ដែលមានការទូទាត់ដោយផ្ទាល់ឬប្រយោលលើទំនិញនាំចូល ពីប្រទេសទាំងនេះ។ ទោះជាយ៉ាងណា ការប្រើប្រាស់ប្រាក់បាតនិងដុងមានកម្រិតទាបទាំងបរិមាណ និងវិសាលភាព ធៀបនឹងប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក។

ការហូរចូលនៃប្រាក់ដុល្លារអាមេរិកជាបន្តបន្ទាប់មកក្នុងសេដ្ឋកិច្ចកម្ពុជា បានធ្វើឱ្យកម្រិត ដុល្លារូបនីយកម្មកើនឡើងជាលំដាប់គឺ ប្រមាណ ៦០% នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ មក ៨០% ក្នុង ទសវត្សរ៍ឆ្នាំ២០០០ និងបានរក្សាក្នុងកម្រិតនេះរហូតដល់បច្ចុប្បន្ន។ ប្រាក់ដុល្លារអាមេរិក បានចាប់ផ្តើម ហូរចូលមកកម្ពុជាយ៉ាងសន្ធឹកសន្ធាប់នៅក្នុងអំឡុងឆ្នាំ១៩៩១-១៩៩២ (ប្រមាណ១,៧ប៊ីលានដុល្លារ អាមេរិក ស្មើនឹងប្រមាណ ២/៣ នៃផលិតផលក្នុងស្រុកសរុប ឆ្នាំ១៩៩៣) សម្រាប់ប្រើប្រាស់ក្នុង ប្រតិបត្តិការរក្សាសន្តិសុខ និងរៀបចំការបោះឆ្នោតនៅកម្ពុជាដោយអាជ្ញាធរបណ្តោះអាសន្នរបស់ អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC)។ ដោយសារការរីកចម្រើននៃសេដ្ឋកិច្ច កំណើនជំនឿ ទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជា និងគោលនយោបាយបើកចំហសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លំហូររូបិយប័ណ្ណ តាមរយៈវិស័យចម្បងៗនៃសេដ្ឋកិច្ចបានគាំទ្រដល់ដុល្លារូបនីយកម្មនៅកម្ពុជា។ ជាក់ស្តែងនៅឆ្នាំ ២០១៤ ការវិនិយោគផ្ទាល់បរទេសកើនឡើងដល់ ៦០% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ការ នាំចេញបានកើនដល់ ៩៣% នៃផ.ស.ស ចំណូលពីវិស័យទេសចរណ៍ ១៧% នៃផ.ស.ស ហើយ ជំនួយបរទេសសរុបមានកម្រិតប្រមាណ ១០% នៃផ.ស.សក្នុងមួយឆ្នាំ។

ចាប់តាំងពីមានវត្តមានក្នុងសេដ្ឋកិច្ចមក ប្រាក់ដុល្លារអាមេរិកត្រូវបានទទួលស្គាល់កាន់តែ ទូលំទូលាយ ហើយមកដល់បច្ចុប្បន្ន ប្រាក់ដុល្លារអាមេរិកនៅតែបន្តតួនាទីរបស់ខ្លួនក្នុងសេដ្ឋកិច្ចកម្ពុជា ទាំងលើមុខងារទូទាត់ ឯកតាកំណត់តម្លៃ និងជាពិសេសការសន្សំក្នុងប្រព័ន្ធធនាគារ។ ជាក់ស្តែង នៅតាមមជ្ឈមណ្ឌលពាណិជ្ជកម្ម ហាងទំនើប និងទីផ្សារទំនិញនិងសេវាមួយចំនួន ប្រាក់ដុល្លារត្រូវ

បានប្រើប្រាស់សម្រាប់កំណត់ថ្លៃនិងទូទាត់ ហើយការប្រើប្រាស់ប្រាក់រៀលនៅលើទីផ្សារទាំងនោះបែរជាទទួលរងការខាតបង់ ដោយសារទីផ្សារទាំងនោះបានកំណត់អត្រាប្តូរប្រាក់ដោយខ្លួនឯងខ្ពស់ជាងអត្រាប្តូរប្រាក់ទីផ្សារ។ ទីផ្សារការងារក៏បានប្រើប្រាស់ប្រាក់ដុល្លារច្រើនផងដែរ ជាពិសេសក្នុងវិស័យឧស្សាហកម្មនិងទេសចរណ៍ជាដើម។ យោងតាមលទ្ធផលអង្កេតរបស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក៏បានបង្ហាញថា ប្រមាណ ៧០% នៃក្រុមហ៊ុន-សហគ្រាសនៅកម្ពុជាផ្តល់ប្រាក់បៀវត្សជាប្រាក់ដុល្លារអាមេរិក។ បើវាស់តាមទំហំប្រាក់បញ្ញើជារូបិយប័ណ្ណក្នុងប្រព័ន្ធធនាគារ ដុល្លាររូបនីយកម្មនៅប្រទេសកម្ពុជាមានកម្រិតខ្ពស់រហូតដល់មានសមាមាត្រ ៨៣% ធៀបនឹងរូបិយវត្ថុទូទៅ (M2) និង ៩៤% បើធៀបនឹងប្រាក់បញ្ញើសរុប។ ទោះជាយ៉ាងណា តម្រូវការរូបិយវត្ថុជាតិក្នុងសេដ្ឋកិច្ចមានការកើនឡើងជាលំដាប់ ឆ្លុះបញ្ចាំងតាមរយៈចរាចរណ៍ប្រាក់រៀលកើនឡើង ១៦% និងប្រាក់បញ្ញើជារៀលកើន ៣៣% ក្នុងអំឡុងពេលមួយទសវត្សរ៍ចុងក្រោយនេះ ខណៈប្រាក់បញ្ញើជារូបិយប័ណ្ណក៏មានការកើនឡើងក្នុងសន្ទុះលឿនផងដែរ (២៦%) ដែលជាលទ្ធផលកម្រិតដុល្លាររូបនីយកម្មបន្តស្ថិតក្នុងកម្រិតខ្ពស់។

**ក្រាហ្វទី២៖ កម្រិតដុល្លាររូបនីយកម្មនៅកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[22]

គួរបញ្ជាក់ថា បន្ថែមទៅលើចំនួនដ៏ច្រើននៃទ្រព្យសកម្មជាប្រាក់ដុល្លារដែលបានកត់ត្រាដោយស្ថិតិផ្លូវការ នៅមានប្រាក់ដុល្លារកំពុងធ្វើចរាចរណ៍យ៉ាងទូលំទូលាយទន្ទឹមនឹងប្រាក់រៀល ដែលមិនអាចទទួលបានស្ថិតិជាក់លាក់ពិតប្រាកដ។ ដោយសារតែមានការលំបាកក្នុងការកំណត់បរិមាណសរុបនៃប្រាក់ដុល្លារអាមេរិកដែលត្រូវបានចរាចរណ៍នៅក្នុងសេដ្ឋកិច្ចកម្ពុជា កម្រិតដុល្លាររូបនីយកម្ម

[22] ធនាគារជាតិនៃកម្ពុជា, (២០១៦), *របាយការណ៍ប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧*

នៅកម្ពុជាត្រូវបានវាស់ដោយប្រើប្រាស់សូចនាករចម្បងៗពីរគឺ ប្រាក់បញ្ញើចារឹកជាប្រាក់ដុល្លារអាមេរិកធៀបនឹងប្រាក់បញ្ញើសរុប ដើម្បីវាស់ពីកម្រិតដុល្លាវូបនីយកម្មហិរញ្ញវត្ថុ (Financial Dollarization) និងប្រាក់បញ្ញើចារឹកជាប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយវត្ថុទូទៅ (Broad Money ឬ M2) ដើម្បីវាស់ពីកម្រិតដុល្លាវូបនីយកម្មនៅក្នុងសេដ្ឋកិច្ចទាំងមូល។ សម្គាល់៖ M2 រួមមាន រូបិយវត្ថុក្នុងចរាចរណ៍ជាប្រាក់រៀល ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស និងប្រាក់បញ្ញើជារៀល ប៉ុន្តែមិនបានរាប់បញ្ចូលសាច់ប្រាក់ជារូបិយប័ណ្ណក្នុងដៃរបស់សាធារណជននោះទេ។

**ក្រាហ្វទី៣៖ កំណើន និងសមាសធាតុរូបិយវត្ថុទូទៅ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[23]

លើសពីនេះ ដុល្លាវូបនីយកម្មមិនត្រឹមតែគ្របដណ្តប់ក្នុងវិស័យរូបវ័ន្តនិងហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែបានចាក់ឫសគល់យ៉ាងជ្រៅទៅក្នុងផ្នត់គំនិតរបស់ប្រជាជន។ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបានផ្សារភ្ជាប់នឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ដោយសារភាពងាយស្រួលក្នុងការប្រើប្រាស់ ការកំណត់ថ្លៃ និងការសន្សំជាប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយវត្ថុជាតិ។ ស្ថានភាពដុល្លាវូបនីយកម្មនៅកម្ពុជាត្រូវបានចាត់ទុកជាប្រភេទដុល្លាវូបនីយកម្មមិនទាំងស្រុងឬមិនផ្លូវការ (Partial Dollarization ឬ Unofficial Dollarization) ដោយសាររូបិយវត្ថុជាតិនៅតែមានវត្តមានក្នុងចរាចរណ៍។ គួរកត់សម្គាល់ផងដែរថា ស្របពេលដែលកម្រិតដុល្លាវូបនីយកម្មបានកើនឡើងនិងស្ថិតក្នុងអត្រាខ្ពស់ក្នុងរយៈពេល

[23] ធនាគារជាតិនៃកម្ពុជា, (២០១៦), *របាយការណ៍ប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧*

២ទសវត្សរ៍ចុងក្រោយនេះ កំណើនរូបិយវត្ថុជាតិក្នុងចរាចរណ៍ និងប្រាក់បញ្ញើជារូបិយវត្ថុជាតិក៏បានកើនឡើង គឺក្នុងអត្រាមធ្យមប្រមាណ ១៧% និង ២៥% ក្នុងមួយឆ្នាំ។ កំណើននេះបញ្ជាក់ថាដុល្លារូបនីយកម្មនៅកម្ពុជាមិនបណ្តាលមកពីបាតុភូតជំនួសរូបិយវត្ថុ (Currency Substitution) ឬជំនួសទ្រព្យសកម្មទេ (Asset Substitution) ដែលជាមូលហេតុនាំឱ្យមានដុល្លារូបនីយកម្មនៅប្រទេសដទៃ។ ដូច្នេះ ប្រាក់ដុល្លារអាមេរិកមិនបានជំនួសទាំងស្រុងលើតួនាទីរូបិយវត្ថុជាតិទេ។

ប៉ុន្តែ ដុល្លារូបនីយកម្មបានកើតមានអស់រយៈពេលជាងពីរទសវត្សរ៍ ហើយបានបង្កើតជាទម្រង់ចាក់ឫសស៊ីជម្រៅហើយដែរ។ ដោយសារតែមានលក្ខណៈមិនទៀងទាត់នៃអតិផរណា និងការធ្លាក់ចុះថ្លៃនៃរូបិយវត្ថុក្នុងស្រុក សាធារណជននៅតែមាននិន្នាការងាកទៅរកការប្រើប្រាស់ប្រាក់ដុល្លារកាន់តែច្រើនឡើង។ ប្រាក់ដុល្លារត្រូវបានប្រើប្រាស់ពីសំណាក់ទាំងនិវាសជន (Residents) និងអនិវាសជន (Nonresidents)។ សហគ្រាសបរទេស អង្គការក្រៅរដ្ឋាភិបាល បណ្តាទីភ្នាក់ងារ និងស្ថានទូត ក៏បានចំណាយជាប្រាក់ដុល្លារអាមេរិកដែរ រួមទាំងការចំណាយចំពោះបុគ្គលិក។ គ្រឹះស្ថានធនាគារក៏និយមធ្វើប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកដែរ។ ប្រជាជនបានគិតថ្លៃទំនិញជាប្រាក់ដុល្លារ រីឯថ្លៃទំនិញជារូបិយវត្ថុក្នុងស្រុកត្រូវបានគណនាដោយផ្អែកទៅតាមអត្រាប្តូរប្រាក់ ឧទាហរណ៍ ថ្លៃស្ករត្នោត និងផលិតផលក្នុងស្រុកផ្សេងទៀត មាននិន្នាការឡើងថ្លៃដូចផលិតផលនាំចូលដែរ នៅពេលដែលតម្លៃប្រាក់រៀលធ្លាក់ចុះ។ ដូច្នេះ ដើម្បីឱ្យដំណើរការនេះវិលមករកសភាពដើមវិញ គឺត្រូវតែប្រើរយៈពេលយូរ និងចាំបាច់ត្រូវមានការចូលរួមយ៉ាងសកម្ម និងភាពអំណត់ពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធទាំងអស់។

រហូតមកដល់បច្ចុប្បន្ននេះ ដុល្លារូបនីយកម្មនៅតែបន្តមាន ទោះបីជាសេដ្ឋកិច្ចនិងនយោបាយមានស្ថិរភាពចាប់តាំងពីឆ្នាំ១៩៩៩យ៉ាងណាក៏ដោយ ដែលប្រការនេះឆ្លុះបញ្ចាំងពីឥទ្ធិពលនៃការរំពឹងទុករបស់ទីផ្សារលើជម្រើសរូបិយវត្ថុដែលប្រើប្រាស់ក្នុងសេដ្ឋកិច្ចកម្ពុជា។ ទោះបីជាដុល្លារូបនីយកម្មកំពុងតែកើនឡើងយ៉ាងទូលំទូលាយក្តី ក៏ប្រាក់រៀលនៅតែត្រូវបានបន្តប្រើប្រាស់ជាឯកតាគណនី និងជាមធ្យោបាយដោះដូរ។ ជាទូទៅ ប្រាក់រៀលត្រូវបានទទួលយកកាន់តែច្រើន ដោយសារតែការសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ ប្រាក់រៀលត្រូវបានប្រើប្រាស់ និងពេញនិយមខ្លាំងនៅក្នុងវិស័យកសិកម្ម ការទូទាត់តូចៗ ការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ ដូចជាចំណាយលើម្ហូបអាហារ ជាដើម។

ជារួម នៅក្នុងតំបន់ជនបទ ប្រាក់រៀលមានតួនាទីសំខាន់ណាស់សម្រាប់សកម្មភាពសេដ្ឋកិច្ចរបស់ប្រជាជន ចំណែកឯប្រាក់ដុល្លារអាមេរិកត្រូវបានប្រើប្រាស់ច្រើននៅក្នុងតំបន់សេដ្ឋកិច្ចសំខាន់ៗ

ដូចជាទីក្រុងនិងទីប្រជុំជន និងលើការទូទាត់ទំនិញនិងសេវាដែលមានតម្លៃធំៗ។ ប្រាក់រៀលត្រូវបានប្រើប្រាស់ដោយរាជរដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា ដើម្បីបើកប្រាក់បៀវត្សឱ្យមន្រ្តី-បុគ្គលិកការទូទាត់ចំណាយ ហើយត្រូវបាននិយមប្រើដោយសាធារណជនសម្រាប់ប្រតិបត្តិការតូចៗ។

## ៣.៣. គុណសម្បត្តិនៃដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ចកម្ពុជា

ដុល្លារូបនីយកម្មជាបាតុភូតដែលនាំមកទាំងអត្ថប្រយោជន៍ និងបញ្ហាប្រឈមដល់សេដ្ឋកិច្ចនៃប្រទេសដែលជួបនឹងបាតុភូតនេះ។ គុណសម្បត្តិរបស់ដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជាមានដូចតទៅៈ

### ៣.៣.១. ការរួមចំណែករក្សាស្ថិរភាពអត្រាប្តូរប្រាក់នៃរូបិយវត្ថុក្នុងស្រុក និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

ដុល្លារូបនីយកម្ម បានជំរុញប្រជាជនឱ្យងាកពីការនិយមប្រើប្រាស់មាសទៅប្រើប្រាស់ប្រាក់ដុល្លារអាមេរិកវិញ ក្នុងការទូទាត់ឬមធ្យោបាយរក្សាទ្រព្យសម្បត្តិនៅដើមទសវត្សរ៍ឆ្នាំ១៩៩០។ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបានធ្វើឱ្យមានភាពប្រសើរឡើងនៃសេដ្ឋកិច្ច ទីផ្សារ ដែលពឹងផ្អែកលើរូបិយវត្ថុ។ ដុល្លារូបនីយកម្មបានកាត់បន្ថយហានិភ័យប្តូរប្រាក់ និងការធ្វើព្រឹទ្ធិកម្ម (Speculation) ពីការធ្វើឱ្យអត្រាប្តូរប្រាក់ប្រែប្រួល។ ដោយសារការប្រើប្រាស់ប្រាក់រៀលមានកម្រិតទាប អាជ្ញាធររូបិយវត្ថុអាចគ្រប់គ្រងលើចរាចររូបិយវត្ថុជាតិនិងអត្រាប្តូរប្រាក់ ហើយអ្នកធ្វើព្រឹទ្ធិកម្មលើទីផ្សារប្តូរប្រាក់ក៏មិនអាចទាញចំណេញច្រើនពីការធ្វើឱ្យប្រែប្រួលលើអត្រាប្តូរប្រាក់ដែរ។ កត្តាទាំងនេះបានរួមចំណែកធ្វើឱ្យកម្ពុជាអាចគេចផុតពីការប្រឈមនឹងវិបត្តិហិរញ្ញវត្ថុអាស៊ី កាលពីក្នុងអំឡុងឆ្នាំ១៩៩៧-១៩៩៨ ដែលបានធ្វើឱ្យរូបិយវត្ថុក្នុងតំបន់ទទួលរងនូវការធ្លាក់ថ្លៃយ៉ាងខ្លាំង។

ដុល្លារូបនីយកម្មបានរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាស្ថិរភាពថ្លៃនិងការពង្រឹងការគោរពវិន័យសារពើពន្ធ (Fiscal Discipline) ជាពិសេសក្នុងដំណាក់កាលដែលសេដ្ឋកិច្ចកម្ពុជាបានជួបប្រទះនឹងអស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ប្រាក់ដុល្លារអាមេរិកត្រូវបានចាត់ទុកជារូបិយប័ណ្ណដែលមានស្ថិរភាពថ្លៃរឹងមាំធៀបនឹងរូបិយប័ណ្ណនានា (Hard Currency) ដូច្នេះការប្រើប្រាស់ដុល្លារក៏បានបន្ថយឥទ្ធិពលអត្រាប្តូរប្រាក់លើអត្រាអតិផរណាផងដែរ (Pass-through Effect of Exchange Rate on Inflation)។ ជាទូទៅ ប្រទេសដែលមានដុល្លារូបនីយកម្មតែងអនុវត្តរបបអត្រាប្តូរប្រាក់ដែលតម្រូវឱ្យប្រទេសនោះរក្សានូវបរិមាណប្រាក់បម្រុងជាប្រាក់ដុល្លារអាមេរិក ដើម្បីរក្សាស្ថិរភាពអត្រាប្តូរ

ប្រាក់រវាងប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ដែលគេហៅថា ការថ្កក់រូបិយវត្ថុក្នុងស្រុកទៅនឹងរូបិយប័ណ្ណ (Currency Peg or Currency Board)។ ការផ្សារភ្ជាប់ ឬថ្កក់ប្រាក់រៀលនឹងប្រាក់ដុល្លារអាមេរិកបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាអំណោយផលពីឥទ្ធិពលនៃការរីកចម្រើននៃសេដ្ឋកិច្ចអាមេរិក និងភាពរឹងមាំនៃប្រាក់ដុល្លារអាមេរិក។ ហេតុនេះ នៅពេលតម្លៃរូបិយប័ណ្ណក្នុងតំបន់ដូចជាប្រាក់បាត ប្រាក់ដុង ជាដើម បានធ្លាក់ចុះ ប្រាក់រៀលនៅតែបន្តមានស្ថិរភាពនិងតម្លៃរឹងមាំក្រោមឥទ្ធិពលនៃប្រាក់ដុល្លារអាមេរិក។ ម្យ៉ាងវិញទៀត ការអនុវត្តរបបអត្រាប្តូរប្រាក់បែបនេះក៏បានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ គឺការធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ដោយធនាគារជាតិនៃកម្ពុជាធ្វើប្រតិបត្តិការទិញ-លក់ប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀល នៅក្នុងទីផ្សារដើម្បីផ្គត់ផ្គង់ឬស្រូបយកប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក ស្របទៅតាមយន្តការតម្រូវការទីផ្សារ សំដៅរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ស្ថិរភាពថ្លៃ និងជំរុញកំណើនសេដ្ឋកិច្ច។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងមិនពឹងផ្អែកលើការបោះពុម្ពរូបិយវត្ថុ ដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិការដ្ឋនោះទេ ដែលបានធ្វើឱ្យមានផលវិជ្ជមានដល់ការគ្រប់គ្រងសម្ពាធអតិផរណា និងការពង្រឹងគោលនយោបាយសារពើពន្ធ។

**ក្រាហ្វទី៤៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ឆ្នាំ២០១៥-ឆមាសទី១ ឆ្នាំ២០១៧**
**(អត្រាមធ្យមទីផ្សារ)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[24]

[24] ធនាគារជាតិនៃកម្ពុជា, (២០១៧), *របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧*

## ក្រាហ្វទី៥៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ឆ្នាំ១៩៩៥-២០១៦

( អត្រាមធ្យមទីផ្សារ )




## ក្រាហ្វទី៦៖ អត្រាអតិផរណានៅកម្ពុជា ឆ្នាំ២០០១-២០១៦




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[25]

25 ធនាគារជាតិនៃកម្ពុជា, (២០១៦), *តួនាទីធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល*

អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ទោះបីជាស្ថិតក្នុងបរិការណ៍ដុល្លារូបនីយកម្មកម្រិតខ្ពស់ក៏ដោយ កម្ពុជាទទួលបានកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ប្រមាណ ៧,៧% ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះដែលធ្វើឱ្យកម្ពុជាជាប់ចំណាត់ថ្នាក់ទី៦ ក្នុងចំណោមប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេលើពិភពលោក។ លើសពីនេះ នៅឆ្នាំ២០១៦ ធនាគារពិភពលោកថែមទាំងដំឡើងចំណាត់ថ្នាក់សេដ្ឋកិច្ចកម្ពុជា ពីប្រទេសដែលមានប្រាក់ចំណូលទាប (Low-income Country) មកប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (Lower-middle-income Country) ទៀតផង[26] ហើយនៅក្នុងឆ្នាំដដែលនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក៏បានហៅកម្ពុជាថាជាខ្លាសេដ្ឋកិច្ចថ្មីនៅក្នុងទ្វីបអាស៊ីដោយសារល្បឿនលឿននៃការរីកចម្រើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។[27] សមិទ្ធផលទាំងនេះបង្ហាញថា ដុល្លារូបនីយកម្មមិនបានរំខានដល់ការអភិវឌ្ឍសេដ្ឋកិច្ចទេ ប៉ុន្តែបានជួយរួមចំណែកមួយផ្នែកក្នុងដំណើរការនេះទៀតផង។

**ក្រាហ្វទី៧៖ កំណើន ផ.ស.ស និងចំណូលរបស់ប្រជាជនម្នាក់ៗ**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[28]

[26] Sodeth Ly, (២០១៦), *Cambodia is now a lower-middle income economy: What does this mean?*, World Bank, នៅគេហទំព័រ៖ http://blogs.worldbank.org/eastasiapacific/cambodia-is-now-a-lower-middle-income-economy-what-does-this-mean, ចូលមើលនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧

[27] Asian Development Bank, (២០១៦), *Here Comes Cambodia: Asia's New Tiger Economy*, នៅគេហទំព័រ៖ https://www.adb.org/news/features/here-comes-cambodia-asia-s-new-tiger-economy, ចូលមើលនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៧

[28] ធនាគារជាតិនៃកម្ពុជា, (២០១៧), *អត្ថបទពិភាក្សា៖ យុទ្ធសាស្ត្រលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល*

### ៣.៣.២. ការទាក់ទាញលំហូរវិនិយោគ ព្រមទាំងលើកកម្ពស់ភាពស៊ីជម្រៅហិរញ្ញវត្ថុ និង បរិយាប័ន្នហិរញ្ញវត្ថុ

ដុល្លាររូបនីយកម្មបានជួយទប់ស្កាត់លំហូរចេញនៃដើមទុន និងលើកកម្ពស់អន្តរការីយកម្មហិរញ្ញវត្ថុ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (Financial Deepening) និងបរិយាប័ន្នហិរញ្ញវត្ថុ (Financial Inclusion)។ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ គឺជាសូចនាករសេដ្ឋកិច្ចមួយដែលឆ្លុះបញ្ចាំងពីភាពរីកចម្រើននៃប្រព័ន្ធហិរញ្ញវត្ថុ ដោយការកើនឡើងកាន់តែច្រើននៃសេវាហិរញ្ញវត្ថុ និងកំណើនទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈសន្ទនីយភាព។ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុត្រូវបានគណនាដោយយករូបិយវត្ថុទូទៅចែកនឹងផលិតផលក្នុងស្រុកសរុប។ ចំណែកឯបរិយាប័ន្នហិរញ្ញវត្ថុវិញ គឺជាសូចនាករសេដ្ឋកិច្ចដែលឆ្លុះបញ្ចាំងពីលទ្ធភាពនៃការទទួលបានសេវាហិរញ្ញវត្ថុនៅក្នុងប្រទេសមួយ ហើយសូចនាករនេះត្រូវបានវាស់ដោយចំនួនប្រជាជនដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេស។ ចំពោះកម្ពុជាបរិយាប័ន្នហិរញ្ញវត្ថុរាប់បញ្ចូល ចំនួនអ្នកដាក់ប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារ ចំនួនអ្នកខ្ចីរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ អតិថិជនប្រើប្រាស់សេវាកម្មរបស់អ្នកដំណើរការតតិយភាគី និងក្រុមហ៊ុនភតិសន្យា។

ដុល្លាររូបនីយកម្មបានផ្តល់លទ្ធភាពក្នុងការសន្សំជាប្រាក់ដុល្លារអាមេរិកនៅក្នុងប្រទេស ដូច្នេះបានកាត់បន្ថយការដាក់ប្រាក់បញ្ញើរបស់និវាសជននៅក្រៅប្រទេស ហើយប្រភពទុនទាំងនេះត្រូវបានយកទៅប្រើប្រាស់ក្នុងការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគ និងការប្រើប្រាស់នានាដែលជួយអភិវឌ្ឍប្រព័ន្ធសេដ្ឋកិច្ចនិងហិញ្ញវត្ថុរបស់កម្ពុជា។ ភាពអំណោយផលទាំងនេះ គួបផ្សំនិងការរីកចម្រើនវិស័យសេដ្ឋកិច្ចបានជំរុញភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (រូបិយវត្ថុទូទៅ/ផសស ឬ M2/GDP) កើនឡើងពី ៥% នៅឆ្នាំ១៩៩៣ ដល់ ៧៤,៧% នៅឆ្នាំ២០១៧ ហើយអនុបាតប្រាក់បញ្ញើនិងឥណទានសរុបរបស់វិស័យធនាគារធៀបនឹង ផ.ស.ស បានកើនពីកម្រិតដ៏ទាបប្រមាណ ២,១% និង ២,៥% ដល់ ៧៦,៥% និង ៨៣% រៀងគ្នា។ មិនតែប៉ុណ្ណោះ បរិយាប័ន្នហិរញ្ញវត្ថុត្រូវបានលើកកម្ពស់ជាលំដាប់ដោយប្រជាជនប្រមាណ ៥៩% កំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុ។

ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ និងបរិយាប័ន្នហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ណាស់នៅក្នុងសេដ្ឋកិច្ច ដោយបានរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈវិសាលភាពនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុ ព្រមទាំងរក្សាស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងកាត់បន្ថយហានិភ័យជាប្រព័ន្ធ (Systemic Risk)។ ដោយប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិកបានរួមចំណែក ៨៩% នៃរូបិយវត្ថុទូទៅ មានន័យថា ការកើនឡើងនៃភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ និងបរិយាប័ន្នហិរញ្ញវត្ថុមកដល់ពេលបច្ចុប្បន្ន គឺមានការ

រួមចំណែកយ៉ាងខ្លាំងក្លាពីប្រាក់ដុល្លារអាមេរិកដែលគ្របដណ្តប់ទៅលើប្រតិបត្តិការ និងសេវាហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចកម្ពុជា។

**ក្រាហ្វទី៨៖ ភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ និងកម្រិតដុល្លារូបនីយកម្ម**




**ក្រាហ្វទី៩៖ ទ្រព្យសកម្ម ប្រាក់បញ្ញើ និងឥណទាននៃវិស័យធនាគារធៀបនឹងផ.ស.ស**
**( គិតជាភាគរយ )**



## ក្រាហ្វទី១០៖ បរិយាប័ន្នហិរញ្ញវត្ថុកម្ពុជា




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[29]

### ៣.៣.៣. ជំរុញការវិនិយោគក្នុងស្រុកដោយថ្លៃដើមទុនសម្រាប់ប្រាក់ដុល្លារមានកម្រិតទាប

ប្រទេសកម្ពុជា ជាប្រទេសដែលស្ថិតក្នុងស្ថានភាពដុល្លារូបនីយកម្មហិរញ្ញវត្ថុដែលប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុបមានកម្រិតដល់ទៅ ៩៥% ដែលជាកម្រិតខ្ពស់ខ្លាំង។ ហេតុនេះ ប្រាក់បញ្ញើនិងឥណទាននៅក្នុងវិស័យធនាគារ ត្រូវបានគ្របដណ្តប់ដោយប្រាក់បញ្ញើនិងឥណទានចារឹកជារូបិយប័ណ្ណបរទេស (ប្រាក់ដុល្លារអាមេរិក)។ ដោយអត្រាការប្រាក់ជាប្រាក់ដុល្លារអាមេរិកមានកម្រិតទាបជាងអត្រាការប្រាក់ជាប្រាក់រៀល វិនិយោគិនទាំងក្នុងស្រុកនិងក្រៅប្រទេសអាចមានឱកាសទទួលបានប្រភពដើមទុនដែលមានថ្លៃដើមទាប។ តាមទ្រឹស្តី ទិន្នផលដែលគ្រោងទទួលបានពីការវិនិយោគជាប្រាក់រៀល មិនត្រឹមតែអាស្រ័យតែលើអត្រាការប្រាក់ (ដែលនៅតែមានកម្រិតខ្ពស់) នោះទេ តែថែមទាំងអាស្រ័យលើអត្រាប្តូរប្រាក់រៀលធៀបជាមួយប្រាក់ដុល្លារ ដែលគេរំពឹងទុកថានឹងប្រែប្រួលយ៉ាងណានៅពេលការវិនិយោគដល់កាលវសាន្ត ដោយបូកបញ្ចូលផងដែរនូវបុព្វលាភហានិភ័យ។ ចំពោះទស្សនៈរបស់បណ្តាធនាគារពាណិជ្ជ ក្នុងនាមជាវិនិយោគិន ហានិភ័យនៃការវិនិយោគជាប្រាក់រៀល នៅតែត្រូវបានចាត់ទុកថាមានកម្រិតខ្ពស់ដដែល។ ដូច្នេះ ចំពោះឥណប្រតិទានដូចគ្នា អត្រាការប្រាក់លើប្រាក់កម្ចីជារៀលមានកម្រិតខ្ពស់ជាងអត្រាការប្រាក់លើប្រាក់កម្ចីជាដុល្លារអាមេរិក ពីព្រោះគេនៅតែនឹកឃើញអំពីកម្រិតអតិផរណាដ៏ខ្ពស់ខ្លាំង និងនៃការចុះថ្លៃនៃប្រាក់រៀល

[29] ធនាគារជាតិនៃកម្ពុជា, (២០១៧), *របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧*

ដែលធ្លាប់កើតមានកាលពីអតីតកាលមក។ ដូច្នេះហើយ ដោយសារតែអត្រាការប្រាក់ជាប្រៀលថ្លៃជាងអត្រាការប្រាក់ដុល្លារអាមេរិក ដុល្លារូបនីយកម្មហិរញ្ញវត្ថុបានអនុញ្ញាតឱ្យវិនិយោគិនទទួលបានប្រភពទុនដែលមានថ្លៃដើមទាប ដែលជាលទ្ធផលជំរុញដល់ការវិនិយោគនៅក្នុងប្រទេសកម្ពុជា។

**ក្រាហ្វទី១១៖ អត្រាការប្រាក់ឥណទានគ្រឹះស្ថានធនាគារ**
**(អត្រាប្រចាំឆ្នាំសម្រាប់កាលកំណត់ ១២ខែ)**




**ក្រាហ្វទី១២៖ អត្រាការប្រាក់ឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
**(អត្រាប្រចាំឆ្នាំសម្រាប់កាលកំណត់ ១២ខែ)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[30]

[30] ធនាគារជាតិនៃកម្ពុជា, (២០១៧), *របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧*

គួរកត់សម្គាល់ថា គិតត្រឹមឆមាសទី១ ឆ្នាំ២០១៧ អត្រាការប្រាក់ឥណទានជាប្រាក់រៀលលើកាលកំណត់១២ខែរបស់គ្រឹះស្ថានធនាគារមានកម្រិត ១៥,៥% ក្នុងមួយឆ្នាំ ខ្ពស់ជាងអត្រាការប្រាក់ជាប្រាក់ដុល្លារអាមេរិកដែលមានកម្រិតត្រឹម ១១,៧% ក្នុងមួយឆ្នាំ។ រីឯអត្រាការប្រាក់ឥណទានជាប្រាក់រៀលលើកាលកំណត់១២ខែរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏មានកម្រិតខ្ពស់ផងដែរ គឺ ៣០,៩៥% ក្នុងមួយឆ្នាំ ខណៈអត្រាការប្រាក់ជាប្រាក់ដុល្លារអាមេរិកមានកម្រិតទាបជាងត្រឹម ២៥%។

## ៣.៣.៤. ការបើកទូលាយសមាហរណកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ

ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក បានជួយដល់ដំណើរការសមាហរណកម្មវិស័យពាណិជ្ជកម្មអន្តរជាតិ ដោយសារប្រាក់ដុល្លារត្រូវបានប្រើប្រាស់នៅក្នុងការដោះដូរអន្តរជាតិទាំងក្នុងតំបន់និងពិភពលោក។ លើសពីនេះ ដុល្លាររូបនីយកម្មបានសម្រួលដល់ការទូទាត់ពាណិជ្ជកម្មអន្តរជាតិដោយមិនចាំបាច់ប្តូរពីរូបិយវត្ថុជាតិទៅប្រាក់ដុល្លារអាមេរិក ហើយអ្នកផលិតក៏អាចរួចផុតពីការខាតបង់នៃអត្រាប្តូរប្រាក់ផងដែរ។ ភាពអំណោយផលនេះបានទាក់ទាញការវិនិយោគពីបរទេសកាន់តែច្រើនឡើងៗចូលមកប្រទេសកម្ពុជា ដែលបានរួមចំណែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញការនាំចេញរបស់កម្ពុជា ជាពិសេសការនាំចេញសម្លៀកបំពាក់ ក្នុងនោះការនាំចេញសម្លៀកបំពាក់ទៅកាន់តំបន់អឺរ៉ុបមានសមាមាត្រធំជាងគេ គឺ ៤២,៤% និងសហរដ្ឋអាមេរិកជាទីផ្សារធំបន្ទាប់ ៣១,៧%។ កម្រិតបើកចំហពាណិជ្ជកម្មអន្តរជាតិនៃសេដ្ឋកិច្ចកម្ពុជា (ការនាំចេញនិងនាំចូលសរុបធៀបនឹងផ.ស.ស) បានកើនឡើងពី ៣៨% នៅឆ្នាំ១៩៩៣ ដល់ ១០៧% នៅឆ្នាំ២០១៣។

**ក្រាហ្វទី១៣៖ សមាមាត្រនៃការនាំចេញសម្លៀកបំពាក់ (គិតជាភាគរយ)**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[31]

[31] ធនាគារជាតិនៃកម្ពុជា, (២០១៦), *របាយការណ៍ប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧*

## ៣.៤. គុណវិបត្តិនៃដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ចកម្ពុជា

ស្របពេលដុល្លារូបនីយកម្មបានផ្តល់អត្ថប្រយោជន៍មួយចំនួនដល់សេដ្ឋកិច្ចកម្ពុជា ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងច្រើនសន្ធឹកសន្ធាប់នេះ ក៏មានផលប៉ះពាល់ផងដែរដែលបានកាត់បន្ថយភាពធន់នៃសេដ្ឋកិច្ច (Economic Resilience) និងរារាំងដល់ការរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ គុណវិបត្តិនៃដុល្លារូបនីយកម្មចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជាមានដូចតទៅ៖

### ៣.៤.១. ការបាត់បង់ចំណូលពីការបោះពុម្ពប្រាក់

ដុល្លារូបនីយកម្ម បានធ្វើឱ្យកម្ពុជាខាតបង់ប្រាក់ចំណូលពីការបោះពុម្ពក្រដាសប្រាក់រូបិយវត្ថុជាតិ (Seigniorage)។ ចំណូលពីការបោះពុម្ពក្រដាសប្រាក់គឺជាភាពខុសគ្នារវាងតម្លៃចារឹកនិងចំណាយផលិតកម្មក្នុងការបោះពុម្ព។ ក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ កម្ពុជាបានបាត់បង់លទ្ធភាពក្នុងការទទួលបានចំណូលពីការបោះពុម្ពនេះ ដោយសារសាធារណជនកាន់រូបិយប័ណ្ណប្រាក់ដុល្លារអាមេរិកជាចម្បងជំនួសឱ្យរូបិយវត្ថុជាតិ។ ការកាន់កាប់នេះមានន័យស្មើនឹងការខាតបង់ចំណូលពីការបោះពុម្ពរូបិយវត្ថុជាតិ ហើយបែរជាផ្តល់ចំណូលទៅឱ្យធនាគារកណ្តាលអាមេរិកដែលជាអ្នកបោះផ្សាយប្រាក់ដុល្លារអាមេរិកទៅវិញ។

នៅពេលដែលរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់កាន់តែច្រើន រាជរដ្ឋាភិបាលក៏អាចទទួលបាននូវប្រាក់ចំណូល Seigniorage កាន់តែច្រើនផងដែរ ដែលនឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចគរពូនទ្រព្យសម្បត្តិជាតិ ឬយកទៅប្រើប្រាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិសំខាន់ៗ ដូចជាហេដ្ឋារចនាសម្ព័ន្ធ ការជួយកាត់បន្ថយភាពក្រីក្រដោយឧបត្ថម្ភប្រាក់ជូនប្រជាជននៅតាមទីជនបទ ជាដើម។ យោងតាមទិន្នន័យរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ កម្ពុជាបានទទួលបានចំណូលពីការបោះពុម្ពក្រដាសប្រាក់ជាមធ្យមក្នុងចន្លោះពី ០,៤% ទៅ ២,៤% នៃផ.ស.ស ក្នុង ១ឆ្នាំ នៅអំឡុងឆ្នាំ១៩៩៤-២០០១ ហើយបានកើនឡើងដល់ប្រមាណ ៥% នៃ ផ.ស.ស នៅឆ្នាំ២០១០ ដែលជាកម្រិតទាបបំផុតបើធៀបនឹងប្រទេសដែលសេដ្ឋកិច្ចមិនស្ថិតក្នុងស្ថានភាពដុល្លារូបនីយកម្ម។

គួរបញ្ជាក់ថា ចំណូលពីការបោះពុម្ពក្រដាសប្រាក់ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្រពីរយ៉ាងគឺ វិធីសាស្ត្រប្រាក់បម្រុង (Reserve Money Method) គណនាដោយយកបម្រែបម្រួលប្រាក់បម្រុងរូបិយវត្ថុ (Change in Reserve Money) ធៀបនឹងផ.ស.ស និងវិធីសាស្ត្រចំណូលរបស់ធនាគារកណ្តាល (Central Bank Profit Method) គណនាដោយយកផលសងរវាងចំណូលការប្រាក់ពីទ្រព្យសកម្មរបស់ធនាគារកណ្តាល (Central Bank's Interest Income) និងការប្រាក់ដែលផ្តល់ទៅឱ្យ

ប្រាក់បញ្ញើជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅធនាគារកណ្តាល ធៀបនឹងផ.ស.ស។ សម្រាប់វិធីសាស្ត្រទី២ ដោយសារធនាគារជាតិនៃកម្ពុជាពុំបានផ្តល់ជាការប្រាក់ដល់ប្រាក់បញ្ញើជាប្រាក់រៀលរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំណូលពីការបោះពុម្ពក្រដាសប្រាក់ត្រូវស្មើនឹងចំណូលការប្រាក់ពីទ្រព្យសកម្មរបស់ធនាគារជាតិនៃកម្ពុជាធៀបនឹងផ.ស.សតែម្តង។

## តារាងការប៉ាន់ស្មានចំណូលពីការបោះពុម្ពក្រដាសប្រាក់នៅកម្ពុជា ឆ្នាំ១៩៩៤-២០០១

| | 1994 | 1995 | 1996 | 1997 | 1998 | 1999 | 2000 | 2001 |
|---|---|---|---|---|---|---|---|---|
| **Reserve Money Method** | | | | | | | | |
| Change in reserve money (CR billion) | 57.8 | 28.6 | 135.3 | 95.5 | 257.3 | 127.3 | 231.1 | 198.6 |
| in percent of GDP | 0.9 | 0.4 | 1.6 | 1 | 2.4 | 1.1 | 1.9 | 1.5 |
| in percent of government revenue | 19.9 | 4.8 | 21 | 12.7 | 29.2 | 13.5 | 17.3 | 13 |
| **Central Bank Profit Method** | | | | | | | | |
| Interest income (CR billion) | … | 18.6 | 28.9 | 47.4 | 58.7 | 67.6 | 114.7 | 88.4 |
| in percent of GDP | … | 0.3 | 0.3 | 0.4 | 0.6 | 0.6 | 0.9 | 0.7 |
| in percent of government revenue | … | 2.9 | 3.9 | 5.4 | 6.2 | 5.1 | 8 | 5.8 |

ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)[32]

## ៣.៤.២. កាត់បន្ថយទុនបម្រុងអន្តរជាតិ

ដុល្លារូបនីយកម្មបានកាត់បន្ថយការគរពូនទុនបម្រុងអន្តរជាតិ (International Reserve) របស់ប្រទេសកម្ពុជាដែលត្រូវបានរក្សាសម្រាប់រក្សាភាពរឹងមាំនៃរូបិយវត្ថុជាតិ និងសម្រាប់ការទូទាត់ជាមួយនឹងប្រទេសផ្សេងៗនៅលើឆាកអន្តរជាតិ។ ទុនបម្រុងអន្តរជាតិ គឺជាទ្រព្យសកម្មចារឹកជារូបិយប័ណ្ណបរទេសដែលមានលក្ខណៈសន្ទនីយភាព ហើយត្រូវបានទទួលយកក្នុងការដោះដូរនិងទូទាត់នៅក្នុងពាណិជ្ជកម្មអន្តរជាតិ។ ជាទូទៅ ទុនបម្រុងអន្តរជាតិរួមមាន មាស រូបិយប័ណ្ណបរទេស ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសនៅស្ថាប័នអន្តរជាតិផ្សេងៗ ទុនបម្រុង SDR (Special Drawing Right) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ មូលបត្រចារឹកជារូបិយប័ណ្ណបរទេសដែលមានលក្ខណៈសន្ទនីយភាព។ល។

[32] Mario de Zamarόczy and Sopanha Sa, (២០០២), *Macroeconomic Adjustment in a Highly Dollarized Economy: The Case of Cambodia*

ដោយរូបិយប័ណ្ណបរទេសជាសមាសធាតុដ៏ចម្បងនៃទុនបម្រុងអន្តរជាតិ ការចរាចររូបិយប័ណ្ណបរទេសដូចជាប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារ ជាកត្តាមួយប៉ះពាល់ដល់ការគរពូនទុនបម្រុងអន្តរជាតិ ដោយសាររូបិយប័ណ្ណបរទេសដែលកំពុងចរាចរទាំងនោះអាចត្រូវបានប្រមូលដោយធនាគារជាតិនៃកម្ពុជាមកជាទុនបម្រុងអន្តរជាតិ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានគរពូនទុនបម្រុងអន្តរជាតិសរុបចំនួន ៧,៧ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការទូទាត់ការនាំចូលទំនិញនិងសេវាបានប្រមាណចំនួន៦ខែ។ បរិមាណទុនបម្រុងអន្តរជាតិអាចនឹងកើនឡើងខ្លាំងប្រសិនបើកម្ពុជាអាចធ្វើបដិដុល្លារូបនីយកម្ម (Dedollarization) ដោយជោគជ័យ ដោយសារតែនៅពេលប្រជាពលរដ្ឋចាប់ផ្តើមបោះបង់ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក និងងាកមកប្រើប្រាស់ប្រាក់រៀលវិញ នោះធនាគារជាតិនៃកម្ពុជានឹងបោះផ្សាយប្រាក់រៀលបន្ថែមដើម្បីបំពេញតម្រូវការប្រើប្រាស់ប្រាក់រៀលរបស់ប្រជាពលរដ្ឋទាំងនោះ ព្រមទាំងស្រូបយកប្រាក់ដុល្លារអាមេរិកដែលត្រូវបានបោះបង់ចូលមកគរពូនទុនបម្រុងអន្តរជាតិ ដែលជាលទ្ធផលនឹងបង្កើនការធានាការទូទាត់ការនាំចូលទំនិញនិងសេវា ពង្រឹងភាពរឹងមាំនៃតម្លៃរូបិយវត្ថុជាតិ និងអាចឱ្យធនាគារជាតិនៃកម្ពុជាយកទុនបម្រុងទាំងនោះទៅវិនិយោគ ដើម្បីទទួលបានចំណូលបន្ថែមទៀតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

**ក្រាហ្វទី១៤៖ ស្ថានភាពទុនបម្រុងអន្តរជាតិកម្ពុជា**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា[33]

[33] ធនាគារជាតិនៃកម្ពុជា, (២០១៧), *របាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៧*

### ៣.៤.៣. ការអនុវត្តគោលនយោបាយរូបិយវត្ថុមិនមានប្រសិទ្ធភាព

ដុល្លារូបនីយកម្ម បានដាក់កំហិតដល់ជម្រើសឧបករណ៍និងប្រសិទ្ធភាពគោលនយោបាយសេដ្ឋកិច្ច ដោយសារការគ្រប់គ្រងបរិមាណផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកមិនអាចធ្វើឡើងដោយធនាគារជាតិនៃកម្ពុជាបានឡើយ គឺត្រូវបានធ្វើឡើងដោយធនាគារកណ្ដាលអាមេរិក (Federal Reserve) ដែលនាំឱ្យជះឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុរបស់អាមេរិកមកលើសេដ្ឋកិច្ចកម្ពុជា។ កម្រិតខ្ពស់នៃការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងសេដ្ឋកិច្ច បានធ្វើឱ្យការអនុវត្តគោលនយោបាយរូបិយវត្ថុទៅលើបរិមាណផ្គត់ផ្គង់រូបិយវត្ថុជាតិមានឥទ្ធិពលតិចតួចបំផុតមកលើសេដ្ឋកិច្ចកម្ពុជា ពោលគឺធនាគារជាតិនៃកម្ពុជាបានបាត់បង់ឯករាជ្យភាពក្នុងការគ្រប់គ្រងប្រព័ន្ធរូបិយវត្ថុរបស់កម្ពុជាទៅហើយ។ មិនតែប៉ុណ្ណោះ សេដ្ឋកិច្ចកម្ពុជាក៏ងាយនឹងទទួលរងវិបត្តិពីខាងក្រៅ ជាពិសេសវិបត្តិនៅសហរដ្ឋអាមេរិក ដែលអាចនឹងប៉ះពាល់ដល់ស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ហើយធនាគារជាតិនៃកម្ពុជានឹងមិនមានឧបករណ៍គោលនយោបាយដែលមានប្រសិទ្ធភាពសម្រាប់ការពារ ឬទប់ទល់នឹងវិបត្តិនេះបានឡើយ។ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងច្រើនក្នុងសេដ្ឋកិច្ច បានធ្វើឱ្យទិសដៅនៃសេដ្ឋកិច្ចកម្ពុជាបង្វែរទៅតាមទិសដៅនៃសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក។ ជាក់ស្ដែង ក្នុងអំឡុងឆ្នាំ២០០៧-២០០៨ នៅពេលដែលវិបត្តិហិរញ្ញវត្ថុពិភពលោកបានកើតឡើង ប្រទេសកម្ពុជាក៏បានទទួលរងឥទ្ធិពលពីវិបត្តិនេះយ៉ាងធ្ងន់ធ្ងរផងដែរ ជាមួយនឹងអតិផរណាខ្ពស់និងផលិតផលក្នុងស្រុកសរុបស្ទើរតែគ្មានកំណើន។

ក្នុងដំណាក់កាលដែលសេដ្ឋកិច្ចកម្ពុជាកំពុងអភិវឌ្ឍន៍នៅឡើយ ការអនុវត្តគោលនយោបាយរូបិយវត្ថុមិនបានពេញលេញពុំមានផលប៉ះពាល់ខ្លាំងក្លាទៅដល់សេដ្ឋកិច្ចកម្ពុជាឡើយ ដោយសារតែប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាមិនទាន់មានភាពស្មុគស្មាញ និងជឿនលឿនខ្លាំង។ ទោះយ៉ាងណា នៅក្នុងរយៈពេលវែង ក្នុងពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកាន់តែមានការរីកចម្រើន និងប្រទាក់ក្រឡា ការកំណត់និងអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព គឺចាំបាច់ណាស់ដើម្បីធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព បញ្ចៀសវិបត្តិដែលអាចកើតឡើង និងការពារសេដ្ឋកិច្ចពីហានិភ័យនិងបញ្ហាប្រឈមនានា ដែលបណ្ដាលមកពីកត្តាទាំងក្រៅស្រុកនិងក្នុងស្រុក។ ហេតុនេះ ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយនឹងអាចឱ្យធនាគារជាតិនៃកម្ពុជាមានឧបករណ៍គោលនយោបាយរូបិយវត្ថុគ្រប់គ្រាន់ និងអាចអនុវត្តគោលនយោបាយរូបិយវត្ថុបានពេញលេញនិងប្រកបដោយប្រសិទ្ធភាព។ ជាទូទៅ ឧបករណ៍គោលនយោបាយរូបិយវត្ថុដែលមានប្រសិទ្ធភាពនិងនិយមប្រើដោយធនាគារកណ្ដាលនៅលើពិភពលោក គឺអត្រាការប្រាក់គោល។ សម្រាប់កម្ពុជា ធនាគារជាតិនៃកម្ពុជាមិនទាន់អាចប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុនេះបាននៅឡើយទេ ពីព្រោះ

កម្រិតខ្ពស់នៃដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ច បានធ្វើឱ្យអត្រាការប្រាក់គោលដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា មិនមានឥទ្ធិពលលើឥណទាននិងប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិក ដែលគ្របដណ្តប់មួយភាគធំនៃឥណទាននិងប្រាក់បញ្ញើសរុប។

គួរបញ្ជាក់ថា អត្រាការប្រាក់គោលជាឧបករណ៍គោលនយោបាយរូបិយវត្ថុដែលត្រូវបានប្រើសម្រាប់គ្រប់គ្រងអតិផរណា កំណត់ប្រតិបត្តិការសន្ទនីយភាពប្រចាំថ្ងៃ កំណត់អត្រាទីផ្សារ និងផ្តល់សញ្ញាពីជំហារនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។ ការដំឡើងឬបញ្ចុះអត្រានេះនឹងមានឥទ្ធិពលទៅលើការកំណត់អត្រាការប្រាក់ឥណទាន របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ ជាក់ស្តែង នៅពេលធនាគារកណ្តាលដំឡើងអត្រាការប្រាក់គោល គ្រឹះស្ថានទាំងនោះនឹងដំឡើងអត្រាការប្រាក់លើឥណទានរបស់ពួកគេផងដែរ ដោយសារប្រភពទុនដែលបានមកពីកម្ចីនៅលើទីផ្សារអន្តរធនាគារ ឬកម្ចីបុនហិរញ្ញប្បទានរយៈពេលខ្លីរបស់ធនាគារកណ្តាល មានថ្លៃដើមខ្ពស់ជាងមុន។ ការដំឡើងនេះអាចធ្វើឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ផ្តល់ឥណទានដល់អតិថិជនបានតិចជាងមុន ដែលជាលទ្ធផលនាំឱ្យបរិមាណផ្គត់ផ្គង់រូបិយវត្ថុក្នុងសេដ្ឋកិច្ចថយចុះ។ ចំណែកឯនៅពេលធនាគារកណ្តាលបញ្ចុះអត្រាការប្រាក់គោលវិញ អត្រាការប្រាក់ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនឹងថយចុះ ដោយសារថ្លៃដើមប្រភពទុនទាបជាងមុន។ ការថយចុះនេះធ្វើឱ្យគ្រឹះស្ថានទាំងនោះអាចផ្តល់ឥណទានទៅឱ្យអតិថិជនបានច្រើនជាងមុន ដែលជាលទ្ធផលនាំឱ្យបរិមាណផ្គត់ផ្គង់រូបិយវត្ថុក្នុងសេដ្ឋកិច្ចកើនឡើង។

ដូចនេះ ការប្រើប្រាស់រូបិយវត្ថុជាតិកាន់តែទូលំទូលាយនៅគ្រប់វិស័យទាំងអស់នឹងផ្តល់លទ្ធភាពឱ្យធនាគារជាតិនៃកម្ពុជាពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ដើម្បីជំរុញនិងរក្សានិរន្តរភាពកំណើន ដោយសារបរិមាណផ្គត់ផ្គង់រូបិយវត្ថុមានឥទ្ធិពលដោយផ្ទាល់ទៅលើសេដ្ឋកិច្ចរូបវន្ត (ផលិតកម្ម និងការងារ)។ រូបិយវត្ថុជាតិមិនត្រឹមតែជាមធ្យោបាយសម្រួលដល់ប្រតិបត្តិការដោះដូរក្នុងស្រុកឱ្យប្រព្រឹត្តិទៅដោយរលូនស្ថិតក្នុងបរិការណ៍ដែលទីផ្សារមានលក្ខណៈសុខដុមនីយកម្ម និងសមាហរណ-កម្មប៉ុណ្ណោះទេ តែថែមទាំងជាឧបករណ៍នៃគោលនយោបាយសេដ្ឋកិច្ចដ៏ចម្បងសម្រាប់លើកកម្ពស់ភាពរឹងមាំ និងវិបុលភាពសេដ្ឋកិច្ចជាតិ។ ឯករាជ្យភាពនិងប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុ និងប្តូរប្រាក់ពឹងផ្អែកជាចាំបាច់លើវិសាលភាពនៃការប្រើប្រាស់រូបិយវត្ថុជាតិ។ ការអនុវត្តគោល-នយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាពនឹងមានផលវិជ្ជមានអញ្ញមញ្ញ (Synergy Effects) ចំពោះការអនុវត្តគោលនយោបាយសារពើពន្ធ និងគោលនយោបាយដទៃទៀតផងដែរ។

### ៣.៤.៤. បាត់បង់លទ្ធភាពជាអ្នកឱ្យខ្ចីចុងក្រោយ

ដុល្លារូបនីយកម្ម បានធ្វើឱ្យធនាគារកណ្តាលបាត់បង់ឬដើរតួនាទីបានតិចតួចជាអ្នកឱ្យខ្ចីចុងក្រោយ (Lender of Last Resort) ហើយធ្វើឱ្យប្រព័ន្ធធនាគារប្រឈមនឹងហានិភ័យសន្ទនីយភាព។ ដោយប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិកនៅក្នុងប្រព័ន្ធធនាគារមានកម្រិតខ្ពស់ខ្លាំង ធនាគារជាតិនៃកម្ពុជានឹងពុំមានលទ្ធភាពផ្តល់កម្ចីជាប្រាក់ដុល្លារអាមេរិក ដើម្បីទប់ស្កាត់នឹងបញ្ហាសន្ទនីភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបាននោះឡើយ ពីព្រោះធនាគារជាតិនៃកម្ពុជាមិនមានសិទ្ធិបោះពុម្ពក្រដាសប្រាក់ដុល្លារអាមេរិកទេ។ ផ្ទុយមកវិញ ប្រសិនបើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជួបនឹងបញ្ហាសន្ទនីយភាពជាប្រាក់រៀល គ្រឹះស្ថានទាំងនោះអាចមកខ្ចីធនាគារជាតិនៃកម្ពុជាដើម្បីដោះស្រាយបញ្ហានេះបាន ដោយធនាគារជាតិនៃកម្ពុជាជាស្ថាប័នដែលមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀល។ ដូច្នេះ ការប្រើប្រាស់រូបិយវត្ថុជាតិកាន់តែទូលំទូលាយ ជាពិសេសនៅក្នុងប្រព័ន្ធធនាគារ នឹងអនុញ្ញាតឱ្យធនាគារកណ្តាលដើរតួនាទីបានពេញលេញ ជាអ្នកឱ្យខ្ចីចុងក្រោយប្រកបដោយប្រសិទ្ធភាពដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការផ្តល់កម្ចីដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅពេលជួបនឹងបញ្ហាសន្ទនីយភាព។ ការពង្រឹងតួនាទីនេះនឹងបង្កើនជំនឿទុកចិត្តរបស់សាធារណជន វិនិយោគិន សហគ្រាស-ក្រុមហ៊ុន និងភ្នាក់ងារសេដ្ឋកិច្ចផ្សេងទៀតមកលើវិស័យហិរញ្ញវត្ថុ និងលើកកម្ពស់សមត្ថភាពបង្ការវិបត្តិរបស់ធនាគារជាតិនៃកម្ពុជា។

### ៣.៤.៥. បង្កើនចំណាយប្រតិបត្តិការ និងហានិភ័យសន្ទនីយភាព

ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងសេដ្ឋកិច្ច បានបង្កើនចំណាយប្រតិបត្តិការ (ទាំងពេលវេលានិងប្រាក់កាស) ដោយសារអ្នកទិញទំនិញប្រឈមនឹងការខាតបង់អត្រាប្តូរប្រាក់។ ការទទួលទូទាត់ទាំងប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារ បានអនុញ្ញាតឱ្យឈ្មួញមួយចំនួនកេងយកចំណេញតាមរយៈការកំណត់អត្រាប្តូរប្រាក់លើសពីអត្រាប្តូរប្រាក់ទីផ្សារ។ លើសពីនេះប្រជាពលរដ្ឋអាចទទួលបានចំណូលជារូបិយវត្ថុ ដែលខុសពីការចំណាយដែលនាំឱ្យពួកគេងាយទទួលរងហានិភ័យអត្រាប្តូរប្រាក់។ ឧទាហរណ៍ ប្រជាកសិករនិងមន្ត្រីរាជការតែងទទួលប្រាក់ចំណូលរបស់ពួកគេជាប្រាក់រៀល ជាលទ្ធផល ពួកគេអាចនឹងទទួលរងការខាតបង់នៅពេលទិញទំនិញនៅផ្សារទំនើបផ្សេងៗ ដោយសារផ្សារទាំងនោះកំណត់តម្លៃទំនិញជាប្រាក់ដុល្លារអាមេរិក។ ដូចគ្នាដែរ សម្រាប់កម្មករនិងបុគ្គលិកក្រុមហ៊ុនឯកជនដែលទទួលបានចំណូលជាប្រាក់ដុល្លារអាមេរិក អាចប្រឈមនឹងការខាតបង់ពីអត្រាប្តូរប្រាក់ នៅពេលពួកគេចំណាយទៅលើទំនិញដែលកំណត់តម្លៃជា

ប្រាក់រៀល។ ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយចំពោះការទូទាត់ប្រតិបត្តិការនៅក្នុងសេដ្ឋកិច្ច នឹងជួយកាត់បន្ថយចំណាយច្រើនសម្រាប់អ្នកលក់និងអ្នកទិញ។

ដុល្លារូបនីយកម្ម ក៏បានធ្វើឱ្យប្រព័ន្ធធនាគារកម្ពុជាប្រឈមនឹងហានិភ័យតារាងតុល្យការ។ ដោយសារតែដុល្លារូបនីយកម្មមានលក្ខណៈមិនទាំងស្រុង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកម្ពុជានឹងមានភាពងាយរងគ្រោះដែលបណ្តាលមកពីការកាន់ទ្រព្យសកម្ម និងទ្រព្យអកម្មជារូបិយវត្ថុខុសគ្នា (Currency Mismatch)។ ឧទាហរណ៍ ប្រភពមូលនិធិនិងប្រាក់បញ្ញើអតិថិជនរបស់គ្រឹះស្ថានធនាគារភាគច្រើនជាប្រាក់ដុល្លារអាមេរិក ដូចនេះពួកគេអាចទទួលរងហានិភ័យសន្ទនីយភាពនិងអត្រាប្តូរប្រាក់ចំពោះឥណទានដែលត្រូវបានផ្តល់ចារឹកជាប្រាក់រៀល។ ការប្រើប្រាស់រូបិយវត្ថុតែមួយក្នុងប្រព័ន្ធហិរញ្ញវត្ថុនឹងកាត់បន្ថយនូវហានិភ័យទាំងនេះ និងពង្រឹងភាពធន់នឹងវិបត្តិរបស់ប្រព័ន្ធហិរញ្ញវត្ថុ។

### ៣.៤.៦. មិនបានចូលរួមលើកស្ទួយអត្តសញ្ញាណជាតិ

ការប្រើប្រាស់ប្រាក់ដុល្លារអាចធ្វើឱ្យបាត់បង់អត្តសញ្ញាណជាតិ។ រូបិយវត្ថុជាតិដើរតួនាទីជាអត្តសញ្ញាណជាតិមួយតំណាងឱ្យប្រជាជននិងប្រទេសជាតិ។ ហេតុដូចនេះ ការប្រើប្រាស់រូបិយវត្ថុជាតិតែមួយ គឺជាមោទនភាពជាតិនិងជាការលើកកម្ពស់ស្មារតីជាតិនិយម ភាពជឿជាក់លើរដ្ឋាភិបាល និងប្រទេសជាតិ និងសាមគ្គីភាពក្នុងចំណោមប្រជាជននៃសង្គមមួយ។ តាមរយៈរូបភាពនៅលើរូបិយវត្ថុជាតិ ប្រជាជនដែលកាន់រូបិយវត្ថុជាតិនឹងមើលឃើញជារៀងរាល់ពេលពីទិដ្ឋភាពទាំងផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ សាសនា និងសេដ្ឋកិច្ច ដូចជាវីរៈបុរសជាតិរបស់ខ្លួន ហេតុការណ៍សំខាន់ៗដែលបានកើតឡើងនៅក្នុងប្រទេស រូបភាពសម្បត្តិវប្បធម៌ ក៏ដូចជាភាពរីកចម្រើននៃសង្គមជាតិ។ រូបភាពទាំងនេះនឹងរំឭកជារៀងរាល់ពេលថា ប្រជាជនដែលកាន់រូបិយវត្ថុនោះស្ថិតនៅក្នុងសង្គមតែមួយមានភាពទាក់ទងគ្នាយ៉ាងជិតស្និទ្ធ និងមានជោគវាសនាតែមួយ។ លើសពីនេះ វត្តមានរូបិយវត្ថុជាតិបានបង្ហាញពីអធិបតេយ្យភាពនិងឯករាជ្យភាពនៃប្រទេសមួយទាំងផ្នែករូបិយវត្ថុ សេដ្ឋកិច្ច ហិរញ្ញវត្ថុ សង្គម និងនយោបាយ។ មិនតែប៉ុណ្ណោះ ដុល្លារូបនីយកម្មបានក្លាយជាឧបសគ្គមួយក្នុងការជំរុញសមាហរណកម្មក្នុងតំបន់ផងដែរ នៅក្នុងក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលប្រទេសនីមួយៗខិតខំប្រើប្រាស់រូបិយវត្ថុផ្ទាល់ខ្លួនក្នុងប្រតិបត្តិការសេដ្ឋកិច្ចតំបន់ ដោយកាត់បន្ថយការពឹងផ្អែកលើប្រាក់ដុល្លារអាមេរិក ដើម្បីលើកកម្ពស់អត្តសញ្ញាណជាតិ ព្រមទាំងឯករាជ្យភាពនិងអធិបតេយ្យភាពរូបិយវត្ថុនិងសេដ្ឋកិច្ចនៃប្រទេសអាស៊ាន។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ដុល្លារូបនីយកម្មនៅកម្ពុជា ជាបាតុភូតដែលកើតឡើងដោយឯកឯងនិងមិនមានការបង្ខំពីសំណាក់រាជរដ្ឋាភិបាល ឬនរណាម្នាក់ឡើយ។ ជាចម្បង ដុល្លារូបនីយកម្មបានកកើតនៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា ដោយកត្តាបួន រួមមាន កត្តាប្រវត្តិសាស្ត្រ កត្តានយោបាយ កត្តាសេដ្ឋកិច្ច និងកត្តាសង្គម។ កត្តាទាំងនេះអាចសរុបបញ្ចូលគ្នាដើម្បីបកស្រាយទៅតាមកត្តាផ្គត់ផ្គង់ និងកត្តាតម្រូវការ។ សម្រាប់កត្តាផ្គត់ផ្គង់ ប្រាក់ដុល្លារអាមេរិកបានហូរចូលមកប្រទេសកម្ពុជាជាបន្តបន្ទាប់ ជាពិសេសក្នុងអំឡុងសម័យ លន់ នល់ និងឆ្នាំ១៩៩២-១៩៩៣ ដែលអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNTAC) បានចំណាយទឹកប្រាក់សរុប ១,៧ប៊ីលានដុល្លារអាមេរិកសម្រាប់ការជួយរៀបចំប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះ ប្រាក់ដុល្លារអាមេរិកក៏បានហូរចូលមកដោយសារការបើកចំហសេដ្ឋកិច្ច ដែលអនុញ្ញាតឱ្យមានលំហូរវិនិយោគដើមទុនជាប្រាក់ដុល្លារអាមេរិកចូលមកកម្ពុជា។ ចំណែកឯខាងផ្នែកតម្រូវការវិញ ការធ្លាក់ចុះយ៉ាងគំហុកនៃតម្លៃប្រាក់រៀល ការកើនឡើងនៃអតិផរណាដល់កម្រិតបីខ្ទង់ និងភាពទន់ខ្សោយនៃគោលនយោបាយរាជរដ្ឋាភិបាលនិងធនាគារកណ្តាល បានធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល ហើយតម្រូវការប្រាក់រៀលនៅលើទីផ្សារក៏បានធ្លាក់ចុះជាលំដាប់ ដែលនាំឱ្យពួកគេងាកមករកប្រាក់ដុល្លារអាមេរិកដើម្បីការពារអំណាចទិញរបស់ពួកគេ។

ដុល្លារូបនីយកម្មបាននាំមកទាំងផលប្រយោជន៍និងហានិភ័យចំពោះកម្ពុជា។ ចំពោះអត្ថប្រយោជន៍ ដុល្លារូបនីយកម្មបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ហើយបានបង្កើនសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងអន្តរជាតិ ក្នុងពេលដែលកម្រិតសមាហរណកម្មកម្ពុជានៅមានកម្រិតដ៏ទាបនៅឡើយ នាអំឡុងពេលដែលសេដ្ឋកិច្ចកំពុងចាប់ផ្តើមលូតលាស់។ ផលប្រយោជន៍ទាំងនោះត្រូវបានឆ្លុះបញ្ចាំងក្នុងរូបភាព៖ ការកាត់បន្ថយថ្លៃដើមនៃដើមទុនសម្រាប់ការវិនិយោគ ការជួយអភិវឌ្ឍវិស័យហិរញ្ញវត្ថុក្នុងពេលដែលប្រជាជនកម្ពុជាបានបាត់បង់ជំនឿទុកចិត្តមកលើប្រព័ន្ធហិរញ្ញវត្ថុ និងរូបិយវត្ថុនាដំណាក់កាលដំបូង ការបង្កើនវិន័យវិស័យសារពើពន្ធ ការសម្រួលការទូទាត់ពាណិជ្ជកម្មអន្តរជាតិ ការទាក់ទាញការវិនិយោគពីបរទេស កម្រិតទាបនៃអតិផរណា ស្ថិរភាពអត្រាប្តូរប្រាក់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ក្នុងន័យនេះ ដុល្លារូបនីយកម្មបានជួយស្តារស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឱ្យប្រសើរឡើងវិញពីសម័យកាលអតុល្យភាពម៉ាក្រូសេដ្ឋកិច្ច។

យ៉ាងណាមិញ ក្នុងរយៈពេលវែង នៅពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកាន់តែមានការរីកចម្រើននិងប្រទាក់ក្រឡា ដុល្លារូបនីយកម្មមិនត្រឹមតែធ្វើឱ្យកម្ពុជាខាតបង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់រៀលប៉ុណ្ណោះទេ ថែមទាំងអាចបង្កជាហានិភ័យ និងមានគុណវិបត្តិកាន់តែច្រើនចំពោះសេដ្ឋកិច្ចកម្ពុជា ជាពិសេស ធ្វើឱ្យមានភាពផុយស្រួយទៅនឹងការប៉ះទង្គិចទាំងដោយកត្តាក្នុងស្រុកនិងខាងក្រៅ។ ម្យ៉ាងទៀត ដុល្លារូបនីយកម្មបានក្លាយជាឧបសគ្គមួយក្នុងការជំរុញសមាហរណកម្មក្នុងតំបន់ផងដែរ នៅក្នុងក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលប្រទេសនីមួយៗខិតខំប្រើប្រាស់រូបិយវត្ថុផ្ទាល់ខ្លួនក្នុងប្រតិបត្តិការសេដ្ឋកិច្ចតំបន់ ដោយកាត់បន្ថយការពឹងផ្អែកលើប្រាក់ដុល្លារអាមេរិក។ លើសពីនេះ ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបានបង្កជាការលំបាកខ្លាំងដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ ដោយវាបានកាត់បន្ថយប្រសិទ្ធភាពគោលនយោបាយ និងរារាំងដល់ការប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុដូចជា អត្រាការប្រាក់គោល ជាដើម។ ជាងនេះទៅទៀត ដោយរូបិយវត្ថុជាតិតំណាងឱ្យអត្តសញ្ញាណ វប្បធម៌ សាសនា និងប្រវត្តិសាស្ត្ររបស់ជាតិយើង ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក និងការមិនចូលរួមប្រើប្រាស់រូបិយវត្ថុរបស់ជាតិយើង គឺមានន័យថាមិនបានចូលរួមលើកស្ទួយដល់អត្តសញ្ញាណជាតិរបស់យើង។

ថ្វីត្បិតតែ ក្នុងរយៈពេលខ្លី ដុល្លារូបនីយកម្មបានផ្តល់នូវអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជានៅក្នុងដំណាក់កាលដែលកម្ពុជាកំពុងអភិវឌ្ឍសេដ្ឋកិច្ច នៅក្នុងរយៈពេលវែង នៅពេលដែលសេដ្ឋកិច្ចកម្ពុជាចាប់ផ្តើមមានការរីកចម្រើន ជឿនលឿន និងមានទំហំកាន់តែធំ ដុល្លារូបនីយកម្មនឹងរារាំងដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុដើម្បីការពារប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពីវិបត្តិ ហានិភ័យ និងបញ្ហាប្រឈមដែលបណ្តាលមកពីកត្តាខាងក្នុងនិងខាងក្រៅ។ ដូចនេះ ដើម្បីបន្តជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ននិងហានិភ័យទាប ព្រមទាំងដើម្បីលើកស្ទួយដល់អត្តសញ្ញាណជាតិយើង ប្រជាពលរដ្ឋខ្មែរទាំងអស់គួរចាប់ផ្តើមងាកមកប្រើប្រាស់រូបិយវត្ថុជាតិ "ប្រាក់រៀល" និងកាត់បន្ថយការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបន្តិចម្តងៗ។

## ២. អនុសាសន៍

ដើម្បីធ្វើបដិដុល្លារូបនីយកម្មជាសន្សឹមៗប្រកបដោយភាពប្រុងប្រយ័ត្ន និងហានិភ័យទាប គោលនយោបាយនិងវិធានការគាំទ្រការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល គួរត្រូវបានដាក់ចេញដោយស្របតាមគោលការណ៍យន្តការទីផ្សារ រួមមាន៖ ១/- ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងជំនឿទុកចិត្តមកលើប្រាក់រៀលតាមរយៈការរក្សាស្ថិរភាពថ្លៃ និងតម្លៃប្រាក់រៀល ដើម្បីការពារអំណាចទិញ

របស់ប្រាក់រៀល ២/- ការពង្រឹងគុណភាព និងសោភ័ណភាពក្រដាសប្រាក់រៀលឱ្យកាន់តែមានភាពទាក់ទាញ ពិបាកក្នុងការក្លែងបន្លំ ស្អាត និងងាយស្រួលកាន់ ៣/- ការបំពេញតម្រូវការប្រាក់រៀលរបស់សេដ្ឋកិច្ចតាមរយៈការចាក់បញ្ចូលសន្ទនីយភាពជាប្រាក់រៀលចូលទៅក្នុងសេដ្ឋកិច្ច ៤/- ការលើកទឹកចិត្ត និងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាសាធារណជននានាប្រើប្រាស់ប្រាក់រៀលដូចជា ការដំឡើងសន្សឹមៗនូវអត្រាប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើនិងកម្ចី (Borrowings) ជាប្រាក់ដុល្លារអាមេរិក ការកាត់បន្ថយជាបណ្តើរៗទៅលើអត្រាការប្រាក់ឥណទានជាប្រាក់រៀល និងការយកកម្រៃសេវាផ្សេងៗជាប្រាក់រៀលទាបជាងរូបិយប័ណ្ណ ៥/- តម្រូវឱ្យការបង់ពន្ធ និងការបង់ថ្លៃសេវាសាធារណៈផ្សេងៗជាប្រាក់រៀល ៦/- ការផ្សព្វផ្សាយនិងអប់រំពីសារៈសំខាន់នៃរូបិយវត្ថុជាតិចំពោះសេដ្ឋកិច្ចនិងប្រទេសជាតិទៅដល់សាធារណជន និងកូនចៅជំនាន់ក្រោយឱ្យយល់ដឹងកាន់តែច្បាស់ និង ៧/- ការលើកទឹកចិត្តឱ្យអាជីវករកំណត់ថ្លៃទំនិញ និងសេវាជាប្រាក់រៀលដែរ។

# ឯកសារយោង

# ឯកសារយោង

ធនាគារជាតិនៃកម្ពុជា, (២០១៥), *រចនាសម្ព័ន្ធ*, យកពីគេហទំព័រៈ https://www.nbc.org.kh/about_the_bank/structure_of_nbc.php, ចូលមើលនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៧

ធនាគារជាតិនៃកម្ពុជា, (២០១៦), *តួនាទីធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល*

